# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី៣៤ លេខ ៣ ខែ មីនា

ព.ស. ២៥០៤ គ.ស. ១៩៦២

– ភ្នំពេញ –

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ


*ផ្នែកសាសនា* បញ្ជីរឿង *ទំព័រ*

– លោកុត្តរចិត្ត អ្នកឧកញ៉ា ទា-សាន អតីតរដ្ឋមន្ត្រី រៀបរៀង . . . . . . . ២៤៦
– ព្រះអភិធម្មបិដក (គម្ពីរព្រះយមកៈ) (ត) លោកប៉ូ-ប៉ុំ ប្រែរៀបរៀង . . . . . . ២៥៧
– មធុរសវាហិណី(ត)សម្ដេចព្រះធម្មលិខិតល្វី-ឯម ប្រែ ព្រះញាណកោសលញ-ឈិនពិនិត្យ ២៦៣
– មហោសថជាតក(ត) លោក អឹម-ភន ចម្លងពីសាស្ត្រាស្លឹករឹតព្រះពុទ្ធវង្ស កឹម-តួរ ពិនិត្យ ២៧១
– រឿងនារទកស្សប កាព្យពាក្យ ៩ (តចប់) លោក យូរ-អ៊ុន និពន្ធ. . . . . . . ២៧៨
– សម្មោទមានាជាតក ព្រះញាណកោសល ញាណ-ឈិន រៀបរៀង . . . . . . . ៣០០

*ផ្នែកអក្សរសាស្ត្រ*

– បញ្ហាផ្សាយអក្សរសាស្ត្រនៅបច្ចុប្បន្នកាល លោក លី-ធាមតេង រៀបរៀង. . . . ៣០៦
– ពាក្យខ្មែរប្រែពីបរទេស ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ "ក". . . ៣១៤
– វចនានុក្រមសំស្ក្រឹត-ខ្មែរ (ត) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . . . ៣១៥
– រឿងសាមកុក (ត) ឧកញ៉ា នូ-កន ប្រែ . . . . . . . . . ៣១៦
– រឿងព្រេងចិន (ត) លោក ភិយ ប៊ុក ប្រែរៀបរៀង . . . . . . . ៣៣៤
– រឿងព្រេងប្រាជ្ញសុភាសិត ៤ ជខ (តចប់) . . . . . . . . . . ៣៤០
– រឿងព្រេងប្រទេសយូហ្គោស្លាវី ភិក្ខុ ម៉ែន-រៀម ប្រែពីភាសាអង់គ្លេស . . , . . ៣៤៦

*ផ្នែកកំណត់ទិនប្បវត្តិការណ៍*

– បណ្ណាល័យពុទ្ធសាសនាមួយនៃប្រទេសកម្ពុជា នៅក្រុងរង្គូន (សហភាពភូមា) . . . ៣៥៧



មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជា ២៣០៛០០

34è Année — N° 2 — Février 1962

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut-Bouddhique de Phnom-Penh

## SOMMAIRE

### Partie religieuse

—Lokottaracitta par l'Oknha TEA-SAN. . . . . . . . . . . 246
—Prah Abhidhamma pitaka (Kampi prah Yamaka) par M. BOU-PO (suite) . . . . . . . . . . . . . 257
—Madhurasavahini traduit par Samdech Prah Dhammalikhita LOUIS-EM, revu et corrigé par Vén. NHEAN-CHHŒUN (suite) . . . . . . . . . . . 263
—Mahosotha Jataka relevé du manuscrit sur feuilles de latanier par M. IM-PHON, revu et corrigé par Vén. KEM-TO (suite). . . . . . . . . . . 271
—Histoire de Naradakassapa en vers par M. YOU-OUN (suite et fin) . . . . . . . . . . . . . . . . 278
—Sammodamanajataka par Vén NHEAN-CHHŒUN . . . 300

### Partie littéraire

—Diffusion de la littérature Contemporaire par M. LY-THEAM TÉNG . . . . . . . . . . . . . 306
—Activités de la Commission Nationale de l'Education section « A » . . . . . . . . . . . . . . . . . 314
—Dictionnaire Sanscrit-Khmèr par Vén. PANG-KHAT(suite) 315
—Histoire de Sam-Kok traduite par l'Oknha NOU-KAN(suite) 316
—Contes et Légendes populaires de la Chine traduits par M. RAY-BUC (suite). . . . . . . . . . . . 334
—Commentaires des proverbes cambodgiens par la Commission des Mœurs et Coutumes(suite et fin). 340
—Légende de Yougoslavie traduit par Vén. MEN-REAM. . . 346

### Notes et Chroniques

—Bibbliothèque bouddhique Khmère à Rangoon (Birmanie) 357

Abonnement annuel (comprenant 12 numéros) : 230 f 00

# សព្ទសាធុការពរឆ្នាំថ្មី

ឱកាសផ្លាស់ឆ្នាំឆ្លូវ, ខាលចូលនៅជាកសិ
នៃជនខ្មែរប្រុសស្រី, សកករាជថ្មីកើនដឿនកាំ ៖
គឺព្រះពុទ្ធស័ក ពីរពាន់ជាក់ប្រាំរយប្រាំ,
គ្រិស្តស័កមួយពាន់ឆ្នាំ ប្រាំបួនរយហុកសិបពីរ ៗ

ពុទ្ធសាសនៈ បណ្ឌិត្យៈជាមន្ទីរ
ផ្សាយធម៌ដ៏គម្ពីរ ដែលជាកេរ្តិ៍ពុទ្ធសាស្នា ៗ
សូមបួងសួងប្រសិទ្ធិ ត្រៃរ័ត្នពិតក្នុងលោកា
ទាំងសូមពួកទេវតា ថែរក្សាការពារជាតិ ៖

មួយ សូមព្រះមហា- ក្សត្រិយានីជាអាទិ
ជាព្រះមាតាជាតិ ចំរើនសុខជោគសួស្តី !

ពីរ សូមព្រះប្រមុខ ជាឪពុកឯករាជ្យថ្មី
ប្រកបជ័យសិរី មានព្រះជន្មជាងរយឆ្នាំ !

បី សូមរាជរដ្ឋា- ភិបាលជាអ្នកឧបត្ថម្ភ
ឲ្យពួកទេពថែទាំ ជួយឲ្យបានសុខមនោរម្យ !

បួន សូមពួកពលរដ្ឋ ខ្មែរប្រាកដក្នុងសង្គម
ចំរើនសុខឧត្តម សំបូរធនធានភោគា !

ពិសេសសូមសន្តាន ជាអ្នកមានចិត្តជ្រះថ្លា
អាន កម្ពុជសុរិយា គបសុខានិរន្តរ៍ហោង !

យ.អិ.

ផ្នែកសាសនា

# លោកុត្តរចិត្ត

*អ្នកឧកញ៉ា ណា-សាឆ អតីតរដ្ឋមន្ត្រីរៀបរៀង*

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលាមក ឲ្យធ្វើល្អទៅ ។
ឲ្យជុំសខាត់ចិត្ត កុំឲ្យហ្មងសៅ
នេះឯងលោកហៅ ពុទ្ធសាសនា ។

ប.ព.

## ១– អត្ថន័យនៃលោកុត្តរចិត្ត

ដើម្បីឲ្យងាយយល់ នូវអត្ថរសនៃលោកុត្តរចិត្តបានច្បាស់លាស់នោះ ខ្ញុំយល់ឃើញថា គួរតែលើកយកលោកិយចិត្តមកបញ្ជាក់ឲ្យដឹងនូវអត្ថន័យដូចម្តេចជាមុនសិន ពីព្រោះលោកុត្តរចិត្តនឹងលោកិយចិត្តមានន័យផ្ទុយគ្នាស្រឡះ ដូចមានសេចក្តីអធិប្បាយបញ្ជាក់ខាងក្រោមនេះស្រាប់ ។

ឯលោកិយចិត្ត គឺចិត្តរបស់សត្វដែលមានក្នុងលោក ពោលគឺចិត្តរបស់លោកិយសត្វ ដែលសៅហ្មងដោយមន្ទិលផ្សេង ៗ នោះឯង ។

រីឯលោកុត្តរចិត្តវិញ គឺសំដៅចិត្តរបស់អរិយបុគ្គលដែលបានត្រាស់ដឹងនូវលោកុត្តរធម៌ ពោលគឺចិត្តដែលអរិយបុគ្គលបានដុសខាត់ជំរះដោយសីល

សមាធិនិងបញ្ញា ឲ្យស្អាតបរិសុទ្ធផូរផង់រួចផុតស្រឡះចាកគ្រឿងសៅហ្មងទាំងឡាយនោះឯង ។

ក្នុងចំនួនចិត្ត ៨៩ ដួង ដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៤ មានកាមាវចរភូមិជាដើមនោះ មានលោកុត្តរចិត្ត ៨ ដួងចែកចេញជាមគ្គចិត្ត ៤ ដួង និងផលចិត្ត ៤ ដួង ។

តើមគ្គចិត្ត ៤ ដួង និងផលចិត្ត ៤ ដួងនោះ ជាចិត្តរួចចាកគ្រឿងសៅហ្មងអ្វីខ្លះទៅ ? ។

រីឯមគ្គចិត្ត ៤ ដួង និងផលចិត្ត ៤ ដួងនោះគឺ សំដៅយកចិត្តដ៏បរិសុទ្ធផូរផង់រួចផុតស្រឡះចាកអាសវៈ៤ និងសំយោជនៈ១០ ហើយនិងតណ្ហា ៣ ពីព្រោះកិលេសទាំង ៣ ប្រភេទនេះ កាលបើមកកើតនៅក្នុងខន្ធសន្តានហើយ រមែងទុកជាបុព្វហេតុអាចកាំងដំពាស់មិនឲ្យលោកុត្តរចិត្តកើតឡើងបានសោះឡើយ ។

ដោយហេតុនេះ ទើបមគ្គចិត្ត ៤ ដួងនោះ ទុកជាចិត្តដែលកើតមានឡើង ដោយសមុច្ឆេទប្បហាន គឺការលះដោយដាច់ខាតនូវអាសវៈ ៤ និងសំយោជនៈ ១០ ហើយនិងតណ្ហា ៣ នោះ រីឯផលចិត្ត ៤ ដួងនោះ ទុកជាចិត្តដែលកើតមានឡើងដោយសមុច្ឆេទវិមុត្តិ គឺការរួចចាកដោយដាច់ខាតនូវអាសវៈ៤ និងសំយោជនៈ១០ ហើយនិងតណ្ហា៣ នោះឯង។

មុននឹងធ្វើអត្ថាធិប្បាយបញ្ជាក់អំពីលក្ខណសម្បត្តិនៃមគ្គចិត្តមួយៗ

នឹងផលចិត្តមួយៗ មានដូចម្តេចខ្លះនោះ ខ្ញុំយល់ឃើញថា គប្បីលើកយកអាសវៈ ៤ នឹងសំយោជនៈ ១០ ហើយនឹងគណ្ត ៣ នោះមកអធិប្បាយបញ្ជាក់ឲ្យដឹង តើកិលេស ៣ ប្រភេទនេះ មានន័យនឹងមានលក្ខណៈដូចម្តេចខ្លះ ទើបកិលេស ៣ ប្រភេទនោះ ត្រូវបានចាត់ទុកជាបុព្វហេតុករាំងដំណាស់មិនឲ្យលោកុត្តរចិត្តអាចសម្រេចកើតឡើងបាន ដូចមានសេចក្តីបរិយាយតទៅនេះ ៖

## ២- អាសវៈ ៤

ឯ អាសវៈ គឺសំដៅយកកិលេសដែលជាគ្រឿងត្រាំទៅក្នុងខន្ធសន្តាន មាន ៤ យ៉ាងគឺ កាម ១ ហៅថា កាមាសវៈ, ទិដ្ឋិ ១ ហៅថា ទិដ្ឋាសវៈ, ភព ១ ហៅថា ភវាសវៈ នឹង អវិជ្ជា ១ ហៅថា អវិជ្ជាសវៈ ។

តើកិលេស ៤ យ៉ាង គឺ កាម, ទិដ្ឋិ, ភព, នឹង អវិជ្ជា មាន អត្ថន័យដូចម្តេចទៅ ? ។

បើតាមខ្ញុំយល់ អត្ថន័យនៃកិលេស ៤ នោះគឺ៖

១- កាម សំដៅយកសេចក្តីប្រាថ្នា ២ ប្រការ គឺសេចក្តីប្រាថ្នានូវវត្ថុដែលជាគ្រឿងលួងលោមចិត្តឲ្យរីករាយ ហៅថាវត្ថុកាម ១ នឹងសេចក្តីប្រាថ្នានូវកិលេសដែលជាគ្រឿងញុះញង់ចិត្ត ឲ្យស្រេបស្រាលសប្បាយ ហៅថា កិលេសកាម ១ ។

២– ទិដ្ឋិ សំដៅយកសេចក្ដីយល់ឃើញខុស មានសេចក្ដីយល់ឃើញខុសចំពោះរូបកាយហៅថា សក្កាយទិដ្ឋិជាដើមនោះ ។

៣– ភព សំដៅយកដំណើរកើតនៃសត្វ ដោយកម្មជាកុសលនិងកម្មជាអកុសលនោះ ។

៤– អវិជ្ជា សំដៅយកសេចក្ដីល្ងង់មិនដឹងនូវអរិយសច្ច៤ ប្រការ ។

រីឯកិលេស ៤ នេះ កាលបើមកកើតត្រាំនៅក្នុងខន្ធសន្ដានហើយ តែងធ្វើចិត្តឲ្យសៅហ្មង ឲ្យជាប់ជំពាក់យ៉ាងស្អិតនឹងកាមគុណជាលំដាប់ ។

ម្យ៉ាងទៀត កិលេស ៤ នេះ បណ្ឌិតលោកចាត់ទុកជាជា ឱឃៈ គឺ អន្លង់ទឹកមាន ៤ គឺ អន្លង់កាម ១ ហៅថា កាមោឃៈ, អន្លង់ទិដ្ឋិ ១ ហៅថា ទិដ្ឋោឃៈ, អន្លង់ភព ១ ហៅថា ភវោឃៈ និងអន្លង់អវិជ្ជា ១ ហៅថា អវិជ្ជោឃៈ ។

ឯអន្លង់ ៤ នេះ ត្រៀមចាំតែពន្លង់សត្វឲ្យលង់លិចក្នុងជលសាគរ ពោលគឺវដ្ដសង្សារ មិនឲ្យសត្វធ្វើដំណើរឆ្លងចេញរួចផុតចាកត្រៃលោកបានឡើយ ។

ម្យ៉ាងវិញទៀត កិលេស ៤ នេះ បណ្ឌិតលោកចាត់ទុកជាគ្រឿងប្រកបហៅថា យោគៈ មាន ៤ គឺ ទិដ្ឋិយោគៈ គ្រឿងប្រកបគឺ ទិដ្ឋិ ១, កាមយោគៈ គ្រឿងប្រកបគឺ កាម ១, ភវយោគៈ គ្រឿងប្រកបគឺ ភព ១ និង អវិជ្ជាយោគៈ គ្រឿងប្រកបគឺ អវិជ្ជា ១ ពីព្រោះ

១– ទិដ្ឋិយោគៈ ទុកជាគ្រឿងប្រកបសំយោជនៈ ៣ ខាងដើម គឺ សក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ និងសីលព្វតបរាមាសៈ ១ ឲ្យមានដំណើរប្រព្រឹត្តិទៅបានជាប្រក្រតីនោះ ។

២– កាមយោគៈ ទុកជាគ្រឿងប្រកបសំយោជនៈ ២ បន្ទាប់មក គឺ កាមរាគៈ និងបដិឃៈ ឲ្យមានដំណើរប្រព្រឹត្តិទៅបានជានិរន្តរ៍នោះ ។

៣– ភវយោគៈ ទុកជាគ្រឿងប្រកបសំយោជនៈ ៤ បន្ទាប់មកទៀតគឺ រូបរាគ, អរូបរាគ, មានៈ និងឧទ្ធចៈ ឲ្យមានដំណើរប្រព្រឹត្តិទៅបានជាអចិន្ត្រៃយនោះ ។

៤– អវិជ្ជាយោគៈ ទុកជាគ្រឿងប្រកបសំយោជនៈ ១ ខាងចុង គឺ អវិជ្ជា ឲ្យមានដំណើរប្រព្រឹត្តិទៅបានជាធម្មតានោះឯង ។

ដោយហេតុនេះ ទើបអាសវៈ ៤ ត្រូវចាត់ទុកជាបុព្វហេតុទី ១ ដែលកំពង់ជំទាស់មិនឲ្យលោកុត្តរចិត្ត អាចសម្រេចកើតឡើងបានដោយប្រការដូច្នេះឯង ។

## ៣– សំយោជនៈ ១០

លំដាប់តទៅនេះ ខ្ញុំនឹងលើកយកសំយោជនៈ ១០ មកធ្វើអត្ថាធិប្បាយបញ្ជាក់វែកញែកឲ្យឃើញ តើសំយោជនៈ ១០ នោះ ជាកិលេសមានលក្ខណៈដូចម្ដេចខ្លះ? ដែលជាហេតុនាំឲ្យបណ្ឌិតលោកចាត់ទុកដូចជា

ចំណងអាចចងរឹតរួតត្បៀតសត្វបង្កប់ទុក ឲ្យនៅវិលវល់ក្នុងវដ្តសង្សារបាន ដូចម្តេចខ្លះ? ដូចមានសេចក្តីអធិប្បាយបញ្ជាក់តទៅនេះ ៖

១- សក្កាយទិដ្ឋិ គឺសេចក្តីយល់ឃើញខុសចំពោះរូបកាយ ។

ឯសក្កាយទិដ្ឋិនេះ គឺសំដៅការយល់ឃើញខុសចំពោះកាយមាន ២០ ប្រការ មានការយល់ឃើញរូបថាជាខ្លួន, ឃើញវេទនាថាជាខ្លួន, ឃើញសញ្ញាថាជាខ្លួន ។ល។ ជាដើម ។

ឯសេចក្តីយល់ឃើញខុសដូច្នេះ ជាហេតុនាំឲ្យប្រកាន់មាំថា រូបកាយនេះ ជារបស់អាត្មាអញ, ជាអាត្មាអញ នឹងជាខ្លួនប្រាណរបស់អាត្មាអញ ។

សត្វណាមានសន្តានចិត្តសៅហ្មង ដោយសក្កាយទិដ្ឋិនេះហើយ សត្វនោះរមែងជាប់ជំពាក់ចិត្ត នឹងរូបកាយ ឬខន្ធ ៥ យ៉ាងស្អិត, វង្វេងភ្លេចខ្លួន, ភ្លេចស្មារតី មិនដឹងថាខន្ធ ៥ នោះជាទោសសោះ ព្រោះខន្ធ ៥ នោះជាគំនរនៃទុក្ខ នឹងជាបន្ទុកមួយដ៏ធ្ងន់ គួរគប្បីតែទម្លាក់ចោលចេញកុំខានឡើយ ។ ដោយហេតុនេះ ទើបបណ្ឌិតលោកចាត់ទុកសក្កាយទិដ្ឋិនេះជាចំណងទី ១ ។

២- វិចិកិច្ឆា គឺសេចក្តីសង្ស័យ ។ ឯវិចិកិច្ឆានេះ សំដៅសេចក្តីសង្ស័យចំពោះហេតុបច្ច័យនៃខន្ធ ៥ ក្នុងកាលទាំង ៣ មាន ១៦ ប្រការ មានសេចក្តីសង្ស័យថាអាត្មាអញកាលពីអតីតធ្លាប់បានកើតមែនឬជាដើម ។

ឯវិចិកិច្ឆានេះ កាលបើមានកើតក្នុងខន្ធសន្តាននៃសត្វហើយ រមែងជាហេតុធ្វើឲ្យសត្វនោះវង្វេងភ្លេចភាំងស្មារតី ពុំដឹងច្បាស់នូវហេតុបច្ច័យដែលជាដើមកំណើតនៃខន្ធ ៥ ព្រមទាំងពុំដឹងច្បាស់នូវឧបាយដែលអាចឲ្យរលាស់ខ្លួនរួចផុតពីខន្ធ ៥ នោះទៀត ។

ដោយហេតុនេះ ទើបវិចិកិច្ឆាត្រូវទុកជាចំណងទី ២ ដោយប្រការដូច្នេះឯង ។

៣- សីលព្វតបរាមាស គឺសេចក្តីជឿបួលចិត្តកប់អាននូវវត្តប្រតិបត្តិខុសទំនង ។ ឯសីលព្វតបរាមាសនេះ សំដៅសេចក្តីជឿហើយព្យាយាមបដិបត្តិ តាមវត្តបដិបត្តិក្រៅព្រះសាសនាដែលជាវត្តបដិបត្តិខុសទំនង ពុំអាចនឹងដឹកនាំដំណើរសត្វឲ្យឆ្ពោះទៅកាន់មគ្គ ផល និព្វានបានឡើយ ។ ដោយហេតុនេះ បានជាបណ្ឌិតលោកចាត់ទុក សីលព្វតបរាមាស ជាចំណងទី ៣ ។

៤- កាមរាគ គឺសេចក្តីត្រេកក្នុងកាម ។ ឯកាមរាគនេះ សំដៅសេចក្តីត្រេកត្រអាលចំពោះឥដ្ឋារម្មណ៍ គឺអារម្មណ៍ដែលជាទីពេញចិត្តមានរូបជាដើម ។ ឯកាមរាគនេះ កាលបើមកកើតក្នុងខន្ធសន្តាននៃសត្វណាហើយ រមែងញុំាងសត្វនោះឲ្យជាប់ជំពាក់ចិត្តនឹងកាមតណ្ហា គឺសេចក្តីប្រាថ្នាចង់ឲ្យបានកើតក្នុងកាមភពជាលំដាប់ ។ ដោយហេតុនេះ បានជាកាមរាគត្រូវទុកជាចំណងទី ៤ ។

៥- បដិឃៈ គឺសេចក្តីថ្នាំងថ្នាក់ចិត្ត ។ ឯបដិឃៈនេះសំដៅសេចក្តីថ្នាំងថ្នាក់ចិត្ត បដិឃារម្មណ៍ គឺអារម្មណ៍ដែលមិនជាទីពេញចិត្តមានរូបជាដើម ។ ឯបដិឃៈនេះកាលបើកើតក្នុងខន្ធសន្តាននៃសត្វណាហើយ រមែងញ៉ាំងសត្វនោះឲ្យអាក់អន់ចិត្ត, ឲ្យតាស់ចិត្ត, ឲ្យខឹងក្រេវក្រោធចំពោះអនិដ្ឋារម្មណ៍នោះ ដែលជាហេតុនាំឲ្យព្យាបាទ គឺសេចក្តីគុំគួនខឹងធ្វើអ្នកដទៃឲ្យវិនាសកើតមានឡើងជាលំដាប់ ។ ដោយហេតុនេះ បានជាបណ្ឌិតលោកចាត់ទុក បដិឃៈជាចំណងទី ៥ ។

៦- រូបរាគ គឺសេចក្តីត្រេកត្រអាលចំពោះរូបភព ។ ឯរូបរាគនេះ ជាភវរាគ គឺជាតម្រេកចង់កើតក្នុងភព, កាលបើកើតក្នុងសន្តានចិត្តសត្វណាហើយ រមែងតែញ៉ាំងសត្វនោះឲ្យជាប់ជំពាក់ចិត្តនឹងភវតណ្ហា គឺសេចក្តីប្រាថ្នាចង់ឲ្យបានកើតក្នុងរូបភពជាលំដាប់ ។ ដោយហេតុនេះ រូបរាគនោះត្រូវចាត់ទុកជាចំណងទី ៦ ។

៧- អរូបរាគ គឺសេចក្តីត្រេកត្រអាលចំពោះអរូបភព ។ ឯអរូបរាគនេះជាភវរាគ គឺតម្រេកចង់កើតក្នុងភពដែរ, កាលបើកើតក្នុងខន្ធសន្តាននៃសត្វណាហើយ រមែងញ៉ាំងសត្វនោះឲ្យជាប់ជំពាក់ចិត្តនឹងវិភវតណ្ហា គឺសេចក្តីប្រាថ្នាចង់កើតក្នុងអរូបភពជាលំដាប់ ។ ដោយហេតុនេះ បានជាបណ្ឌិតលោកចាត់ទុក អរូបរាគនេះ ជាចំណងទី ៧ ។

៨- មានះ គឺសេចក្តីប្រកាន់ខ្លួន ។ ឯមានៈនេះ សំដៅមានះ៣

ប្រការ គឺសេចក្ដីប្រកាន់ខ្លួនថា អាត្មាអញប្រសើរជាងគេ ១ អាត្មាអញស្មើនឹងគេ ១ អាត្មាអញអន់ថយជាងគេ ១ ។

កាលបើសត្វណាមានខន្ធសន្ដានសៅហ្មងដោយមានះ គ្រង់ប្រការណាមួយហើយ, សត្វនោះរមែងបោះបង់ចោលនូវករណីយកិច្ចដែលកំពុងបំពេញ ព្រោះសត្វនោះគិតឃើញថា អាត្មាអញបានប្រសើរជាងគេទៅហើយ, ឬគិតឃើញថា អាត្មាអញបានស្មើនឹងគេទៅហើយ, ឬគិតឃើញថា អាត្មាអញអន់ថយជាងគេពេក ដែលជាហេតុនាំឲ្យសត្វនោះពុំអាចនឹងសម្រេចនូវគុណប្រយោជន៍ជាទីបំផុតនោះបានឡើយ ។ ដោយហេតុនេះ ទើបបណ្ឌិតលោកចាត់ទុកមានះជាចំណងទី ៨ ។

៩– ឧទ្ធច្ចៈ គឺសេចក្ដីរាយមាយ ។ ឯឧទ្ធច្ចៈនេះ សំដៅសេចក្ដីរាយមាយដែលញុំាងចិត្តឲ្យរើរវាយរវែក មិនដឹងជាឆ្លាក់ទៅខាងណាឲ្យប្រាកដសោះ ។ ឯឧទ្ធច្ចៈនេះ កាលបើកើតកងខន្ធសន្ដានៃសត្វណាហើយ រមែងញុំាងសត្វនោះឲ្យចាប់នេះចាប់នោះមិនះគ្មានគ្រង់ណា ដែលជាហេតុនាំឲ្យសត្វនោះពុំអាចនឹងសម្រេចប្រយោជន៍អ្វីជាប្រាកដបានឡើយ ។ ដោយហេតុនេះ បានជាឧទ្ធច្ចៈត្រូវបានចាត់ទុកជាចំណងទី ៩ ។

១០– អវិជ្ជា គឺសេចក្ដីល្ងង់ ។ ឯអវិជ្ជានេះ គឺសំដៅសេចក្ដីល្ងង់៤ ប្រការ គឺល្ងង់មិនដឹងច្បាស់នូវទុក្ខ ១, ល្ងង់មិនដឹងច្បាស់នូវហេតុនៃទុក្ខ ១, ល្ងង់មិនដឹងច្បាស់នូវកិរិយារលត់នៃទុក្ខ ១ នឹងល្ងង់មិនដឹង

ច្បាស់នូវបដិបទា ដែលអាចញុំាងកិរិយារលត់នៃទុក្ខ ឲ្យសម្រេចឡើងបាន១ ។ គឺសេចក្ដីល្ងង់ទាំង ៤ នេះហើយ ដែលជាហេតុនាំសត្វឲ្យវង្វេងខ្វល់គិតរកឧបាយ ដើម្បីដោះខ្លួនឲ្យរួចផុតពីកងទុក្ខពុំឃើញសោះឡើយ ។ ដោយហេតុនេះ ទើបអវិជ្ជាត្រូវបានចាត់ទុកជាចំណងទី ១០ ដោយប្រការដូច្នេះឯង ។

រីឯចំណង ១០ ប្រការនេះ មានចំណង ៣ ខាងដើម ទុកជាចំណងយ៉ាងមាំ ដែលអរិយបុគ្គលត្រូវព្យាយាមកាត់ផ្ដាច់ឲ្យអស់ជាមុន ទើបជាហេតុនាំឲ្យកាត់ផ្ដាច់នូវចំណង ៧ ទៀតបានដោយស្រួល គឺចំណង១០នេះហើយដែលនៅត្រៀមចាំ តែងចងត្បែងសត្វទុកឲ្យនៅវិលកើតវិលស្លាប់លើត្រៃភពជាប្រក្រតីមិនឲ្យសត្វដោះខ្លួនរួច ដើម្បីនឹងធ្វើដំណើរឆ្លងចេញចាកត្រៃលោកបានឡើយ ។

ដោយហេតុនេះ ទើបសំយោជនៈ១០ ត្រូវចាត់ទុកជាបុព្វហេតុទី ២ ដែលរាំងដំខាស់មិនឲ្យលោកុត្តរចិត្តអាចសម្រេចកើតឡើងបាន ដោយប្រការដូច្នេះឯង ។

## ៤- តណ្ហា ៣ ប្រការ

ម្យ៉ាងទៀតបើពិនិត្យនូវលក្ខណៈនៃសំយោជនៈ១០ នេះឲ្យបានល្អិតទៅទៀត គេអាចដឹងបានថា គឺសំយោជនៈ១០ នេះហើយដែលទុកជាបច្ច័យតាក់តែងនូវតណ្ហា ៣ ប្រការគឺ កាមតណ្ហា១, ភវតណ្ហា១,

នឹងវិភវតណ្ហា ១ ឲ្យមានដំណើរប្រព្រឹត្តទៅក្នុងខន្ធសន្តានជាប្រក្រតីនោះ ។

មែនពិតគឺ សំយោជនៈ ៥ ខាងដើមដែលជា ឱរម្ភាគិយ-សំយោជនៈ ត្រូវចាត់ទុកជាបច្ច័យតាក់តែងនូវកាមតណ្ហា ឲ្យមានដំណើរប្រព្រឹត្តទៅបានជាធម្មតា, ហើយសំយោជនៈ ៥ ខាងចុងដែលជា ឧទ្ធម្ភាគិយសំយោជនៈ ត្រូវចាត់ទុកជាបច្ច័យតាក់តែងនូវភវ-តណ្ហានឹងវិភវតណ្ហា ឲ្យមានដំណើរប្រព្រឹត្តទៅបានជាប្រក្រតីនោះ ។ គឺតណ្ហា ៣ ប្រការនេះហើយ ដែលជាមេដាំងនៅត្រៀមចាំតែស្ថាបនានូវខន្ធ ៥ ឲ្យកើតមានក្នុងភពថ្មីទៀតជានិរន្តរ៍នោះ ។

ម្យ៉ាងទៀត កាមតណ្ហា, ភវតណ្ហា, នឹងវិភវតណ្ហានោះ បណ្ឌិតលោកចាត់ទុកជាអន្ទាក់កាម ៣ សម្រាប់ចាំតែទាក់សត្វទុក មិនឲ្យសត្វអាចធ្វើដំណើរឆ្លងចេញរួចផុតចាកត្រៃលោកបានសោះឡើយ ។

ដោយហេតុនេះ ទើបតណ្ហា ៣ ប្រការត្រូវចាត់ទុកជាបុព្វហេតុទីញ ដែលកាំងដំពាសមិនឲ្យលោកុត្តរចិត្តអាចសម្រេចកើតឡើងបាន ដោយប្រការដូច្នេះឯង ។

(នៅមានត)

ព្រះអភិធម្មបិដក

# គម្ពីរព្រះយមកៈ

លោក ប៊ូ - ប៊ុ ប្រែរៀបរៀង

( តមក )

កាលសុរុចិព្រាហ្មណ៍ កំពុងតែដើរបណ្តើរគិតបណ្តើរដូច្នេះ អាការដំក្តៅ ក៏កើតមានដល់បណ្ឌុកម្ពលសិលាសន៍ នៃសម្តេចអមរិន្ទ្រទេវរាជ ។ ទ្រង់អាវជ្ជនាការពិចារណាមើល ក៏ជ្រាបរឿងនោះច្បាស់ ក្នុងព្រះហឫទ័យ ទើបចុះចាកតាវត្តិង្សមកកាន់មនុស្សលោក ហើយនិម្មិតជានាយជាងឈើមកឈរនៅចំពោះមុខសុរុចិព្រាហ្មណ៍ ហើយមានទេវបញ្ជាត្រាស់សួរព្រាហ្មណ៍ថា បុគ្គលណាត្រូវការរកជួលជាងឈើដែរឬទេ ? ។ សុរុចិព្រាហ្មណ៍ឮពាក្យនោះត្រេកអរណាស់ ឆ្លើយយ៉ាងរហ័សថា ខ្ញុំបាននិមន្តសម្តេចព្រះពុទ្ធអង្គព្រមទាំងព្រះភិក្ខុសង្ឃជាបរិវារ និងឲ្យមកទទួលអាហារបិណ្ឌបាតទាននៅគេហស្ថានរបស់ខ្ញុំ ប៉ុន្តែ ខ្ញុំគ្មានមណ្ឌបនិងអាសនៈប្រគេនលោកម្ចាស់ទាំងអស់នោះគង់ទេ អ្នកចូរសង្គ្រោះដល់ខ្ញុំជួយធ្វើមណ្ឌបឲ្យទាន់នៅពេលព្រឹកស្អែកនេះ ។ សម្តេចព្រះពិស្ណុការ ក៏ទទួលពាក្យធ្វើជាមណ្ឌបដោយទេវឫទ្ធិ ធ្វើពុទ្ធាសនៈជាទីគង់នៃព្រះពុទ្ធអង្គ និងអាសនៈដែលព្រះភិក្ខុសង្ឃ និងគង់ធ្វើភត្តកិច្ច ។ ព្រះឥន្ទ្រនិម្មិតស្រេចហើយ ក៏ត្រឡប់ទៅទេវលោកវិញ ។

លុះព្រឹកព្រាងស្វាងព្រះសុរិយាឡើងហើយ សម្តេចព្រះពុទ្ធអង្គនាំព្រះភិក្ខុសង្ឃមកទទួលបិណ្ឌបាតទាន សុរុចិព្រាហ្មណ៍ថ្វាយចង្ហាន់បិណ្ឌ-បាតចំពោះសម្តេចព្រះពុទ្ធអង្គព្រមទាំងព្រះភិក្ខុសង្ឃជាបរិវារ ។ លុះព្រះពុទ្ធអង្គព្រមទាំងព្រះភិក្ខុសង្ឃធ្វើភត្តកិច្ចស្រេចហើយ ក៏និវត្តនាការវិលទៅព្រះវិហារវិញ ។

សុរុចិព្រាហ្មណ៍បានបំពេញពាហិរកទាន គឺឲ្យរបស់ក្រៅរូបកាយខ្លួនទៅជាទានយ៉ាងច្រើនដល់ម្ល៉ោះហើយ ក៏នៅតែមិនទាន់ស្កប់ចិត្តគិតចង់ឲ្យអជ្ឈត្តិកទាន គឺឲ្យអវយវៈក្នុងកាយខ្លួនទៅជាទានទៀត ក៏ក្តៅទៅដល់អាសនៈព្រះឥន្ទ្រ ទ្រង់ជ្រាបហេតុនោះហើយ ស្តេចចុះពីត្រៃ-វត្តិង្សពិភពនិម្មិតភេទជាព្រាហ្មណ៍ចូលទៅសូមភ្នែករបស់សុរុចិព្រាហ្មណ៍ៗគ្មានចិត្តតក់ស្លុតញាប់ញ័រសោះ ត្រេកអរណាស់ ក៏ឆ្កៀលភ្នែកទាំងពីរខាងដាក់ទានដោយសទ្ធាជ្រះថ្លា ។ ព្រះឥន្ទ្រទទួលយកភ្នែកមកហើយក៏បណ្តាលឲ្យភ្នែកទាំងគូ នៃសុរុចិព្រាហ្មណ៍ត្រឡប់កើតមានជាប្រក្រតីដូចដើមវិញ ដោយទេវឫទ្ធិ រួចហើយយាងត្រឡប់ទៅកាន់ទេវលោកវិញ ។

ការដែលសុរុចិព្រាហ្មណ៍បានបំពេញទាន នឹងធ្វើការជាកុសលទាំងអស់នោះឈ្មោះថា ការកុសលបង្កើតអំពីចក្ខុទ្វារ ព្រោះថាបានឃើញព្រះស្មៅនៃព្រះសុមង្គលសាស្តាចារ្យ ហើយទើបបានកើតសទ្ធាជ្រះថ្លាធ្វើការកុសល ។

ចំណែកការស្ដាប់វិញ សម្រេចដោយការបានឮបានស្ដាប់សម្លេងអ្វីៗ ហើយកើតសទ្ធាជ្រះថ្លាប្រាថ្នានឹងធ្វើការជាកុសល ក៏បានឈ្មោះថា កុសលបង្កើតអំពីសោតទ្វារ ។

បើបានធុំក្លិនអ្វីៗហើយ គិតប្រុងនឹងធ្វើការជាកុសល ក៏បានឈ្មោះថា កុសលបង្កើតអំពីឃានទ្វារ ។

បើបានលិទ្ធភ្លក្សរសអ្វីៗ ហើយគិតចង់ធ្វើការកុសល ក៏បានឈ្មោះថា កុសលបង្កើតអំពីជិវ្ហាទ្វារ ។

បើបានពាល់ត្រូវនូវគ្រឿងសម្ផស្សដោយកាយហើយ កើតចិត្តសទ្ធាជ្រះថ្លាកងការកុសល ក៏បានឈ្មោះថា កុសលបង្កើតអំពីកាយទ្វារ ។

បើត្រិះរិះគិតហេតុទាំងឡាយដែលជាកុសលហើយប្រុងនឹងធ្វើកុសលនោះ ក៏បានឈ្មោះថា កុសលបង្កើតអំពីមនោទ្វារ

អ្នកប្រាជ្ញគប្បីសន្និដ្ឋានចូលចិត្តចុះថា ការជាកុសលនឹងការជាអកុសលទាំងពីរប្រការនេះ ក៏បង្កើតអំពីទ្វារឬអាយតនៈទាំង ១២ ដោយន័យដែលបានរៀបរាប់មកហើយខាងដើមនោះ គ្រាន់តែការជាអកុសលផ្ទុយនឹងការជាកុសលប៉ុណ្ណោះ ឯរបៀបបង្កើតអំពីទ្វារ ឬអាយតនៈទាំង ១២ ប្រការដូចគ្នា ទោះជាកុសលក្ដី ជាអកុសលក្ដី ។

អាយតនយមកៈ ចប់ ។

X
X X

# ធាតុយមកៈ

អដ្ឋារសធាតុយោ ចក្ខុធាតុ សោតធាតុ ឃានធាតុ ជិវ្ហាធាតុ កាយធាតុ មនោធាតុ រូបធាតុ សទ្ទធាតុ គន្ធធាតុ រសធាតុ ផោដ្ឋព្វធាតុ ធម្មធាតុ ចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាវិញ្ញាណធាតុ កាយវិញ្ញាណធាតុ មនោវិញ្ញាណធាតុ ។

*លំដាប់អំពីអាយតនយមកៈ សម្ដេចព្រះបរមសាស្ដា ទ្រង់ត្រាស់ទេសនាធាតុយមកៈតទៅទៀត មានសេចក្ដីថា ទេវាតិទេវោ ព្រះមានព្រះភាគជាវិសុទ្ធិទេវតាក្នុងបង់នូវទេវតាទាំងឡាយ គឺសម្មតិទេវតានឹងឧបបត្តិទេវតា កាលព្រះអង្គត្រាស់ទេសនានូវអាយតនយមកៈចប់ចុះហើយ ទើបទ្រង់ត្រាស់ទេសនានូវធាតុយមកៈតទៅទៀត ។ ធាតុយមកៈនោះ ទ្រង់ត្រាស់សំដែងនូវធាតុទាំង ១៨ ប្រការ ។*

*ឯធាតុទាំង ១៨ ប្រការនោះគឺ ចក្ខុធាតុ ១ សោតធាតុ ១ ឃានធាតុ ១ ជិវ្ហាធាតុ ១ កាយធាតុ ១ មនោធាតុ ១ រូបធាតុ ១ សទ្ទធាតុ ១ គន្ធធាតុ ១ រសធាតុ ១ ផោដ្ឋព្វធាតុ ១ ធម្មធាតុ ១ ចក្ខុវិញ្ញាណធាតុ ១ សោតវិញ្ញាណធាតុ ១ ឃានវិញ្ញាណធាតុ ១ ជិវ្ហាវិញ្ញាណធាតុ ១ កាយវិញ្ញាណធាតុ ១ មនោវិញ្ញាណធាតុ ១ គ្រប់ជាធាតុ ១៨ ប្រការ ។*

ព្រះពុទ្ធអង្គទ្រង់ត្រាស់ទេសនាធាតុយមកៈនោះ ក៏ទ្រង់ត្រាស់បុច្ឆាជាគូៗ ត្រាស់វិសជ្ជនាជាគូៗ ទ្រង់ត្រាស់បុច្ឆាថា ចក្ខុនោះឬ ឈ្មោះថាចក្ខុធាតុ ? ចក្ខុធាតុនោះឬ ឈ្មោះថា ចក្ខុ ?

ទ្រង់ត្រាស់វិសជ្ជនាថា អាមន្តា អើ! ចក្ខុនោះឈ្មោះថា ចក្ខុធាតុ នោះឯងហើយឈ្មោះថា ចក្ខុ ៗ

អ្នកប្រាជ្ញគប្បីសន្និដ្ឋានចូលចិត្តថា ព្រះពុទ្ធអង្គទ្រង់ត្រាស់បុច្ឆានិងវិសជ្ជនាក្នុងចក្ខុធាតុដូចម្ដេច ក៏ទ្រង់ត្រាស់បុច្ឆានិងវិសជ្ជនាក្នុងធាតុទាំង-ឡាយមានសោតធាតុជាដើម មានធម្មធាតុជាបរិយោសាន ដូចោះដែរ ៗ

ចក្ខុធាតុនោះ បានដល់ចក្ខុ មានសេចក្ដីដូចគ្នានឹងចក្ខុរបស់ខ្លួន តែផ្សេងអំពីអាយតនៈ ព្រោះអាយតនៈប្រែថា ជាទីកើត ឯធាតុប្រែថា ជាទីទ្រទ្រង់ទុក ៗ

សម្ដេចព្រះមានព្រះភាគទ្រង់ត្រាស់ទេសនាក្នុងធាតុទាំង ១៨ ប្រការនោះ ដោយអំណាចមានព្រះពុទ្ធបំណងនឹងឲ្យព្រះយោគាវចរកុលបុត្រពិចារណានូវធាតុទាំងពួងនោះ ឲ្យឃើញថាជារបស់សូន្យ ជារបស់ទទេ, ជារបស់ល្បងលួងលោមមនុស្សសត្វ ឲ្យលិចលង់វង្វេងនៅក្នុងវដ្ដសង្សារមិនឲ្យគេចរួចពីវដ្ដទុក្ខនានា គឺជាតិ ជរា ព្យាធិនិងមរណៈទៅបាន ៗ

ប៉ុន្តែ បុគ្គលដែលអាចនឹងពិចារណាឲ្យឃើញថា ធាតុទាំងអស់នោះជារបស់សូន្យ, ជារបស់ទទេ ត្រូវអាស្រ័យមានសតិ និងសម្បជញ្ញៈ ៗ

កន្ទីនេះ លើកសតិទុកដោយឡែកមិនអធិប្បាយទេ សូមអធិប្បាយតែសម្បជញ្ញៈមួយចំណែកប៉ុណ្ណោះ ។ តាមពិត សតិជាគូនឹងសម្បជញ្ញៈ ។ សតិគឺស្មារតី តែងកើតមុនសម្បជញ្ញៈជាដរាប បើគ្មានសតិគឺស្មារតីទេ សម្បជញ្ញៈក៏គ្មានដែរ ។ បើមានសតិគឺស្មារតីហើយ ទើបមានសម្បជញ្ញៈ ។ ហេតុនេះ សូមជ្រាបដោយន័យខ្លីថា បើមានសម្បជញ្ញៈវេលាណា វេលានោះឈ្មោះថា មានសតិ គឺស្មារតីជាមុនរួចមកហើយ ។

## អធិប្បាយអំពីសម្បជញ្ញៈ

ចតុត្ថំ បទំ សម្បជញ្ញំ ។ សម្បជញ្ញៈ ប្រែថា សេចក្ដីដឹងខ្លួន ។ សម្បជញ្ញៈមានលក្ខណៈឲ្យដឹងខ្លួនចាំក្នុងវេលាកំពុងធ្វើ, កំពុងនិយាយ, កំពុងគិត តម្រែតម្រង់អំពើ, សំដីនឹងគំនិតនោះឲ្យបានល្អត្រឹមត្រូវតាមផ្លូវដែលសតិរឭកឃើញរួចមកហើយនោះដរាបទៅ ។ សម្បជញ្ញៈមានកិច្ចឲ្យកំចាត់បង់នូវសេចក្ដីខ្លាច នឹងគំនិតល្ងង់ខ្លៅក្នុងវេលាធ្វើការងារជាដើម ។ សម្បជញ្ញៈ មានផលដោយធ្វើឲ្យអំពើ, សំដី នឹងគំនិតត្រឹមត្រូវល្អ ឥតខុស មិនអាក្រក់ ។

(នៅមានត)

## មង្គលសភាហ៍ណី

## សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ.ឈឺន ពិនិត្យ

(តមក)

---

តស្មា សោ ទារុណោ យក្ខោ ទិស្វា តំ សរណេ ឋិតំ

ទុព្ភិតោ ភយប្បត្តោ លោមហដ្ឋោ ឆម្ភិតោ ។

ព្រោះហេតុដូច្នោះ យក្សកាចអាក្រក់នោះ បានឃើញទាសកដែលឋិតនៅក្នុងពុទ្ធសរណៈ ក៏ភ្ញាក់ភ័ន្តភាំង ដល់នូវភ័យតក់ស្លុត ព្រឺព្រួចរោម មានកាយញាប់ញ័ររន្ធត់ពិត ៗ

ភមន្តោ ឆារិតំ ទិស្វា តិរោវ សុរិយុគ្គតា
សម្ពូលិតុលកប្ពុវ មណ្ឌាភតេន ហារិតំ ។

លុះយក្សបានឃើញបុរសអ្នកជនបទពោលថា ពុទ្ធំ ជាដើមហើយ ក៏ស្លុតវិលត្រឡប់ខ្លួនស្ទុះរត់ទៅខាងក្រៅ ដូចជាព្រះអាទិត្យរះឡើងហើយ កំចាត់ងងឹតចេញទៅខាងក្រៅដូច្នោះផង ដូចជាប៉ុយកា ឬ ប៉ុយគរវិល អណ្តែតឡើងដោយខ្យល់នាំកួចបន្សាត់ទៅដូច្នោះឯង ៗ

យំ ទុក្ខំ ភជតោភិ យក្ខាបេតាទិសម្ភវំ
និច្ចន្តេន មនុស្សេន គន្តុំ សរណាត្តយំ ។

សេចក្តីទុក្ខណាដែលកើតអំពីមនុស្ស មានស្តេចនឹងចោរជាដើមក្តី

ទុក្ខដែលកើតអំពីអមនុស្សមានយក្សជាដើមក្តី ជនមានសន្តានខ្ពស់ អ្នកមិនប្រាជ្ញានូវសេចក្តីទុក្ខទាំងអំបាលនោះ ត្រូវតែយកព្រះរតនត្រ័យទាំងបី គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងដោយពិត ។

យោ ច ពុទ្ធញ្ច ធម្មញ្ច សំឃញ្ច សរណង្គតោ
សោ តំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ
ចត្តារិ អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ ។

បុគ្គលណាមួយបានដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរលឹកហើយ, បុគ្គលនោះនឹងរួចចាកទុក្ខទាំងពួង នឹងបានត្រាស់ដឹង នូវព្រះអរិយសច្ចទាំងបួនដោយប្រាជ្ញាដ៏ឧត្តម ព្រោះអាស្រ័យនូវអានិសង្សនៃត្រៃសរណគមន៍នោះឯង ។

លំដាប់នោះ បុរសអ្នកជនបទក៏បានដឹងជាក់ច្បាស់ដោយខ្លួនឯងនូវគុណនឹងអានិសង្សព្រះត្រៃសរណគមន៍ដ៏ប្រសើរ ទាំងបានដល់នូវអាបាណកោដិសរណគមន៍ គឺដល់នូវព្រះពុទ្ធជាទីពឹង មានជីវិតជាទីបំផុត ដូច្នេះថា ខ្ញុំព្រះអង្គសូមគោរពក្នុងព្រះពុទ្ធជាម្ចាស់ សូមដល់នូវព្រះពុទ្ធជាទីពឹងមានជីវិតជាទីបំផុត ។ បុរសនោះក៏បានដល់នូវព្រះពុទ្ធជាទីពឹងដូចបានពណ៌នាហើយ, ដោយអំណាចផលានិសង្សនោះ លុះធ្វើមរណកាលក្ស័ណក្ស័យជីវិត ក៏បានអន្ទោលទៅកើតក្នុងឋានទេវលោក ក្នុងមួយរំពេចបីដូចជាបុរសភ្ញាក់អំពីដេកលក់ បានសោយសម្បត្តិទិព្វទាំង ១០

ប្រការជាអស្ចារ្យក្រៃលែង ព្រោះហេតុដូច្នោះ ព្រះគន្ថរចនាចារ្យលោក ពោលជាបទព្រះគាថាជូនទៀតថា:

និស្សាន ឃរំ សរណំ គច្ឆន្តិ
អបេន្តិ យក្ខាបិ មហព្ភយេន
ចាគេថ សីលំ សរណញ្ច តស្មា
ជហាថ ទុក្ខំ សុគតឹ គមិស្ស ។

អធិប្បាយថា ចំណែកឯយក្សនា១ ដែលមានស័ក្តិធំ លុះបានឃើញឧបាសក ដែលបានដល់នូវព្រះសរណគមន៍ជាអស្ចារ្យយ៉ាងនេះហើយ ក៏មានសេចក្តីភិតភ័យខ្លាំងរត់ចៀសចេញទៅនាគ្រានោះឯង ។

ព្រោះហេតុដូច្នោះ អ្នកជាសប្បុរសទាំងឡាយ ត្រូវតែរក្សាសីលនឹងសរណគមន៍ឲ្យខ្ជាប់ខ្ជួន ត្រូវលះបង់នូវសេចក្តីទុក្ខ ហើយសេពគប់នូវសុគតិភពវិញហោង ។

សម្តែងរឿងនិទាន មនុស្សបញ្ឆោតយក្សជាបឋមកង់វគ្គទីបី ក៏ចប់ដោយសង្ខេបតែប៉ុណ្ណេះឯង ។

x
x x

២- មិច្ឆាទិដ្ឋិវត្ថុកថា

សម្តែងរឿងនិទាន ពីកុមារជាបុត្រនៃជនជាអ្នកមិច្ឆាទិដ្ឋិ តទៅទៀតដោយវារៈបាលីថា ភគវតិ បរិនិព្វុតេ ដូច្នេះជាដើម អធិប្បាយថា

កាលព្រះមានព្រះភាគទ្រង់ចូលបរិនិព្វានទៅហើយ បានឮមកថា មានព្រាហ្មណ៍ម្នាក់ជាមិច្ឆាទិដ្ឋិ នៅអាស្រ័យក្នុងនគររាជគ្រឹះ ហើយមានព្រាហ្មណ៍ម្នាក់ទៀតជាសម្មាទិដ្ឋិ នៅអាស្រ័យក្នុងនគរនោះដែរ ។

ព្រាហ្មណ៍ទាំងពីរនាក់នោះសោត មានបុត្តប្រុសមួយ ៗ ម្នាក់ ៗ ឯកុមារទាំងពីរនាក់នោះ តែងលេងអង្គញ់កាល់គ្នាក្នុងទីជាមួយគ្នា ពុំដែលដាច់ ។

លុះចំណេរកាលមកជាខាងក្រោយ បណ្ដាកុមារទាំងពីរនាក់នោះ មុនកាលលេងអង្គញ់កាល់គ្នា កុមារជាបុត្តនៃព្រាហ្មណ៍អ្នកសម្មាទិដ្ឋិ មុននឹងបោះអង្គញ់ទៅក៏ពោលថា ឯ មោ ពុទ្ធស្ស ហើយបោះអង្គញ់ទៅ តែងបានឈ្នះកុមារជាសំឡាញ់នោះសព្វថ្ងៃជាដរាប ។

ឯកុមារជាបុត្តនៃព្រាហ្មណ៍អ្នកមិច្ឆាទិដ្ឋិ កាលដែលនឹងបោះអង្គញ់ទៅក៏ពោលថា ឯ មោ ព្រាហ្មណោ ហើយបោះអង្គញ់ទៅ តែងតែចាញ់កុមារជាបុត្តនៃព្រាហ្មណ៍អ្នកសម្មាទិដ្ឋិសព្វ ១ ថ្ងៃ ។ លុះថ្ងៃមួយជាខាងក្រោយ កុមារជាបុត្តនៃព្រាហ្មណ៍អ្នកមិច្ឆាទិដ្ឋិ បានឃើញកុមារជាបុត្តនៃព្រាហ្មណ៍អ្នកសម្មាទិដ្ឋិ ចេះតែបានឈ្នះខ្លួនជានិច្ចដូច្នោះហើយ ក៏សួរថា ម្នាលសំឡាញ់មានធុរៈស្មើ! សំឡាញ់អ្នកតែងបានឈ្នះខ្ញុំជានិច្ច ចុះមុននឹងបោះអង្គញ់ទៅ តើអ្នកពោលនូវពាក្យថាដូចម្ដេចខ្លះ? ។

ឯកុមារជាបុត្តព្រាហ្មណ៍ អ្នកសម្មាទិដ្ឋិបានស្ដាប់ហើយ ក៏ឆ្លើយ

ប្រាប់ថា ម្នាលសំឡាញ់! ខ្ញុំពោលថា ឯមោ ពុទ្ធស្ស ហើយទើបបោះអន្ទាក់ទៅ បានជាខ្ញុំឈ្នះអ្នកឯងជានិច្ច ។

ឯមិច្ឆាទិដ្ឋិកបុត្ត តាំងដើមអំពីកាលនោះមកតែងពោលថា ឯមោ ពុទ្ធស្ស ហើយទើបបោះអន្ទាក់ទៅជានិច្ច ដូចសំឡាញ់របស់ខ្លួនដែរ ។

កាលដែលកុមារទាំងពីរនាក់នោះ បានពោលដូចគ្នាថា: ឯមោ ពុទ្ធស្ស ដូច្នេះហើយ ទើបបោះអន្ទាក់ទៅក៏បានឈ្នះនឹងចាញ់ស្មើ ៗ គ្នា ពុំលើសពុំខ្វះគ្នាឡើយ ។ លុះដល់កាលជាខាងក្រោយទៀត សម្មាទិដ្ឋិកបុត្ត បានចេញទៅរកកាប់ឧសជាមួយនឹងបិតារបស់ខ្លួន ហើយបានដឹករទេះឧសត្រឡប់មកវិញ ក៏ដាក់រទេះឈប់សម្រាកក្នុងទីជិតក្រុង ហើយលែងគោឲ្យចេញទៅរកស៊ីស្មៅបរិភោគក្នុងកាលនោះឯង ។

ចំណែកឯគោនៃនាយរទេះនោះ វាដើរស្វែងរកស៊ីស្មៅរៀង ៗ ទៅក៏បានចូលទៅខាងក្នុងទីក្រុងជាមួយនឹងហ្វូងគោទាំងឡាយដទៃទៅ ។

កាលនោះបិតារបស់កុមារ ក៏ដើរស្វែងរកគោពុំទាន់បានឃើញ ទើបនិយាយទៅនឹងបុត្តថា ម្នាលបា! ឯងត្រូវត្រឡប់ទៅមើលរទេះវិញចុះ លុះនិយាយហើយក៏ដើរតាមរកគោ ដែលចូលទៅក្នុងទីក្រុងកាលនោះឯង ។

ពេលនោះ ជាវេលាសាយណ្ហសម័យថ្ងៃល្ងាចជិតយប់ មនុស្សទាំងឡាយ ដែលរក្សាទ្វារក្រុងក៏គេបញ្ចូលគ្នាចាក់សោបិទទ្វារក្នុងវេលានោះដែរ

ឯបុរសជាបិតាពុំអាចនឹងចេញមកបានទៀយ ។

លំដាប់នោះ កុមារនៅចាំរេចះនេះចាំមើលផ្លូវបិតាក៏ពុំបានឃើញបិតាត្រឡប់មកសោះទៀយ ហើយក៏ដេកតែម្នាក់ឯងខាងក្រោមរេចះទសលទ់លក់ទៅ ឮដ៏ខាងក្រៅទ័ក្រុងនោះហោង ។

កងកក្រោយប់នោះមានយក្សពីរនាក់ យក្សម្នាក់ជាមិច្ឆាទិដ្ឋិ យក្សម្នាក់ជាសម្មាទិដ្ឋិ យក្សទាំងពីរនាក់នោះជាសំឡាញ់នឹងគ្នា ហើយបណ្តើរគ្នាចេញទៅស្វែងរកចំណីអាហារនឹងបរិភោគ ក៏បានឃើញកុមារតូចម្នាក់ដេកនៅខាងក្រោមរេចះនោះ ។ បណ្តាយក្សទាំងពីរនាក់នោះ ឯយក្សជាមិច្ឆាទិដ្ឋិក៏និយាយថា អញនឹងចាប់កុមារតូចនេះទំពាស៊ីឥឡូវនេះឯង ។ ចំណែកយក្សជាសម្មាទិដ្ឋិក្រៅនេះបានស្តាប់ហើយ ក៏ហាមឃាត់ថា: អ្នកឯងមិនត្រូវធ្វើយ៉ាងនេះទេ ដ្បិតកុមារនេះតែងពោលថា ឯមោ ពុទ្ធស្ស ពុំដែលដាច់ទៀយ ។ ឯយក្សជាមិច្ឆាទិដ្ឋិពុំបានស្តាប់ ក៏ពោលតបវិញថា អញនឹងចាប់កុមារនេះទំពាស៊ីដោយពិត, កាលបើយក្សជាសម្មាទិដ្ឋិនេះឃាត់ពីរដងបីដង ក៏ពុំបានស្តាប់ទៀយ ហើយស្ទុះទៅចាប់ជើងកុមារនោះទាញគន្ទ្រាក់មកដើម្បីនឹងសំឡាប់ ហើយទំពាស៊ីជាអាហារ ខណៈនោះកុមារក្រោកឡើងពោលថា: ឯមោ ពុទ្ធស្ស ៗ ញាប់មាត់ដោយបុព្វចរិតដែលខ្លួនធ្លាប់សន្សំទុកមកអស់កាលជាយូរហើយ ។

ឯយក្សជាមិច្ឆាទិដ្ឋិលុះបានស្តាប់ពាក្យកុមារនោះពោលថា ឧមោ ពុទ្ធស្ស ៗ ដូច្នេះហើយ ក៏ដល់នូវសេចក្តីតក់ស្លុតភិតភ័យញ័ររន្ធត់ ព្រឺព្រួចរោមាលែងដៃជាប្រញាប់ហើយថយក្រោយមកឈរក្នុងទីឆ្ងាយ ៗ (មានពាក្យគាំទ្រគួរកោតស្ញប់ស្ញែងថា) ឱហ្ន៎! យើងទាំងឡាយគួរឃើញនូវអានុភាព នៃពុទ្ធគុណជាទីអស្ចារ្យពេកណាស់ កុមារតូចពុំបានថ្វាយខ្លួនឲ្យជាទីពឹងទេ គ្រាន់តែពោលថា ឧមោ ពុទ្ធស្ស កិរិយានមស្សការចំពោះព្រះពុទ្ធ តែប៉ុណ្ណោះ ដោយចរិតដែលខ្លួនធ្លាប់សន្សំទុកមក ក៏គង់មានផលានិសង្សដ៏វិសេសពន់ពេក ភ័យតក់ស្លុតនិងសេចក្តីចង្រៃឧបទ្រពទាំងពួង ពុំបានកើតមានដល់កុមារនោះឡើយ, ចាំបាច់និយាយថ្វីដល់បុគ្គលដែលបានថ្វាយខ្លួនដល់ព្រះសម្មាសម្ពុទ្ធ ជាទីពឹងទីរលឹកស្មើដោយជីវិតនោះនឹងរឹងរឹតតែមានផលានិសង្ស រាប់ពុំបានស្មានពុំអស់ឡើយ, ព្រោះហេតុដូច្នោះ បានជាព្រះអរហន្តទាំងឡាយ លោកពោលជាបទព្រះគាថាដូច្នេះថា:

យថាបិ សិខិនោ នាទំ ភុជគានំ ភយាវហំ

ឯវំ ពុទ្ធោតិវចនំ អមនុស្សានំ ភយាវហំ ។

អធិប្បាយថា កិរិយាបន្លាក់ដុតបំពក់នូវគំនរភ្លើងឲ្យឆេះឡើងខ្លាំង ជាទីនាំមកនូវភ័យនិងសេចក្តីតក់ស្លុតខ្លាំងដល់ពស់ទាំងឡាយ មានឧបមាយ៉ាងណា, ពាក្យដែលបុគ្គលពោលថា ពុទ្ធោ ៗ នេះ ជាពាក្យដ៏ឧត្តម

នាំមកនូវភ័យទីផងសេចក្ដីតក់ស្លុត ដល់អមនុស្សទាំងឡាយមានយក្សជាដើម ក៏មានឧបមេយ្យយ៉ាងនោះឯង ។

យថា មន្តស្ស ជប្បេន វិលយំ យាតិ តិព្វិសំ
ឯវំ ពុទ្ធានុភាវេន ភាយន្តិ កុណខាទកា ។

ពិសពស់ដ៏ក្លៀវក្លា ភពដល់នូវការរលាយសូន្យទៅ ដោយកិរិយាស្វាធ្យាយទកយមន្តដ៏វិសេស មានឧបមាយ៉ាងណា , យក្សទាំងឡាយដែលទំពាស៊ីនូវសាកសពរមែងតក់តក់ភ័យតែទៅដោយពុទ្ធានុភាព ក៏មានឧបមេយ្យយ៉ាងនោះឯង ។

អគ្គិបត្តា យថា សិតំ ទុរតោ លិយតិ
បត្វា ឯវំ សរណគតំ បេតា បេន្តិ ទូរតោ ។

ដូចត្រជាក់ដែល លុះបានត្រូវកំដៅហើយ រមែងរលាយបាត់សូន្យទៅអំពីចម្ងាយ មានឧបមាយ៉ាងណា, ប្រេតទាំងឡាយ បើបានដល់នូវទីសំណាក់អាស្រ័យរបស់បុគ្គលអ្នកដល់នូវពុទ្ធរតនៈជាទីពឹងហើយ តែងតក់ស្លុតភ័យខ្លាចចៀសចេញទៅកាន់ទីឆ្ងាយដោយពិត ក៏មានឧបមេយ្យយ៉ាងនោះឯង ។

(នៅមានត)

# មហោសថជាតក

លោក អ៊ឹម-គង ចម្លងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស គឹម-ទួរ ពិនិត្យ

(តមក)

---

ស្ដេចទ្រង់ព្រះចិន្ដាដូច្នោះហើយ ក៏ទ្រង់ព្រះកន្សែងថ្ងងព្រះទំនួញ ខ្ញួញពិលាបអាណិតអនាថពោធិសត្វហើយថា ម្ដេចឡើយ អញក៏យកពាក្យអាចារ្យទាំង ៤ ជាអ្នកកំឡៅអន្ធពាលស្រាលសេចក្ដីស្រដីកាច់ថា មហោសថក្បត់ ក៏ពុំពិចារណាទូវអាថ៌នោះឲ្យប្រាកដ ក៏យកព្រះខ័នឲ្យទៅវាទាំង ៤ សម្លាប់កូនកំសត់បងតាមចំណង់វាជាអ្នកខ្លៅ ទៅពាំនាំពាក្យអពមង្គលមកប្រាប់អញ ក៏អញនោគដោយវា ឱមហោសថបុត្រពុំងាអា-ពុកអើយ! អ្នកមានពាក្យនោះពីរោះ ឥតមានអ្នកឯណាមួយស្មើ រីអំពើអញធ្វើនេះពុំគួរសោះឡើយ, ឱព្រឹកថ្ងៃស្អែកហើយ សមអញមិនយល់មុខចៅមហោសថអ្នកប្រាជ្ញ ឡើងមកគាល់ហ្មៅនៅបំរើដោះសាសារពើទាំងពួងឡើយ, ស្ដេចខ្ញួញដូច្នោះហើយ ក៏បែកញើសពេញទាំងព្រះអង្គទ្រង់ព្រះពិលាបធ្ងន់ពន់ប្រមាណ ឥតមានហៅសុខក្នុងព្រះហឫទ័យដល់តិចឡើយ ៗ ឮដ៏កាលនោះ, នាងឧទុម្ពរវរល័ក្ខណ៍ ជាអយិអគ្គមហេ-សី ទើបនាងលីលាយាត្រាទៅកាន់ក្រឡាព្រះបន្ទំបរមសុខ នៃព្រះរាជស្វាមីដូចអំពីដើមប្រក្រតី, នាងយល់ស្ដេចពុំសប្បាយរោះរាយដូចសព្វដង

នាងគិតក្នុងព្រះទ័យថា ព្រះមហាក្សត្រអ្នកមានបើខ្ញាល់ ខឹងសម្បានឹងអ្នកឯណា ឬ ខ្ញាល់នឹងអញ ហើយនាងរំពឹងនូវកំហុសរបស់នាងខុសនោះពុំយល់ឡើយ, ទើបគិតថា សមបើមានហេតុអ្វីមួយមកដល់អម្ចាស់អញ ក៏គួរអញទូលដណ្ដឹងហោង ហើយនាងសូត្រនូវព្រះគាថានេះថា :

កឹ ត្វំ វិមនោសិ រាជសេដ្ឋ
ទិបទិន្ទ វចនំ សុណោមិ តេ តំ
កឹ ចិន្តយមានោ ទុម្មនោសិ
ន ហិ ទេវ អបរាធោ អត្ថិ មយ្ហន្តិ ៗ

ព្រះនាងទូលថា បពិត្រព្រះមហាក្សត្រប្រសើរអើយ ! អម្ចាស់មានព្រះហឫទ័យពុំសប្បាយព្រោះហេតុអ្វី ? ឬអម្ចាស់មានបើរំពឹងដញ្ជឹងគិតនូវគាថាម្ដេច ? ឬមួយអញខ្ញុំមានបើខុសឆ្គងឲ្យស្រៅហ្មងព្រះរាជហឫទ័យនៃអម្ចាស់ផាស់ព្រះនេត្រ ? ដ្បិតហេតុនោះហោង ព្រះអង្គពុំសុខក្នុងព្រះ-រាជហឫទ័យ, រីខ្ញុំបារម្ភពុំដឹងទោសខ្លួនជាមានសភាពដូច្នោះ, បពិត្រអម្ចាស់អើយ ! ខ្ញុំស្មានជាខ្លួនឥតទោសណាអម្ចាស់ ៗ

រីព្រះបាទវិទេហរាជ ស្ដេចស្ដាប់នាងទូលនូវប្រការអម្បាលនោះ ហើយ ស្ដេចសូត្រនូវព្រះគាថានេះថា :

បញ្ញា វិជ្ជា មហោសធោ
អាណត្តោ មេ វិជាយ ភូរិបញ្ញោ
តំ ចិន្តយមានោ ទុម្មេធោស្មិ
ន ហិ ទេវិ អបរាធោ អត្ថិ តុយ្ហន្តិ ។

ស្តេចថា ភទ្ទេ ម្នាលនាងឧទុម្ពរទេវី មេអើយ! រីកំហុសទោសនាងនោះឥតអន្តីមានឡើយ, នាងអើយ ! ដ្បិតអ្នកប្រាជ្ញទាំង ៤ ឡើងមកប្រាប់អញថា មហោសថអ្នកប្រាជ្ញគិតក្បត់ជាសត្រូវនឹងអញហើយ អញបង្គាប់អ្នកប្រាជ្ញទាំង ៤ ឲ្យសម្លាប់មហោសថបង់ទៀត, ហេតុនោះហោង អញថប់បារម្ភពុំសប្បាយក្នុងចិត្តដល់តិចឡើយ ។

នាងឧទុម្ពរទេវី ស្តាប់ព្រះបន្ទូលព្រះមហាក្សត្រដូច្នោះហើយ ក៏ទ្រង់ព្រះពិលាប មានព្រះហឫទ័យនោះទន្ទឹះផ្អូកផ្អះជាទុក្ខធំ ហាក់បីដូចភ្នំនឹងរលំលើ ហេតុដ្បិតនឹងប្រែប្រាសនិរាសព្រះមហាក្សត្រជាប្អូនទៅ ទៅសោះសូន្យអសារ ទើបនាងគិតថា អញនឹងលោមព្រះមហាក្សត្រឲ្យក្សាន្តព្រះរាជហឫទ័យផ្ទុំសិន ហើយអញនឹងប្រើរនាំពតិមានឲ្យទៅប្រាប់មហោសថប្អូនអញ នាកាលស្តេចផ្ទុំលក់នោះហោង ។ លំដាប់នោះ, នាងក្រាបទូលព្រះមហាក្សត្រថា បពិត្រមហារាជអើយ! បើមហោសថគិតក្បត់ដូច្នោះហើយ ព្រះអង្គឲ្យសម្លាប់នោះគួរ ដ្បិតព្រះអង្គអាសូរករុណាឲ្យយសសក្តាផាធំស្មើនឹងសេនាបតី, ហេតុអ្វីឥឡូវនេះកើតជាសត្រូវនឹងព្រះអង្គ? បើចិត្តពុំត្រង់នឹងព្រះបាទអម្ចាស់ដូច្នោះហើយ,

គប្បីព្រះអង្គឲ្យសម្លាប់ចោលបង់កុំស្តាយឡើយ ។ ស្តេចស្តាប់ពាក្យនាងទូលដូច្នោះហើយ រីទុក្ខពាំងសម្ហាយក៏រសាយបង់ទៅ, ព្រះអង្គផ្ទំលក់ជាសុខទៅហោង ។

កាលនោះ, នាងទុទុម្ពរទេវី ចូលទៅក្នុងលំនៅនាងហើយ ទើបនាងសរសេរសំបុត្រ, ឯក្នុងសេចក្តីសំបុត្រនោះថា " ឲ្យព្រាមព្រាប់មហោសថឲ្យបានដឹង ដ្បិតអាចារ្យទាំង ៤ ពាំនាំពាក្យមកក្រាបទូលព្រះមហាក្សត្រថា បាឯងគិតក្បត់ ស្តេចខ្ញាល់ទើបបង្គាប់ប្រើអាចារ្យទាំង ៤ ឲ្យមកឃ្វាំចាំនៅល្វែកមាត់ទ្វារ ថាបើបាចេញមកនាព្រឹកស្អែក គេនឹងសម្លាប់បាពុំខាន, ហេតុនេះ កុំបីបាឡើងមកគាល់ស្តេចឡើយ, ពោះយោបីបានឹងឡើងមក ក៏ចូរបាធ្វើឲ្យអស់អ្នកនគរខ្លាចអំណាចបាហើយលុះទូវកណ្តាប់ដៃបា ហើយសឹមបាឡើងមកហោង " ។ នាងសរសេរសំបុត្រនោះស្រេចហើយ នាងដាក់សំបុត្រនោះក្នុងទំ យកអំបោះរុំគ្របនូវភាជន៍ថ្មី បិទខ្ជាប់ហើយនៃ នាងឲ្យទៅដៃខ្ញុំស្រីតែងបំរើ ហើយនាងផ្តាំថា ចូរហែងនាំនូវបាយនេះ ទៅជូនចៅមហោសថជាប្អូនអញហោង ។ រីមេនោះ ក៏ធ្វើដូចនាងទេវីប្រើនោះហោង, រីពាក្យចំណាំថា នាកត្រើយព្រលប់នោះ ធ្វើម្តេចក៏ខ្ញុំស្រីនោះនឹងចេញបាន ហេតុដ្បិតតែត្រាស្តេចឲ្យនាងទេវីអំពីដើមហើយ ដ្បិតហេតុនោះហោង រីអ្នកឯណាមួយក៏ពុំហានឃាត់ឡើយ ។

វរពោធិសត្វអ្នកទទួលបាយដំនូខពីមេនោះហើយ អ្នកឲ្យជំណើរមេនោះវិលទៅហោង, មេនោះវិលមកទូលនូវប្រការនាងជូនរួចហើយ ។ ក្បៀណនោះ នាងឧទុម្ពរទេវី នាងមកជុំមួយអន្ទើនូវព្រះបាទវិទេហរាជវិញហោង ។ វរពោធិសត្វអ្នកស្រាយទំលាយបាយនោះចេញហើយ អ្នកយល់នូវសំបុត្រនោះ អ្នកក៏ដឹងអាថ៌សេចក្តីពីនាងឧទុម្ពរនោះហើយ អ្នកពិចារណាប្រការកិច្ចគប្បីធ្វើហើយផ្ញើលក់ទៅហោង ។ វរអាចារ្យទាំង ៤ មិញ ព្រឹកព្រហាមបានព្រះខ័ន ទន្ទឹមចាំនៅញឹងទ្វារមិនយល់ព្រះមហោសថឡើយ ក៏ជាទុក្ខមានចិត្តពុំប្រាថ្នា ហើយអ្នកទាំង ៤ នោះ ទៅកាន់សំណាក់ព្រះបាទវិទេហរាជ កាលនោះ ព្រះបាទវិទេហរាជបន្ទូលដណ្តឹងថា ដូចម្តេចកូនគហបតី អ្នកទាំងឡាយសម្លាប់ហើយឬ ? ។ អ្នកទាំង ៤ ទូលថា បពិត្រមហារាជ! យើងខ្ញុំមិនយល់វាចេញមកឡើយ ។ វរពោធិសត្វ កាលព្រះអាទិត្យអរុណរះទ័យឡើង ទើបអ្នកធ្វើអស់អ្នកនគរឲ្យលុះកណ្តាប់ដៃនៃអ្នកហើយ អ្នកមានមហាជនជាបរិវារច្រើន អ្នកឡើងជិះរទេះបរទៅកាន់ទ្វារវាំង នូវបរិវារច្រើន ។ ព្រះបាទវិទេហរាជ ស្តេចបើកបង្អួចរមិលមើលទៅយល់ពោធិសត្វ ។ លំដាប់នោះ, ពោធិសត្វអ្នកចុះអំពីរទេះហើយថ្វាយបង្គំព្រះបាទវិទេហរាជ ព្រះអង្គយល់ហើយគិតថា បាមហោសថនេះ ជាបើរជាសត្រូវនឹងអញហើយ ក៏វាមិនសំពះអញឡើយ ។

លំដាប់នោះ, ព្រះបាទវិទេហរាជឲ្យហៅព្រះមហោសថចូលទៅ ព្រះមហោសថចូលទៅដូចព្រះបន្ទូលព្រះមហាក្សត្រ ហើយក្រាបថ្វាយបង្គំ អង្គុយឰដ៏ឋានមួយអន្លើ ។ អ្នកប្រាជ្ញទាំង ៤ ក៏អង្គុយនៅនាឋាននោះដែរ ។ លំដាប់នោះ, ព្រះបាទវិទេហរាជធ្វើដូចមិនដឹងដល់តិចឡើយ ក៏ដណ្ដឹងថា ហៃបាមហោសថ! បាទៅបង់អញអំពីម្សិល លុះថ្ងៃនេះ ទើបបាមក បាបង់អញដូច្នេះ ហេតុអ្វីបាខានដូច្នោះ ហើយទើបបន្ទូលជាគាថានេះថា:

អភិគោសតោ ឥធាគមាសិ
កឹ សុត្វា កិមាសង្កិតេ មនោ តេ
កោ តេ កិមវោច ភូរិបញ្ញ ឥង្ឃ
តំ វចនំ សុណាម ព្រូហិ មេ តត្ត ។

ហៃបាមហោសថមានប្រាជ្ញាក្រាស់ដូចផែនដីឥតគេស្មើ បាទៅតាំងពីព្រលប់យប់បឋមអំពីម្សិលមិញ លុះថ្ងៃនេះទើបបាមក, បាឮអ្វី ឬចិត្តនៃបាសង្កាថាម្ដេច? ឬអ្នកឯណាថាអ្វីបា? ចូរបាសំដែងថ្លែងសេចក្ដីនោះមកអញទឹងស្ដាប់ពាក្យបាហោង ។

លំដាប់នោះ, ពោធិសត្វទូលព្រះបាទវិទេហរាជថា បពិត្រមហារាជអើយ! អម្ចាស់យកពាក្យអាចារ្យទាំង ៤ នោះហើយ អម្ចាស់បង្គាប់ឲ្យ

សម្លាប់ទូលព្រះបង្គំ ហេតុនោះ អញខ្ញុំមិនមក ថាតែអម្បាលនោះហើយ ក៏សូត្រជាគាថានេះថា :

បញ្ញា រជ្ជា មហោសធោ
យទិ តេ មន្តយិ តំ ជនិន្ទ នោសំ
ករិយា រហោ គតោ អសំសិ
តុយ្ហំ ហាតុកាតំ សុតំ មមេតន្តិ ។

បពិត្រមហារាជប្រសើរក្រៃលែងក្រុងផង ព្រះអង្គជាអម្ចាស់មានព្រះបន្ទូលអំពីព្រលប់យប់បឋមយាមថា រីមហោសថមានប្រាជ្ញា ប្រស្នាច្រើនអញក្រវើនបង្គាប់អ្នកប្រាជ្ញទាំង ៤ ឲ្យសម្លាប់, ពាក្យនេះអម្ចាស់ទៅនាឋានស្ងាត់ ហើយបន្ទូលប្រាប់ព្រះរាជទេពី នូវក្តីកំបាំងនោះប្រាកដកំណត់អញខ្ញុំឮហើយ ។

ព្រះបាទវិទេហរាជ ស្តាប់ពាក្យព្រះមហោសថថាដូច្នោះហើយ ស្តេចមើលទៅនាងឧទុម្ពរទេវីគឺកញ្ញារតី ខ្ញាលពិតាល់ក្នុងព្រះរាជហឫទ័យថា សមនាងនេះ ឲ្យព្រមានមហោសថនេះឯងមិនខេទៀយ ។

(នៅមានត)

រឿងជាតកសង្ខេប

កាព្យពាក្យ ៩

ឃុនសុវត្ថិវេទី យូរ-អ៊ុន ធិពត្ថ

បានទទួល

រង្វាន់លើកទឹកចិត្ត

ផ្នែកកវីនិពន្ធ ក្នុងការប្រឡងអក្សរសាស្ត្រ
របស់សមាគមអ្នកនិពន្ធខ្មែរ នៅឆ្នាំ១៩៦១

(ត-ចប់)

---

គ្រូគុណាស្ដី ពោលកាត់ក្ដី នូវបរលោក
ច្រង់គួរយោគ ប្រមោកសប តបសួរទៅ
ថាអាទិត្យ នឹងព្រះចន្ទ តើតាំងនៅ
លោកនេះក្ដី ឬក៏នៅ លោកឯណា?
តាមដែលពិត ព្រះអាទិត្យ នឹងព្រះចន្ទ
ឃើញជាក់ស្បាន់ កណ្ដូ[១]ច្បាស់ទែង នឹងនេត្រា
មិនឋិតនៅ ក្នុងលោកយើង នេះកាលណា
គឺពិតជា ឋិតនៅនា លោកដទៃ ។
បើលោកទៃ នឹងលោកថ្ងៃ ជាលោកផ្សេង

---

១ កំណាត់, សង្កាត់, កំណត់, ពួក, ជុំ; ក្នុងទីនេះ សំដៅ ជុំ ។

ទ្រង់គួរឈ្វេង ជាបរលោក មានពិតក្រៃ

ព្រោះពាក្យនេះ បើគិតវិះ ប្រែមកវៃ

ក៏បានន័យ ជាលោកផ្សេង ពីលោកយើង ។

ឱព្រះអង្គ ទ្រង់មានគុណ ធ្ងន់ដ៏ធំ!

ឥឡូវខ្ញុំ សុំបែរពោល ដោលដេញដើង

ពីអលាភ ជាតិទាយក មន្ត្រីច្រើន

ដែលស្តីទៀង ជាបុណ្យបាប សាបគ្មានផល ។

លោកអលាភ ថ្វីមិនប៉ាក ព:ទដូទោះ

ព្រោះលោកនោះ គំនិតខ្វី ស្តីឥតធ្លល់

ដឹងជាតិខ្លួន តែមួយមួន មិនខ្វាយខ្វល់

គិតឲ្យយល់ ដល់មនុស្សយើង មានជាតិច្រើន ។

ក្នុងជាតិខ្លះ ខះខំធ្វើ អំពើបុណ្យ

ជាតិខ្លះស៊ិន ធ្វើសុទ្ធបាប ឆ្អាបឆ្អះកើន

ជាតិខ្លះធ្វើ នូវអំពើ ទាំងពីរច្រើន

លោកអលាភ មិនក្រវើន គិតដល់សោះ ។

គិតតែជាតិ មាឌខ្លួនកើត ជាបិណ្ឌល:

ឃាតក:[១] សម្លាប់គោ មោហ៍[២] បាំងស្មោះ

---

១ អ្នកសម្លាប់សត្វ. អ្នកបៀតបៀនសត្វឲ្យបានទុក្ខវេទនា ។ ២ អ្នកវង្វេង, អ្នកងងិតងងល់មិនយល់ខុសត្រូវ ។

លុះលែងជាតិ រក់តចេញ មកពីនោះ
ផលបាបលោះ ព្រោះផលបុណ្យ ជាតិមុនផ្តល់ ។
នាំឲ្យកើត យកកំណើត ជាអលាត
បុណ្យជួយរក់ត លាតឲ្យមុខ សុខសែនសល់
ព្រោះរឿងនេះ ទើបអលាត ជ្រៀតការយល់
ថាបុណ្យបាប ឥតឲ្យផល ពាល់តែសោះ ។

បំណែកខាង វីជកៈ អ្នកកំសត់
ក៏កំណត់ កត់យល់តាម ស្នាមគេនោះ
ដោយសំគាង គាងថាខ្លួន ដឹងជាតិស្មោះ
ដែលមានឈ្មោះ ប្រាកដថា ការសេដ្ឋី ។
សេដ្ឋីនេះ បេះធ្វើទាន ចែកជានធន
ដល់ពួកជន ទុក្ខលំបាក យ៉ាកប្រក្រតី
លុះលះជាតិ ឃ្លាតពីនោះ មកវិញខ្មី
យកជាតិ ជាវីជកៈ ថ្នាក់ខ្ញុំគេ ។
វីជកៈ មិនដឹងជាក់ ជាតិដទៃ
ជាជាតិថ្ងៃ ឬថោកក្រៃ ផ្សេងទៀតទេ
ទើបកំណត់ កត់រឿងនេះ យកជាមេ
ថាឲ្យទាន គ្មានផលទេ ឥតសង្ស័យ ។

លោកអលោក, វិជកៈ ទាំងពីរនោក
ជាមនុស្សពក់ ខ្វីប្រាជ្ញា អន្ធការព្រៃ
ដឹងជាតិខ្លួន តែមួយជាតិ ទៀតវិទិច្ឆ័យ
ជាសីលពាន គ្មានដំរៀ ឥតប្រយោជន៍ ។
បើដឹងជាតិ ពកបានច្រើន ដូចខ្ញុំម្ចាស់
ទើបគួរណាស់ វិទិច្ឆ័យ ផ្ទៃល្អិតល្អោច
ចេះព្រះអង្គ ទ្រង់សណ្ដាប់ តាប់ប្រាមោជ្យ
ខ្ញុំនឹងស្រោច ទឹកព្រះធម៌ បវរថ្មោ ។
ខ្ញុំអម្ចាស់ ដឹងជាតិខ្លួន ដប់បួនជាតិ
ដប់បួនពក ចែកជាទ្វី ពីរកាលា(១)
គឺអតីត អនាគត ជាគូគ្នា
កាលមួយៗ ឃើញជាក់ជា ប្រាំពីរពក ។
ជាតិអតីត គិតទាំងអស់ ប្រាំពីរគត់
ដឹងប្រាកដ គ្មានភ្លេចភ្លាំង ចាំងដួងចិត្ត
ខ្ញុំម្ចាស់ចាំ អាចទូលទ្រង់ សួង់ពិនិត្យ
មានគម្រិត ពកដូចថ្លែង ចែងទៅថា ៖
ជាតិទី ១ កាលនោះខ្ញុំ កេទជាប្រុស

១ កាលា ប្រែថា "កាល, ពេល, សម័យ" ។

បេះសព្វសុស ខាងធ្វើជាង មាសរចនា

នៅនគរ រាជគ្រឹះ ប្រសើរថ្លា

អ្នកហ៊ឹបោ នៅស្រណុក សុខក្សេមក្សាន្ត ៗ

តែជាងមាស ចាសក្នុងចិត្ត គប់មិត្តខូច

មិត្តនាំលួច លួចស្រីគេ ដោយក្លាហាន

ដោយយកទ្រព្យ ភ្ជាប់ចិត្តស្រី ស្ដីពប់អាន

ដោយការមាន ទ្រព្យធនធាន គ្មានរលោះ ៗ

អំពើនេះ ជាកំណប់ កប់ក្នុងចិត្ត

ចាប់ជាប់ស្អិត ឥតរសាត់ បាត់ទៅសោះ

ដូចភ្លើងកប់ ខ្ទប់ក្នុងផេះ ឆេះដូច្នោះ

បាបគ្រោះ គង់មានកាល បណ្ដាលទុក្ខ ៗ

ជាតិទី ២ លុះខ្ញុំឃ្លាត ជាតិពីជាង

បាបនោះឃ្លាំង មិនទាន់ផ្ដល់ ផលទៅមុខ

បែរជាមាន កុសលមួយ ជួយទំនុក–

បម្រុងទុក លុកឲ្យកើត ជាសេដ្ឋី ៗ

សេដ្ឋីនោះ មោះមុតមាំ ចំសីលទាន

ដោយសារមាន កល្យាណមិត្ត ចិត្តឃ្មាតខ្មី

ណែនាំឲ្យ ប្រព្រឹត្តធម៌ ល្អប្រក្រតី

មួយជីវិត ឥតធ្វើអ្វី អាក្រក់សោះ ។

៦ កុសលនេះ ដិតស្អិតនៅ ជៅសន្តាន

ដូចកំណាប់ ទ្រព្យកល្យាណ ក្នុងទឹកជ្រោះ

គង់ពេលណា ផ្តល់សុខា ឥតមានមោះ

គ្មានគេចជោះ ដូចស្រមោល ពុំចោលប្រាណ ។

ជាតិទី ៣ លុះសេដ្ឋី ផុតជីវិត

ទៅកើតពិត ក្នុងភេរព(១) ភពជោកឋាន

ដោយផលកម្ម តាំងកាលកើត ជាងមាសមាន

ដែលបំពាន ហ៊ានបំពារ ភរិយាគេ ។

ចាប់នោះឯង ស្វែងឲ្យផល ដល់អាត្មា

កើតទៅជា សត្វនរក ទុក្ខគ្មានល្ហែ

ចំណែកបុណ្យ បែរជាដុន ត្រឡប់ខ្វេ

គ្មានចេញផ្លែ ប្រែមិនផ្តល់ ផលពេលនោះ ។

ជាតិទី ៤ ខ្លួនខ្ញុំរួច ពីនរក

ឋានណាមក រងតែទុក្ខ ធុកឥតលោះ

មកកើតជា កូនស្វាឈ្មោល ពេលចាប់គ្រោះ

ត្រូវមេហ្វូង នៃស្វានោះ ជោះ(២)ពងពាយ ។

---

១ ឈ្មោះឋាននរកមួយ ដែលមានសូរសម្រែកកងរំពង ។ ២ ទាំផ្តើះ, ទាប់បែក ។

ជាតិទី ៥ កម្មខ្ញុំប្រែ ខ្ញែពីស្វា

មកកើតជា កូនគោឈ្មោល ពោលពងកយ

ដោយគេក្រៀវ កាំយកពូជ ដូចគ្មានស្ដាយ

ហើយគេកាយ ប្រើបង្គំ ក្រំគ្មានស្បើយ ។

ទី ៦ លុះខ្ញុំស្លាប់ ពីគោមក

បានយោនយក ជាតិជាមនុស្ស ខុសគេខ្ទើយ

មានអង្គជាត មិនដូចមាឌ គេសោះទ្បើយ

ជនប្រុសស្រី ពុំកៀកកើយ យកជាគ្នា ។

ទី ៧ ខ្លួនខ្ញុំវិល ទៅកើតឮ

សួគ៌ាល័យ ត្រៃត្រិង្ស ជាទេវ្ដា

ដោយគេជះ តបះ(១)ធ្វើ កាលកើតជា

ជាតិសេដ្ឋី បិតនៅនា កោសម្ពី(២) ។

ដោយអំណាច នៃកុសល ផលដដែល

នាំខ្ញុំហោល ធ្លោលមកកើត ជាបុត្រី

នាមរុចា ជាធីតា ព្រះចក្រី

តែមិនទាន់ អាចកាត់ក្រី គេងស្រីបាន ។

បតិត្រព្រះ នរេន្ទ្រា ជាម្ចាស់រដ្ឋ

---

១ ការប្រព្រឹត្តកាន់វត្ត ។ ២ ឈ្មោះទីក្រុងមួយ នៅប្រទេសឥណ្ឌា សម័យពុទ្ធកាល ។

ហេតុប្រាកដ សឹងកើតមាន នៅឧទ្យាន
ឈ្មោះនន្ទវ័ន ជាន់ត្រៃត្រិង្ស ជាសួគ៌ឋាន
ឥឡូវមាន ទេពច្រើនប្រាណ មកជួបជុំ ។
ហើយនាំគ្នា ធ្វើកម្រង ចងបាច់ផ្កា
ច្រើនត្រៀបត្រា រៀបទុកដាក់ តាមថ្នាក់ក្រុម
ដើម្បីធ្វើ កិច្ចមង្គល ទទួលខ្ញុំ
រៀបផ្សំផ្គុំ នឹងទេវបុត្រ ឈ្មោះជវៈ ។
ពុំយូរយារ ខ្ញុំនឹងលា ព្រះបិតា
ទៅកើតជា ទេពកញ្ញា សមឋានៈ
ជាប្រពន្ធ ដ៏ប្រពៃ នៃជវៈ
សោយសុខៈ ថ្នាក់ទេព្តា ណាព្រះអង្គ! ។
ខ្ញុំម្ចាស់ នឹងអន្ទោល យោលទៅមក
ក្នុងលោក វាលសង្សារ ប្រាំមួយវង់
លុះដល់ជាតិ ទីប្រាំពីរ វិលប្រែអង្គ
ជាទេពខ្ជន់ អង្គជាប្រុស ធ្នុះបុទ្ធៃក្រ ។
ចាប់ពីនោះ ខ្ញុំម្ចាស់ ប្រុសរហូត
លែងរបូត កើតប្រុសឆ្អៅ ទៅវិញវៃ
ដោយសារខ្ញុំ ដឹងសុខុម ធម៌ប្រពៃ

មិនហ៊ានលៃ លួចសេពសន្ថវ៍ ប្រពន្ធគេ ។
តាមការណ៍ពិត ជនភេទប្រុស បើប្រាថ្នា
ឲ្យអាត្មា មានទុប្ដា ប្រុសឥតរេ
ត្រូវតែតម កុំលូកលាន់ ប្រពន្ធគេ
ទ្រង់ះឃើញទេ ខ្ញុំអម្ចាស់ ពីដើមប្រុស ។
ជនភេទស្រី បើប្រាថ្នា ភេទប្រុសវិញ
ត្រូវបំពេញ វត្តស្វាមី កុំឲ្យខុស
គោរពប្ដី ទុកដូចជា ទេវ្ដាមនុស្ស
ភេទប្រាណប្រុស នឹងសម្រេច ស្រេចមិនខាន ។
សម្បត្តិទិព្វ គឺអាយុ សុខនឹងយស
ពុំដែលលស់ លះបង់ចោល ជនកល្យាណ
ដែលជាអ្នក វៀរចាកបាប អំបាលម៉ាន
ធ្វើតែទាន រៀនកាន់សីល មួយជីវិត ។
ហេតុនេះខ្ញុំ សុំព្រះអង្គ ផ្ចង់ព្រះទ័យ
កាន់វិន័យ ប្រពៃណី តាមធម៌ពិត
សូមលះចោល កម្មកម្រោល ខុសក្រមក្រិត្យ
សូមប្រព្រឹត្ត ផ្តិតផ្ទៃធម៌ ដ៏ឧត្តម ។

ស្មេះទុករឿង នាងរុចា តែត្រឹមនេះ

សូមត្រិះរិះ ពិចារណា ការណ៍ព្រះព្រហ្ម
នៅព្រហ្មលោក កំពុងយោគ ដើរចង្ក្រម(១)
រួចហើយផ្ទុំ សម្ងំអង្គ ត្រង់អាស្នា ។
ព្រះព្រហ្មនេះ មាននាមថា នារទ:
កស្សប: លោកជាអ្នក មានវិជ្ជា
អាចនិម្មិត គិតតំណែង តែងកាយា
ចង់យ៉ាងណា ក៏ធ្វើបាន ប្រាណដូច្នោះ ។
ពេលសម្រាក លោកក៏ងាក បែរនេត្រា
ប្រើប្រាជ្ញា ឆ្កាប្រមើល ដោយសគ្រោះ
មកឯឋាន មានមនុស្សនៅ ក្រែងកើតមោះ
កើតជម្លោះ ឬមានហេតុ ភេទដូចម្តេច ។
លោកធ្មៀងនេត្រ សង្កេតឃើញ នាងវុធា
មានប្រាជ្ញា កំពុងទំ រំពឹកស្តេច
តែពោះបី នាងប្រឹងស្តី ក៏មិនស្រេច
ដ្បិតអង្គស្តេច ត្រាច់ព្រះទ័យ ទៅជ្រៅឆ្ងាយ ។
លោកយល់ថា បើអាត្មា ចេញទៅជួយ
នាងបាត់ព្រួយ ដោយស្តេចនោះ នឹងប្រែក្លាយ

១ ការដើរទៅដើរមក, ការដើរសាចុះសាឡើងច្រើនបក ដើម្បីឲ្យស្រួលខ្លួន ។

យល់ឃើញត្រូវ ត្រង់តាមផ្លូវ ធម៌ទាំងឡាយ
បែរកើកាយ ចាយកម្លាំង តាំងប្រព្រឹត្ត ។
នារទៈ អ្នកក៏ហោះ ផ្លោះពីព្រហ្ម[១]
សំដៅចំ វិមានចន្ទុក[២] សោភ័ណពិត
លុះដល់ហើយ ព្រះនារទ សូត្រប្រសិទ្ធ
សំដែងឫទ្ធិ និម្មិតខ្លួន ជាឥសី ។
ឥសីនោះ ឋិតនៅឯ អាកាសឋាន
ជិតពិតាន ល្វែងប្រាសាទ ស្អាតសិរី
ដៃគ្មានកាន់ ជើងគ្មានជាន់ គ្មានជាប់ដី
ធ្វើអាការ ឲ្យចក្រី ទតឃើញភ្លាង ។
ព្រះមហាក្សត្រ អង្គិត ទ្រង់ឃើញជាក់
ទ្រង់ក៏ភ្ញាក់ ដូចកន្ត្រាក់ ផ្អកស្រពាង
ទ្រង់តក់ស្លុត រន្ធត់ខ្លាំង តាំងហៅនាង
ឲ្យមើលខាង ជិតពិតាន ឋានប្រាសាទ ។
នាងរុចា ទតឃើញថា តាឥសី
ក៏ធ្វើក្តី គារវៈ[៣] សំពះថ្វាត់
រួចបែរទៅ ក្រាបទូលន័យ ព្រះមហាក្សត្រ

---

១ ឋានព្រហ្ម, ព្រហ្មលោក ។ ២ ឈ្មោះប្រាសាទ ។ ៣ ការគោរព ។

ឲ្យកំចាត់ កាត់ការភ័យ ក្នុងទយា ។

ព្រះរាជា ក្រាបវន្ទា តាឥសី

រួចត្រាស់ខ្មី ដោយសេចក្តី យ៉ាងនេះថា

ចុះលោកម្ចាស់ ច្បាស់ជាអ្វី មកពីណា

រូបសោភា ឆវីថ្លា(១) ល្អអ្វីម៉្លេះ ?

លោកមានឫទ្ធិ ឥទ្ធិលាភ អស្ចារ្យក្រៃ

ឋិតលើផ្ទៃ នៃអាកាស ប្រាសាទនេះ

តើលោកមាន វិជ្ជាអ្វី ប្រពៃអេះ

ទើបអាចបេះ សំដែងឫទ្ធិ ពិតអស្ចារ្យ ?

ឥសីព្រហ្ម ថាអាត្មា ឈ្មោះនារទ(២)

ជាព្រហ្មព្រត(៣) នៅព្រហ្មលោក យោគធម៌អាថ៌

ដែលរូបល្អ ទាំងមានឫទ្ធិ ច្រើនប្រការ

គឺដោយសារ ការប្រព្រឹត្តិ ធម៌សុចរិត ។

កាលដែលកើត យកកំណើត ក្នុងភពមុន

---

១ ឆវី ប្រែថា « ស្បែកសម្បុរថ្ងៃ » គឺស្បែកស្តើង ដែលនៅក្រៅសាច់ សម្រាប់ទទួលកំដៅថ្ងៃ ។ ២ ហៅបាន ២ យ៉ាង ថា « នារទ » ក៏បាន ថា « នារទៈ » ក៏បាន ។ ៣ ព្រត ជាពាក្យសំស្ក្រឹត, បាលីថា « វត្ត » ប្រែថា « បព្រឹត្តធម៌, កាន់សីល » ។ នារទ អាន នារៈទ់, ព្រត អាន ព្រត់ ដូច អស្តង្គត, ប្រាកដ, ដេតពត, ទ្រព្យធន, កុសល ជាដើម ។

បានធ្វើបុណ្យ តាំងដឹងគុណ ដ៏ពិសិដ្ឋ
កាន់សច្ចៈ ពោលទៀងទាត់ ប្រាកដពិត
តាំងប្រព្រឹត្ត អហិង្សា ការពារសត្វ ។
ហើយទូន្មាន ប្រៀនប្រាបខ្លួន សួនទោសៈ
មានចាគៈ លះកំណាញ់ កាញ់ស្វិតក្តាត់
ចែករំលែក ញែកធនធាន ឲ្យទានសត្វ
កុសលនេះ ជាសម្បត្តិ ឲ្យមានបុទ្ធិ ។
— ចុះលោកម្ចាស់ ជ្រាបច្បាស់ទេ ម្តាយឪពុក
គេគួរទុក ជាមានគុណ ធ្ងន់មែនពិត
បើមានមែន គួរកូនគប កបពេញចិត្ត
ខ្ញុំតែងគិត គំនិតវល់ ពុំយល់សោះ ។
តាំងទេព្តា ឋានសួគ៌ា មានឬទេ
សូមរិះរេ ពីបរលោក ឯនាយនោះ
តើមានពិត ឬមិនមាន សូមទានដោះ
ដោយចិត្តស្មោះ ធ្វើសង្គ្រោះ សោះសង្ស័យ ។
— បពិត្រទ្រង់ ត្រង់រឿងនេះ រូបអាត្មា
មិនដោះសា ឲ្យវែងទេ នាំយូរក្រៃ
ព្រោះរឿងនេះ ទ្រង់បានជ្រាប ពីស្រីថ្ងៃ

នាងកែវ ៗ លៃខ្ទួលហើយ ណាចមពន្ស!
អាត្មាភាព ថ្វាយសេចក្តី យ៉ាងខ្ជាថា
ជនពាលា ប្រាជ្ញាពក់ ខ្ជាក់ខ្ទៅល្ងង់
ថាម៉ែឪ ឥតមានគុណ ជូនលើអង្គ
ថានេះចង់ បំបាត់ចោល ព្រហ្មវិហារ ។
ឯអ្នកប្រាជ្ញ អាចយល់ថា លោកមានគុណ
ព្រោះចិត្តបុណ្យ ស្រោចស្រពបុត្ត ក្រអូស្ការ
អាស្រ័យហេតុ ដែលលោកមាន ព្រហ្មវិហារ
ទើបជីវិត នៃកុមារ រស់រានបាន ។
ពួកទេព្តា ឋានសួគ៌ា នឹងបរលោក
ពាលប្រាយព្រោក ដោយចេតនា ថាមិនមាន
បើទេព្តា ឋានសួគ៌ា បរលោកគ្មាន
ចុះរូបអង្គ អាត្មាមាន ជាតិស្រោប ។
ឯអាត្មា ជាពួកទេព នៅសួគ៌ា
ដែលទុកជា ឋានបរលោក តាមផ្លូវច្បាប់
អ្នកថាគ្មាន ព្រោះហេតុខ្លួន ប្រាជ្ញាអាប់
សំដៅចាប់ ឃើញទីងងៃគូក ទើបថាមាន ។
ឃើញម្តេចកើត បើឋានសួគ៌ ឆ្ងាយពេកក្រៃ

ឆ្ងាយហួសថ្ងៃ ហួសព្រះចន្ទ ជាប្រធាន
ដែលឃើញបាន លុះតែលោក ចំរើនឈាន
ធ្វើជាយាន ទើបហោះច្យាន ដល់ទីនោះ ។

— ឱឥសី! បើបរលោក ពិតជាមាន
ខ្ញុំសូមទាន ខ្ចីប្រាក់លោក មួយពាន់ចុះ
ដល់ខ្ញុំសង សងមួយម៉ឺន គ្មានគេបដោះ
តែសង្គ្រោះ សូមទៅទារ ឯបរលោក ។

— ព្រះចមពង្ស ទ្រង់ជ្រាបទេ មនុស្សទុក្រិដ្ឋ
មានលិខិត ពិតពស្តុតាង យ៉ាងគរគោក
ច្បាប់កាត់ទោស ឲ្យជាប់គុក តាមផ្លូវលោក
អស់ជ័យជោគ ឃោតតែទុក្ខ ទុកឥតក្សាន្ត ។
តើមានច្បាប់ សម្រាប់រដ្ឋ ឲ្យអ្នកទារ
អាចបើកទ្វារ ពារពុះដល់ អ្នកទោសបាន
ទារបំណុល បុលចំពាក់ ពាក់ប៉ុន្មាន
តើទារបាន ឬពុំបាន សូមទ្រង់ថ្លែង?

— ឱឥសី! គ្មានច្បាប់អ្វី ឲ្យចូលទារ
ទោះបីទ្វារ អនុញ្ញាត ឲ្យចូលស្តែង
ក៏អ្នកទោស គ្មានធនធាន លើងធេង

តើបានអ្វី ទឹងសងឯង ណាលោកតា !

– ព្រះមហាកដ! សេចក្ដីនេះ យ៉ាងណាមិញ
រឿងទ្រង់វិញ ដែលខ្ញុំប្រាប់ ជាក់ដូចគ្នា
ទ្រង់មានទោស ជាទុក្រិដ្ឋ ដៀតពាលា
បាបផ្ដន្ទា ឲ្យទ្រង់ទៅ នៅនរក ។
បើចមពង្ស កំពុងទ្រង់ សោយគ្រោះថ្នាក់
ដោយការធ្លាក់ ទៅរងទុក្ខ មុខពក្ក
មានភ្លើងឆេះ សត្វកាចខាំ ត្រាំលាមក
លិចក្នុងភក់ ឈ្លក់ជាប់ស្អិត ក្នុងបន្ទា ។
ឬកំពុង លង់លិចក្នុង ខ្ទះទឹកក្ដៅ
ឬក៏ទៅ ផឹកទឹកក្រុក ហុតគូថ
ឬទៅរង លំបាកអន្ដ ត្រង់ទីណា
ឲ្យអាត្មា ទៅពារប្រាប់ ដូចម្ដេចបាន ។

ព្រះរាជា ទ្រង់ពាល់ប្រាជ្ញ មិនអាចតប
ទើបសម្រប ស្របចុះញ៉ម ប្រគល់ប្រាណ
ទ្រង់តក់ស្លុត ខ្លាចបាបធ្ងន់ ពន់ប្រមាណ
បន្ទូលថ្កាន ដោយសូរសៀង ទន់ភ្លន់ថា ៖

សូមលោកតា មេត្តាប្រោស សង្គ្រោះខ្ញុំ

លោកតាកុំ ផ្តុំប្រកាន់ នឹងករុណា
ធ្វើម្ដេចហេតុ តែខ្ញុំខ្លៅ ឆៅប្រាជ្ញា
សូមលោកតា ជួយជ្រោងគ្រាហ៍ ឲ្យផុតទុក្ខ ។
សូមប្រាប់ផ្លូវ ដែលនឹងទៅ កាន់ឋានសួគ៌
ជាផ្លូវគួរ ធ្វើដំណើរ ដើររកសុខ
ជាផ្លូវត្រង់ តម្រង់ទៀស អបាយមុខ
ខ្ញុំសូមទុក លោកតាជា គ្រូប្រដៅ ។
ឥសីព្រហ្ម ទទួលស្ដាប់ សព្វគម្រាស់
ទើបប្រកាស ព្រះសទ្ធម្ម ឧត្តមជ្រៅ
ស្រោចស្រង់ស្ដួច ឲ្យចរត្រាច់ តាមផ្លូវត្រូវ
រួចហោះស្ទៅ សំដៅទៅ ព្រហ្មលោក ។
រឿងនារទៈ ជាក់ចប់សព្វ ត្រឹមប៉ុណ្ណោះ
តពីនេះ នឹងប្រជុំ ផ្ដុំប្រយោគ
សមោធាន នូវជាតក ឆកជាតិលោក
ខ្ញុំនឹងក្រោក យោគពយនាម ដូចតទៅ ៖
លោកអលាត ជាទាយក រដ្ឋមន្ត្រី
កាលនោះខ្ញុំ ឥឡូវបែរ ចេះរឹងស្ទៅ
ជាភិក្ខុ ទេវទត្ត គាត់ចិត្តខ្មៅ

ពាលកំទៀត ទៅប្រទូស្ត ព្រះសម្ពុទ្ធ ។
លោកសុនាម រាជអាមាត្យ កាលនោះណា
បានកើតជា ភទ្ទជិ ប្រាជ្ញមុត ;
លោកវិជ័យ ក្នុងកាលនោះ គឺសារីបុត្ត
ប្រាជ្ញផុត ជាឯកអគ្គ សាវ័កស្ដាំ ។
វីដកៈ ជាតាសៈ អ្នកដទៃ
កាលនោះវៃ ឥឡូវបុណ្យ ជួយឧបត្ថម្ភ
ជាមោគ្គល្លាន មានឫទ្ធិខ្លាំង ដោយបុញ្ញកម្ម
ជួយដឹកនាំ ឲ្យបានជា សាវ័កឆ្វេង ។
លោកអចេលក៍ ដែលឈ្មោះគុណ មានបុណ្យសក្តិ
កាលនោះជាក់ ឥឡូវនេះ បុណ្យគុបតែង
ជាកូនស្តេច លិច្ឆវី ប្រាជ្ញខែង
មាននាមស្តែង សុនក្ខត្ត ពិតប្រាកដ ។
នាងរុចា ជាធីតា ប្រាជ្ញឆើត
បានមកកើត ជាអានន្ទ អនុជរ័ត្ន ;
ឯព្រះបាទ អង្គតិ មហាក្សត្រ
គឺកស្សប· តេភាចារ្យ ឧរុវេឡ ។
នារទៈ កស្សបៈ មហាព្រហ្ម

គឺបរមេ សម្ពុទ្ធម្ចាស់ ត្រាស់ទុកកេរ្តិ៍
ជាព្រះមួយ ជួយស្រង់សត្វ គ្មានទំនេរ
សាស្នាទ្រង់ គង់ឋិតថេរ យ៉ាងឧត្តម ។

## បរិយោសានកថា

រឿងនារទៈ ដែលលោកអ្នក កាន់នៅដៃ
បើតាមន័យ សេចក្តីយល់ យោបល់ខ្ញុំ
ជាជារឿង ដ៏មានអាថ៌ ការណ៍សុខុម
ដូចនឹងផ្តុំ ប្រជុំគោល យ៉ាងនេះថា ៖

គោលទី ១ បំណងឲ្យ វៀរបាបមិត្រ
ឲ្យចូលជិត មិត្រកល្យាណ មានប្រាជ្ញា
ព្រោះបាបមិត្រ ពិតនាំដើរ ផ្លូវសោកា
មិត្រកល្យាណ៍ នាំដើរផ្លូវ ត្រូវប្រពៃ ។
គួរយ៉ាងដូច អង្គតិ ព្រះមហាក្សត្រ
ស្តេចទ្រង់ស្គាត់ ទៅរកចួប ពាលចង្រៃ
នាមគុណៈ ជាអចេលក៍ បួសនៅព្រៃ
ទ្រង់ក៏លង់ ព្រះហឫទ័យ តាមពាលា ។
លុះទ្រង់ចួប នារទៈ មហាព្រហ្ម

អ្នកប្រាជ្ញធំ ដែលតំណែង ក្នុងកាយា
ជាឥសី ចុះមកស្តី សន្ទនា
ព្រះរាជា ក៏យល់ត្រូវ ផ្លូវអាថ៌ធម៌ ។

គោលទី ២ ឲ្យសំភ័ជឿកម្មផល

ថាកុសល ផ្តល់អារម្មណ៍ គួរត្រេកអរ
អកុសល ផ្តល់អារម្មណ៍ នាំវីវរ
កម្មទាំងពីរ នាំសត្វចរ ទៅសួគ៌នរក ។
ព័ស្តុតាងដូច រាជកុមារី ស្រីវុតា
កាលកើតជា ជាងមាសពិត ចិត្តអាក្រក់
ហ៊ានប្រព្រឹត្ត ធ្វើអំពើ ដ៏លាមក
កម្មតម្រក់ នេះនាំទៅ រងទុក្ខធ្ងន់ ។

គោលទី ៣ ស្តីបំភ្លឺ ឲ្យស្គាល់ជាក់

ទូវលោកអ្នក ដ៏មានគុណ ជាអនន្ត
ដូចឪម៉ែ ថែរក្សា បុត្រត័ន្តគន់
ពុំដិនធ្អន់ ធន់លំបាក យ៉ាកក្រៃគ្រូន ។
បុត្តធីតា បើដឹងថា ខ្លួនរស់រាន
ដោយសារមាន ព្រហ្មវិហារ ជាមាំមួន

នៃម៉ែឪ ដែលមានគុណ ធ្ងន់លើខ្លួន
គួរថែធ្នូន តបលោកវិញ ទើបពេញត្រូវ ។

គោលបំណង ប៉ុន្មាន ៣ នៃរឿងនេះ
ខ្ញុំបានរិះ គិតពិនិត្យ សង្កេតទៅ
ឃើញជាក់ថា បើមនុស្សយើង ដើរតាមផ្លូវ
គោលនេះក្លូវ នឹងបានទៅ ចួបសួស្តី ។

ក្នុងលោកនេះ គឺជាមនុស្ស មានចរិយា
គួរស្នេហា រាប់រកគ្នា ជាមេត្រី
មានចិត្តត្រង់ សង្គ្រោះគ្នា ជាប្រក្រតី
ដោយសារគុណ គោលទាំងបី ដែលបានកាន់ ។

បើជឿថា ស្លាប់កាលណា តែងកើតវិញ
គួរបំពេញ នូវធម៌នេះ ទើបសោភ័ណ
ដើម្បីទុក ជាកំណប់ ទ្រព្យសំខាន់
ជាស្ពាន់ គ្រាន់ទីពឹង តាំងនឹងខ្លួន ។

ថៃ្ងទី ៣ នៃកញ្ញា ជួតពិសេស
ទៅក្នុងគ្រិស្ត សតវត្សរ៍ ដប់ប្រាំបួន
ហុកសិបគត់ ជាឆ្នាំសល់ គល់ទំនួន

ពុទ្ធស័កស្ទួន ជូនពីរពាន់ ប្រាំរយបី ។

ក្នុងជំនាន់ ជាន់សម័យ ព្រះប្រមុខរដ្ឋ

នាមប្រាកដ ព្រះសីហនុ មានបារមី

មានតេជះ ឈ្នះសត្រូវ សួយផែនដី

កម្ពុជា ឯករាជ្យថ្មី ល្បីខ្ចរខ្ចាយ ។

នេះជាពេល ដែលខ្ញុំចាប់ ប្រារព្ធតែង

រឿងនេះឯង រហូតចប់ សព្វបរិយាយ

ឥឡូវខ្ញុំ សុំបង្គុំ ឈប់អធិប្បាយ

លែងអក់ប្រាយ ត្រឹមប៉ុណ្ណេះ សូមលាហើយ !

# សម្មោទមានជាជាតក

ព្រះញាណកោសល ញាណ-ឈឹង ប្រែរៀបរៀង

---

កាលព្រះបរមសាស្តាទ្រង់ប្រថាប់នៅនិគ្រោធារាម ជិតក្រុងកបិលព័ស្តុ ទ្រង់ប្រារព្ធរឿងជំលោះរបស់ក្រុមព្រះញាតិ ហើយទ្រង់សំដែងនូវព្រះគាថាមានបទថា សម្មោទមានា ដូច្នេះជាដើម ។

រឿងជំលោះនេះ មានសេចក្តីពិស្តារក្នុងកុណាលជាតកឯណោះ ។ សេចក្តីថា ក្នុងកាលនោះ ព្រះបរមសាស្តា ទ្រង់ត្រាស់អញ្ជើញពួកស្តេចធំ ៗ ជាព្រះញាតិមកកាន់សំណាក់ព្រះអង្គហើយ ទ្រង់ត្រាស់ថា "បពិត្រមហាពជពាំងឡាយ ! ការប្រកួតប្រកាន់គ្នាឯងរវាងពួកញាតិបែបនេះ មិនសមហេតុផលសោះឡើយ ដ្បិតកាលពីមុនមានពួកសត្វតិរច្ឆានជាច្រើន កាលដែលនៅរួមមូលគំនិតមានសេចក្តីព្រមព្រៀងគ្នា មានកម្លាំងគ្របសង្កត់ពួកបច្ចាមិត្តដទៃ ហើយបានដល់នូវសុវត្ថិភាព លុះចំណេរកាលជាខាងក្រោយមក កើតវិវាទទាស់ទែងខ្វែងគំនិតគ្នា ក៏ដល់នូវការវិនាសក្នុងកាលនោះ" , លុះទ្រង់ត្រាស់ប៉ុណ្ណោះហើយ ទើបពួករាជត្រកូលជាព្រះញាតិសូមអារាធនាឲ្យទ្រង់សំដែងជាតកនោះ ព្រះអង្គក៏នាំអតីតនិទានតទៅថា :

អតីតេ ពារាណសិយំ ព្រហ្មទត្តេ រជ្ជំ ការេន្តេ...

សេចក្ដីថា ក្នុងកាលដែលកន្លងទៅហើយ មានព្រះមហាក្សត្រមួយព្រះអង្គ ទ្រង់ព្រះនាមព្រះបាទព្រហ្មទត្ត សោយរាជ្យសម្បត្តិក្នុងក្រុងពារាណសី ។ កាលនោះ ព្រះពោធិសត្វជាអម្ចាស់នៃយើងកើតជាតាបពួកជាមេហ្វូង មានតាបច្រើនពាន់ជាបរិវារ តែងនៅក្នុងដងព្រៃមួយជាទីសប្បាយ ។ កាលនោះ មានព្រានសត្វស្លាបម្នាក់បានទៅកាន់ព្រៃជាទីនៅរបស់តាបទាំងនោះ បានធ្វើទ្រនំសម្រាប់ឲ្យតាបរាំ លុះដឹងថា តាបទាំងនោះទំជុំគ្នាហើយ ក៏ដំឡើងលប់ (សម្រាប់គ្រប) លើពួកតាបទាំងឡាយរួចហើយរាយដំព្រៃជុំវិញ ដេញតាបនានាឲ្យរត់មកមូលជាមួយក្នុងផ្លូវតែមួយ ហើយចាប់ដាក់ត្រក នាំយកទៅកាន់ផ្ទះលក់ចំណាយចិញ្ចឹមជីវិតរបស់ខ្លួនសព្វៗកាល ។

ថ្ងៃមួយជាខាងក្រោយ ពោធិសត្វបាននិយាយនឹងពួកតាបទាំងអស់ជាបរិវារថា ៉ ព្រានសត្វស្លាបនេះតង់តែនឹងធ្វើពួកញាតិរបស់យើងឲ្យដល់នូវសេចក្តីវិនាសជីវិត (ជាច្រាកដ) ខ្ញុំស្គាល់ឧបាយមួយថា តាំងពីថ្ងៃនេះទៅ មុខជាព្រានសត្វស្លាបនេះ មិនអាចនឹងចាប់យើងបានដោយងាយទេ កាលណាឃើញមានលប់គ្របពីលើពួកយើង តាមការព្យាយាមរបស់ព្រាន, កាលនោះ ពួកយើងម្នាក់ ១ ត្រូវតែយកក្បាលច្រកក្នុងក្រឡាលប់មួយក្រឡាម្នាក់ៗ ហើយខ្លួលលប់លើកឡើងនាំយកទៅកាន់ទីគួរតាមប្រាថ្នា ទំលាក់ចោលលើគុម្ពបន្លាណាមួយ លុះធ្វើដូច្នេះរួចហើយ

ពួកយើងនឹងហើរទៅតាមចន្លោះខាងក្រោមដើមលប់នោះដោយសួស្តី " ។ ពួកចាបទាំងអស់ក៏ទទួលព្រមថា "សាធុប្រពៃហើយៗ" ។ ក្រោយពីនោះមកមិនយូរប៉ុន្មាន ព្រានសត្វស្លាបបានដាំឡើងលប់គ្របពីខាងលើ ( ទ្រនំចាបទាំងនោះ ) ដូចធម្មតា ។ ចាបទាំងនោះក៏ទទួលលប់នាំយកទៅចោលលើគុម្ពបន្លា ហើយហើរចេញទៅអំពីកន្លែងនោះ តាមចំណែករៀងខ្លួន ដូចន័យដែលចាបពោធិសត្វនិយាយហើយនោះ ។ ព្រានសត្វស្លាបចំពាំតែដោះលប់រួចចេញពីគុម្ពបន្លាបាន ពេលវេលាក៏ជ្រុលហួសទៅតាកប្រប្រក ។ ព្រានសត្វស្លាបនោះ មានតែដៃទទេដើរទៅកាន់ផ្ទះរបស់ខ្លួន ឥតបានលាភអ្វីតិចតួចសោះតែកល់ថ្ងៃ ។ លុះថ្ងៃតមក ភរិយារបស់ព្រានទឹងអន់ចិត្តណាស់ក៏ស្តីបន្ទោសថា « អ្នកឯងត្រឡប់មកកាន់ផ្ទះដោយដៃទទេតែកល់ៗថ្ងៃ ប្រហែលជាមានគ្រកូលគ្រួសារដទៃឲ្យដឹកខាងក្រៅដែលខ្លួនត្រូវចិញ្ចឹមពុំលែងឡើយ ។ ព្រានសត្វស្លាបនិយាយដោះសាថា " ម្នាលនាង ! យើងពុំមានគ្រកូលណាដទៃ ដែលយើងត្រូវចិញ្ចឹម (ដូចនាងស្មាននោះ) ទេ, ប៉ុន្តែ ចាបពួកទាំងនោះមានសេចក្តីព្រមព្រៀងគ្នាក់បានទូលនាំយកលប់ដែលយើងលាតគ្រងដាក់ពីខាងលើ ទៅបោះចោលនៅគុម្ពបន្លាហើយហើរទៅ ក៏ឯចាបពួកទាំងនោះមិនមែនស្រុះស្រួលគ្នាសព្វកាលទេ (គង់នឹងឈ្លោះទាស់ទែងនឹងយោបល់គ្នាវិញ) នាងកុំគិតឡើយ

កាលណាបើតាបពួកតាំងនោះតាស់ទែងគ្នាហើយ យើងនឹងចាប់យកពាំងនោះនាំមកបង្ហាញ នឹងធ្វើនាងឲ្យមានមុខស្រស់ស្រាយក្នុងកាលជាខាងក្រោយ លុះនិយាយហើយ ក៏សូត្រជាបទព្រះគាថានេះថា :

សម្មោទមានា គច្ឆន្តិ

ជាលមាទាយ បក្ខិនោ

យទា តេ វិវទិស្សន្តិ

តទា ឯហិន្តិ មេ វសន្តិ

ប្រែថា សត្វស្លាបតាំងឡាយ កាលដែលមានសេចក្ដីព្រមព្រៀងគ្នា តែងទូលលប់នាំយកទៅតាលហើយហើរទៅ លុះកាលណា សត្វស្លាបតាំងនោះតាស់ទែងគ្នា វានឹងមកកាន់អំណាចនៃយើងក្នុងកាលនោះ ៗ

អធិប្បាយថា ព្រានសត្វស្លាបញ៉ាំងករិយាឲ្យស្រុះស្រួល ដោយពាក្យជាបទព្រះគាថាដូចខាងលើនេះ ៗ បណ្ដាបទតាំងឡាយនោះ ត្រង់បទថា កាលណាសត្វស្លាបតាំងនោះតាស់ទែងគ្នាដូច្នេះ តាបភូកតាំងនោះមានលទ្ធិផ្សេងពីគ្នា មានការប្រកាន់ខុសគ្នា ហើយនឹងកើតវិវាទឈ្លោះប្រកែកគ្នាឯង ៗ ត្រង់បទថា វានឹងមកកាន់អំណាចនៃយើង ក្នុងកាលនោះ ថានដល់ពាក្យថា តាបពួកតាំងអស់នោះវានឹងលុះអំណាចយើង ក្នុង

កាលនោះ ៗ កាលមានករណីដូចបានពណ៌នាមកយ៉ាងហ្នឹងហើយ យើងនឹងចាប់យកកំពាំងនោះនាំមកកាន់ទីលំនៅនៃយើង នឹងធ្វើនាងឲ្យមានមុខស្រស់ស្រាយ (តាមគួរដល់សេចក្តីប្រាថ្នា) ។

លុះកន្លងទៅ ២-៣ ថ្ងៃហើយ មានចាបពួកមួយចុះកាន់វិគោចរ-ភូមិ មិនបានដឹងជាមុនក៏ទៅជាន់ក្បាលចាបដទៃមួយទៀត ។ ឯចាបដែលរងគ្រោះត្រូវគេជាន់ក្បាលនោះ កើតខឹងតូចចិត្តថា "នរណាមកជាន់ក្បាលយើងដូច្នេះ?" ។ ចាបដែលមានកំហុសតបថា "ខ្ញុំមិនបានដឹងជាមុនទើបចុះមកជាន់ សុំអ្នកកុំខឹងតូចចិត្តឡើយ" សូម្បីចាបនោះអង្វរដូចម្តេចក្តី ចាបអ្នករងគ្រោះក៏នៅតែខឹងខ្ទូរខ្ទាំ ។ ចាបទាំងពីរនោះដដែកតបតនឹងគ្នាទៅវិញទៅមកដដែល ៗ កើតជំលោះនឹងគ្នាដោយពាក្យថា "ទំនងជាអ្នកម្នាក់ឯងនេះ ទូលទំលាយលប់តែឯងបានឬ? ។ កាលដែលចាបទាំងពីរកើតទាស់ទែងខ្វែងយោបល់គ្នាដូច្នោះ ពោធិសត្វគិតថា "សុវត្ថិ-ភាពនឹងមិនកើតមានដល់ការទាស់ទែងខ្វែងយោបល់គ្នាទេ, ឥឡូវសត្វស្លាបទាំងនោះនឹងមិនបានទូលទំលាយលប់ដូចមុនទៀតទេ យើងនឹងដល់នូវមហាវិនាសក្នុងវេលានោះ ព្រានសត្វស្លាបក៏បានឱកាស (ចាប់យកបានដោយងាយ) បើដូច្នោះ យើងមិនអាចនឹងនៅក្នុងហ្វូងនេះបានឡើយ" ។

ពោធិសត្វគិតហើយក៏នាំបរិស័ទរបស់ខ្លួនទៅនៅក្នុងទីដទៃវិញ ។ លុះកន្លង ២ ៣ ថ្ងៃទៅ ព្រានសត្វស្លាបនោះ មកកាន់ទីជម្រំតាបពួក ដំឡើងលប់ពីលើទីប្រជុំសត្វស្លា ំងនោះដូចគ្រាមុន ។ ។ កាលនោះ តាបមួយនិយាយថា កាលបើអ្នកទូលទំលាយលប់នេះ ពេមក្បាលរបស់អ្នកនឹងរបោចចុះដោយពិត, ឥឡូវចូរអ្នកទូលទំលាយតែម្នាក់ឯងចុះ ។ តាបដទៃឆ្លើយថា កាលបើអ្នកទូលទំលាយលប់នេះ ស្លាបទាំងសងខាងរបស់អ្នកនឹងបាក់ជាមិនខាន ឥឡូវនេះ ចូរអ្នកទូលទំលាយតែម្នាក់ឯងចុះ ។ លុះតាបទាំងពីរពួកនោះដដែកគ្នាថា ចូរអ្នកទូលចុះ ចូរអ្នកទូលចុះ មិនដាច់ស្រេចដូច្នេះ ព្រានសត្វស្លាបក៏ទំលាក់លប់គ្របពីលើមកជាប់ជាមួយគ្នារួចហើយចាប់ដាក់គ្រុកនាំយកទៅកាន់គេហស្ថាន ញុំាងភរិយាឲ្យត្រេកអរក្នុងគ្រានោះឯង ។

ព្រះបរមសាស្ដាបានទ្រង់ត្រាស់ថា "ក្សត្រធំ ។ មិនគួរនឹងធ្វើជំលោះចំពោះក្រុមញាតិ (របស់ខ្លួនឡើយ) ធម្មតាជំលោះនេះ ជាមូលដ្ឋាននៃសេចក្ដីវិនាសពិតប្រាកដ រួចហើយទ្រង់សំដែងធម៌ទេសនាបន្តអនុសន្ធិប្រជុំជាតកថា " តាបពួកអ្នកល្ងង់ទៅ ក្នុងកាលនោះ គឺរូបទេវទត្ត (នេះ)" ឯតាបបណ្ឌិតអ្នកចេះដឹង គឺអង្គតថាគតនេះឯង ។

ចប់សម្មោទមានជាតក ។

## ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរក្រវែង
ឲ្យរីកចម្រើន គង់វង់គត់មត់ ។
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ ។

ប.ព.

# បញ្ហាផ្សាយអក្សរសាស្ត្រនៅបច្ចុប្បន្នកាល

លោក លី-ធាមតេង រៀបរៀង

---

ការកសាងជាតិគ្រប់ផ្នែកគ្រប់វិស័យ ពុំងាយនឹងអស់ហើយ នៅពេលឆាប់ៗ មួយដងមួយគ្រាឡើយ គឺតែងតែជាប់ដឹកបន្តគ្នាជាយូរយារពេលវេលាមិនងាយផុត ។ ហេតុនេះ បញ្ហាកសាងនិងផ្សាយនូវអក្សរសាស្ត្រដែលជាមែកធាងមួយសំខាន់ក្នុងការស្ថាបនាជាតិដែរនោះ ក៏ពុំចេះអស់ហើយនូវបញ្ហាដែលត្រូវតែដោះស្រាយដែរ ។ ក្នុងបច្ចុប្បន្នកាលនេះ ការផ្សាយអក្សរសាស្ត្របានជួបនឹងបញ្ហាសំខាន់ ៣ យ៉ាងគឺ៖

១– ខ្វះអ្នកនិពន្ធ,

២– ពុំទាន់សម្បូណ៌អ្នកអាន,

៣– ពិបាកខាងការបោះពុម្ពផ្សាយ ។

ចំពោះបញ្ហាជាទុបសគ្គទាំងប៉ុន្មាននេះ យើងអាចពិចារណាឃើញនូវមូលហេតុនិងវិធីដោះស្រាយខ្លះៗដូចតទៅ ៖

១- បញ្ហាខ្វះអ្នកឯកទេស· ចំពោះបញ្ហានេះ យើងសញ្ជឹងគិតបន្តិច ក៏យល់បានភ្លាមថា ប្រទេសជាតិយើងទើបតែបានឯករាជ្យបរិបូណ៌ដោយអធិបតេយ្យ ដែលមានរដ្ឋធម្មនុញ្ញបើកសេរីភាពខាងការបញ្ចេញមតិ មានការតែងនិពន្ធបោះពុម្ពផ្សាយស្នាដៃអក្សរសាស្ត្រនេះជាដើម ម៉្លោះហើយ ពីដើមមកអ្នកប្រកបរបរតែងនិពន្ធបោះពុម្ពផ្សាយនេះពុំសម្បូណ៌ទេ បើថាគ្មានផងក៏បាន ព្រោះគេពុំបានប្រទះនឹងអ្នកនិពន្ធណាមានវិជ្ជាជីវៈជាអ្នកនិពន្ធសុទ្ធសាធ ដោយគ្មានប្រកបមុខរបរដទៃទៀតសោះឡើយ ៗ បើមានអ្នកនិពន្ធ ករខ្វះៗនោះ ក៏សុទ្ធតែអស់លោកសប្បុរសចិត្តសរសេរតែងដោយទុត្តមគតិលោកបង្ខំឡើមានៈសរសេរតែងឡើង ចែកជូនដល់ជនរួមជាតិយើងអានជាហូរហែមកប៉ុណ្ណោះ ៗ ឯមតិដែលលោកលាតត្រដាងឡើងក្នុងស្នាដៃរបស់លោក ក៏ពុំសូវហ៊ានបញ្ចេញឲ្យអស់តាមការយល់ផ្ទាល់ខ្លួនដែរ ព្រោះមានច្បាប់នឹងការត្រួតពិនិត្យរបស់បរទេសពុំអនុញ្ញាតឲ្យធ្វើបានតាមចង់ ៗ

លុះមកដល់ពេលដែលប្រទេសជាតិយើងដោះខ្លួនរួចពីអាណាព្យាបាលបរទេសដោយព្រះរាជកិច្ចដឹកនាំដ៏ឈ្លាសវៃ នៃសម្តេចសហជីវិនជាទី

ស្រឡាញ់និងគោរពនៃយើងគ្រប់គ្នា  អ្នកនិពន្ធដែលមានឧត្តមគតិចិញ្ចឹមចិត្តបំណងក្នុងការផ្សាយអក្សរសាស្ត្រនោះ  ក៏មានលេចឈ្មោះលេចនាមឡើងជាច្រើនដូចផ្សិតនៅរដូវភ្លៀងដំបូង  ដើម្បីបំផុសនូវគោលមតិផ្សេងៗដោយវេទនាជាអត្ថបទបែបសិក្សាខ្លះ  បែបប្រលោមលោកខ្លះ ។ ប៉ុន្តែទោះបីជាឃើញមាននាមអ្នកនិពន្ធច្រើនលើសលុបដូច្នេះក៏ដោយ  ក៏គេត្រូវតែសង្កេតចំពោះខ្លឹមសារនៃស្នាដៃរបស់អ្នកនិពន្ធទាំងនោះផង  ព្រោះថា ការចំរើនលូតលាស់ ពុំមែនសំដៅដល់ការកើននូវចំនួនប៉ុណ្ណោះទេ ត្រូវមានគុណភាពល្អប្រពៃថែមទៀត ។ បើសង្កេតត្រង់គុណសម្បត្តិនេះ គេតែងមានយោបល់ថា  ស្នាដៃទាំងនេះពុំបានប្រកបដោយគុណភាពល្អទាំងអស់ឡើយ  ដូច្នេះចំនួនច្រើនក៏ដូចជាតិចដែរ ។ បើយើងដេញដោលតទៅទៀតថា  ហេតុដូចម្ដេចបានជាអ្នកនិពន្ធខ្មែរយើងពុំខិតខំសំ-រិតសំរាំងស្នាដៃខ្លួនឲ្យឆើតឆាយឡើង ?  ឲ្យមានខ្លឹមសារសមទៅតាមវិវឌ្ឍនាការក្នុងលោកឡើង ? ចំពោះសំនួរទាំងនេះ  គេឆ្លើយបានថាៈ

ក- មកពីស្រុកយើងជាស្រុកឯករាជ្យថ្មី  អ្នកនិពន្ធយើងភាគច្រើនទើបតែបានធ្វើសិក្ខាការក្នុងមុខរបរខ្លួនក្នុងរយៈពេលនៅខ្លីនៅឡើយ ។

ខ- ទោះបីស្នាដៃណាល្អពិសិដ្ឋគ្រាន់បើ  ក៏ពុំបានផលក្នុងការផ្សាយល្អប៉ុន្មានដែរ  ព្រោះសៀវភៅនៅស្រុកយើងបោះពុម្ពក្នុងមួយលើកមិនបានលើសពីពីរពាន់ក្បាលផង (ចំពោះប្រលោមលោកធម្មតា ពេលជា

កណ្ដាល) ។ ដូច្នេះ អ្នកនិពន្ធពុំអាចមកផ្ដើមជីវិតខ្លួនលើរបរបោះពុម្ពផ្សាយបានឡើយ ហើយរវល់តែរបរទៅប្រកបមុខងារដទៃ ១ទៀត ពុំមានឱកាសហ៊ឹកហ៊ឺនក្នុងវិជ្ជាជីវៈជាអ្នកនិពន្ធឡើយ ។

គ- ពីដើមមកប្រទេសយើង ពុំមានការសិក្សាអក្សរសាស្ត្រជាតិឲ្យបានជ្រាលជ្រៅ ម្ល៉ោះហើយ អ្នកដែលចេះតែងនិពន្ធក៏មកតែពីទេព-កោសល្យរបស់ខ្លួនប៉ុណ្ណោះ ។

សេចក្ដីបរិយាយមកនេះ បង្ហាញឲ្យឃើញថា បញ្ហាដែលខ្វះអ្នកនិពន្ធនេះ គឺស្ថិតនៅលើគុណភាពពុំមែនលើចំនួនច្រើនតិចទេ បានសេចក្ដីថា ស្នាដៃដែលប្រកបដោយគុណភាពប្រពៃនោះ នៅមានចំនួនតិចនៅឡើយ ។ ដូច្នេះបញ្ហាដែលយើងត្រូវដោះស្រាយតទៅទៀតគឺបញ្ហារិះរកខ្លឹមសារល្អ សំរាប់ការផ្សាយអក្សរសាស្ត្រយើង ជាពិសេសខាងផ្នែកប្រលោមលោក ។

២- បញ្ហាពុំធាន់សម្បូណ៌អ្នកអាន.- ជាការពិតណាស់នៅស្រុកយើង ពិតមែនតែពីដើមមកយើងជាជាតិមានវប្បធម៌ចាស់ចាមបុ-រាណ ប៉ុន្តែជនជាតិយើងច្រើននិយមតែការស្ដាប់ជាជាងការអាន បានន័យថា បើមានអ្នកម្នាក់អានសាស្ត្រាឬនិទានរឿងប្រាកដជាមានមនុស្ស

ច្រើននាក់មកតាមរេមស្ដាប់ ប៉ុន្តែឲ្យអានទាំងអស់គ្នាវិញមិនចូលចិត្ត ឡើយ ៗ ចំលាប់នេះមានរហូតមកដល់សព្វថ្ងៃ ទោះបីជាបានយល់ ហើយថា ការអានជាការប្រពៃមួយខាងបណ្ដុះសតិអារម្មណ៍ក៏ដោយ ៗ បើ ពោលចំពោះប្រលោមលោក មានអ្នកខ្លះបានយល់ខុសថា សៀវភៅ បែបនេះជាគ្រឿងនាំឲ្យខូចចិត្តខូចគំនិតទៅវិញ ហើយបានសំគាល់ក្នុង ចិត្តទាំងពោលប្រាប់គ្នីគ្នាថា កុំឲ្យអានសៀវភៅបែបនេះទៀត ៗ បើតាមពិត យើងសូមរំលឹកថា រឿងប្រលោមលោកទាំងអស់ពុំមែនសុទ្ធតែជារឿងខូច រឿងអាក្រក់ទេ ដូច្នេះគួរតែនិយមពិនិត្យលើរឿងក៏ទាំងនោះសិនមុននឹង វិនិច្ឆ័យថា រឿងនោះយ៉ាងណា ១ ៗ ប្រសិនជាឃើញថារឿងនោះអាក្រក់ ក៏បោះបង់ចោលទៅ តែបើឃើញថាជារឿងល្អវិញក៏គួរតែណែនាំគ្នីគ្នា អានដើម្បីដកស្រង់យកបញ្ហាខ្លះ ៗ ក្នុងរឿងនោះមកធ្វើជាបទពិចារណាក្នុង ដំណើរជីវិតយើង ព្រោះថារឿងប្រលោមលោក សុទ្ធសឹងជារឿងសម្ដែង ពីការរស់នៅធម្មតារបស់មនុស្ស ៗ បានសេចក្ដីថា បើមនុស្សរស់នៅមាន បញ្ហាអ្វី ប្រលោមលោកក៏ត្រូវមានបញ្ហានោះដែរ ដ្បិតតួរឿងក៏ជាមនុស្ស, មនុស្សធម្មតា ក៏សុទ្ធតែជាតួរឿងក្នុងប្រលោមលោកដែរ ឧទាហរណ៍ ដូចជា អ្នកដើរលេងមុខរាំង គឺជាតួសម្ដែងរឿងដើរកំសាន្ត, អស់លោក អ្នកកំពុងអានសៀវភៅ គឺជាតួសម្ដែងរឿងមនុស្សសិក្សាអានសៀវភៅ

។ល។ ម្យ៉ាងទៀតគួរដកចិត្តពីការយល់ច្រឡំថា "ប្រលោមលោក គឺជារឿងលួងលោមចិត្តមនុស្សឲ្យត្រេកក្នុងកាម" នោះចោលចេញ ហើយគប្បីយល់ថា "ប្រលោមលោក គឺជារឿងនិទានពីមនុស្សកំពុងជួបបញ្ហាក្នុងកាមកិលេស ហើយរិះរកវិធីដោះស្រាយឲ្យរួចពីកាមកិលេសទាំងនោះ" ដូច្នេះវិញ ។

៣- បញ្ហាពិបាកខាងការបោះពុម្ពផ្សាយ .- គ្រប់បញ្ហានេះ ស្ថិតនៅលើសម្ភារៈទាំងស្រុង ព្រោះប្រទេសយើងជាប្រទេសឯករាជ្យថ្មី ដែលពីមុនមកពុំមែនសម្បូណ៌ដោយឧស្សាហកម្ម ជាពិសេសឧស្សាហកម្មខាងរោងពុម្ពបោះផ្សាយនេះឯង ។ លុះប្រទេសយើងបានឯករាជ្យឡើង យើងក៏ចាប់មានកសាងរោងពុម្ពជាហូរហែមក ប៉ុន្តែសម្ភារៈសំរាប់ប្រើក្នុងនេះ ដូចជាម៉ាស៊ីនបោះអក្សរ, តួអក្សរ, ទឹកខ្មៅពុម្ព, ក្រដាស,... ពីមុនមក សុទ្ធតែទិញមកពីប្រទេសក្រៅទាំងអស់ តែសព្វថ្ងៃយើងស្រាយបានខ្លះ ដូចជាមានរោងចក្រធ្វើក្រដាស នៅស្រុកយើងជាដើម ។ ដោយសារសម្ភារៈរោងពុម្ពមានតម្លៃច្រើន ព្រោះសុទ្ធតែជារបស់នាំមកពីបរទេស ហើយការបោះពុម្ពសៀវភៅយើង ១ លើក ១ មានចំនួនតិចក្បាល ជាហេតុនាំឲ្យចុះសោហ៊ុយក្នុងការរៀបអក្សរពុម្ព ដូច្នេះហើយបានជាសោហ៊ុយបោះពុម្ពសៀវភៅនៅស្រុកយើងមានកំរិតខ្ពស់ នាំ

ឲ្យពិបាកដល់អ្នកមានប្រាក់កាសតិចតួច ពុំអាចទិញសៀវភៅអានបានឡើយ ។

ចំពោះបញ្ហាជាខសំខាន់ទាំង ៣ ដូចពោលមកខាងលើនេះ មានបច្ច័យទាក់ទងគ្នាជានិច្ច បើដោះស្រាយតែមួយ ៗ ដាច់ពីគ្នាពុំបានឡើយ តោងតែដោះទាំងបីព្រមគ្នាទើបទៅរួច ។ ព្រោះថាបើយើងម្នាក់ ៗ ស្ថិតនៅខាងបញ្ហាមួយដាច់គ្នា ហើយយើងតាំងសំនួរនោះ ច្បាស់ជាការបកស្រាយសំនួរនោះនឹងត្រឡប់មកវិញជាពុំខាន ។ ឧបមាថា បើយើងជាអ្នកនិពន្ធ យើងស្រែកថា " ខ្ញុំប្រកបរបរជាអ្នកនិពន្ធពុំរស់ទេ ព្រោះអ្នកអានមានចំនួនតិចណាស់ ! " ។ បើយើងជាអ្នកអាន យើងនឹងស្រែកឆ្លើយថា " ខ្ញុំចង់អានដែរ តែសៀវភៅទាំងនោះមិនទាន់មានខ្លឹមសារល្អ ហើយលក់ថ្លៃ ៗ ណាស់ " ។ បើយើងជាអ្នកបោះពុម្ព យើងនឹងឆ្លើយតបមកទៀតថា " មិនឲ្យខ្ញុំយកតម្លៃច្រើនយ៉ាងណាបាន បើសម្ភារៈខ្ញុំមានតម្លៃច្រើន ៗ ណាស់ ហើយអ្នកបោះពុម្ព ៗ មានចំនួនតិចក្បាលពេក បើអ្នកបោះពុម្ព ៗ រាប់ហ្មឺនក្បាលទៅ ខ្ញុំនឹងយកថោកបំផុត" ។ ហើយអ្នកនិពន្ធនឹងស្រែកបន្តទៀតថា " ឲ្យខ្ញុំបោះច្រើន ៗ យ៉ាងណាបាន

បើអ្នកអានខ្មែរមានតិចណាស់" ។ ដូចឧទាហរណ៍មកនេះ នាំឲ្យយើងឃើញថា បញ្ហានេះជាប់ទាក់ទងគ្នាប្រាកដមែន ។ ដូច្នេះ គួរយើងផ្ចង់ចិត្ត រកវិធីដោះស្រាយព្រមគ្នានូវខទាំងបីដូចខាងក្រោមនេះ៖

១- អ្នកនិពន្ធយើងគប្បីហ្វឹកហ្វឺនខ្លួនដើម្បីសរសេរតែងសៀវភៅផ្សេងៗឲ្យរឹងរឹតតែមានខ្លឹមសារវិសេសវិសាលឡើង ។

២- អ្នកអានគួរតែខំព្យាយាមអាន និងណែនាំគ្នីគ្នាឲ្យស្គាល់ច្បាស់នូវតម្លៃនិងប្រយោជន៍នៃការអានសៀវភៅ ដែលនៅប្រទេសគេ គេចាត់ទុកដូចជាចំណីអាហារ និងខានអាស្រ័យពុំបានឡើយ ។

៣- គប្បីរៀបរយយ៉ាងណា ឲ្យមានអ្នកនិយមអានសៀវភៅកើនច្រើនឡើង ដើម្បីឲ្យបានការបោះពុម្ពកើនចំនួនច្រើនឡើង និងឲ្យចុះនូវតម្លៃសៀវភៅនោះវិញ ព្រមទាំងបង្កបង្កើតឲ្យសម្បូណ៌នូវសម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការងារនេះ ដោយមានជាផលិតកម្មនៅក្នុងស្រុកយើងផ្ទាល់ផង ។

## ពាក្យខ្មែរប្រែចេញពីបរទេស

# ដោយគណៈកម្មការជាតិនៃការសិក្សា ផ្នែកអក្សរ "ក"

---

*ក្នុងខែនេះ គណៈកម្មការវប្បធម៌ផ្នែកអក្សរ "ក" បានប្រជុំពិភាក្សា ហើយបានសម្រេចយកជាបានការ នូវពាក្យដូចខាងក្រោមនេះ ៖*

| | | |
|---|---|---|
| Alinéa | *n.m.* | វគ្គៈ សង្កាត់នៃសេចក្ដី ពីបន្ទាត់លូកមួយទៅទល់នឹងបន្ទាត់លូកមួយ ។ |
| Appliquer la peine | | អនុវត្តទោស |
| Autochtone | *adj.* | រដ្ឋិកសី |
| Condamné | *n.m.* | ទណ្ឌិត |
| Condamner | *v.* | ដាក់ទណ្ឌកម្ម |
| Concussion | *n.f.* | វិតក្រម : បទល្មើសរបស់អ្នករាជការដែលបង្គាប់ ឬ បង្ខិតបង្ខំឲ្យទារ ឬ ក៏ទទួលនូវវត្ថុដែលខ្លួនបានដឹងថា គេមិនជំពាក់ក្នុងមុខពន្ធអាករ ប្រាក់ខែ ។ល។ |
| Corruption passive | | សំណូកអកម្ម : បទល្មើសរបស់អ្នករាជការ ដែលទទួលជំនូន ឬ កិច្ចប្ដេជ្ញា ដើម្បីបំពេញ ឬ មិនបំពេញ កិច្ចណាមួយក្នុងមុខងាររបស់ខ្លួន ក្រៅអំពីបៀវត្សរ៍ ទោះបីកិច្ចនោះ ធ្វើដោយយុត្តិធម៌ក៏ដោយ ។ |
| Corruption active | | សំណូកសកម្ម : បទល្មើសរបស់ជនណាមួយ ដែលសូកអ្នករាជការឲ្យធ្វើ ឬ មិនឲ្យធ្វើនូវកិច្ចការណាមួយ ជាមុខងាររបស់អ្នករាជការនោះ ដើម្បីជាប្រយោជន៍ដល់ខ្លួន ។ |

*(នៅមានត)*

ព្រះមហា ចាំង . ទាត់ រៀបរៀង

( តមក )

អតិភាហន ឧបុំ. កិរិយានាំទៅក្រៃលែង, ភារៈក្រៃលែង ។

អតិភាហ្យ ឧបុំ. កិរិយានាំទៅក្រៃលែង, កិរិយាកន្ទុងទៅក្រៃលែង, (យប់), កិរិយានៅភលំព្រឹក ។

អតិវិក្រម គុ. ដែលក្លៀវក្លាក្រៃលែង ។

អតិវិក្សិប ធាតុ. យកក្រៃពេក (ន្ធ) ។

អតិវិគប៊ិ គុ. ដែលឥតថ្លៃក្រៃលែង, ដែលមិនមានប្រយោជន៍សោះ ។ – វាច៊ គុ. ដែលពោលឥតថ្លៃក្រៃលែង, ដែលកុហកក្រៃពេក ។

អតិវិទ្ធ គុ. ដែលមុតក្រៃពេក, ដែលត្រូវរបួសហើយ ។

អតិវិធុរ គុ. ដែលទុក្ខគួរអាសូរក្រៃពេក ។

អតិវិបយ៌យ បុំ. សេចក្ដីខុសយ៉ាងក្រៃលែង ។

អតិវិបន គុ. ដែលមានព្រៃក្រៃពេក ។

អតិវិប្រកម៌ បុំ. ការឆ្ងាយក្រៃលែង ។

(នៅមានទៀត)

# រឿងសាមកុក

## កណ្ឌទី ៤៧

ទុកញ៉ាវិបុលកជសេនា ឆ្វ-ការ ង ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកភាងវៃឆ្លាសបើបានអាន
ទឹងបេះទហ៊ាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ

យូរ-អ៊ុន

នាងស៊ុនហ៊ូយិនឮដូច្នោះខឹងណាស់ ក៏ជេរប្រទេចជីវយីថា អាចោរកំណាចមិនមានសេចក្ដីកតញ្ញូសោះ វាមកនៅក្នុងស្រុកកាំងតាំងនេះ បានស៊ុបាយផឹកទឹកបងអញ ។ ក៏បានតាំងវាឲ្យធ្វើជានាយទាហានធំ ហើយចិញ្ចឹមគ្រៀមិនឲ្យរៈមោះហ្មង , គួរប្ដូវាមិនដឹងគុណខុសត្រូវ ឡើងពីជាមាព្រះចៅហៀនគេ ម្ដាយអញនឹងស៊ុនគួន ក៏បានលើកអញឲ្យធ្វើកិរិយាទៀត កាលឡើងពីដឹកនាំអញមកនេះ ម្ដាយអញនឹងស៊ុនគួនក៏បានព្រមអនុញ្ញាតឲ្យអញមក ជីវយីយល់ថា អញបានរបស់ទ្រព្យសព្វគ្រប់មកច្រើនឬ? បានជាប្រើឯងតាំងពីរនាក់ឲ្យលើកទាហានចន្ទំធ្វើចោរមកប្លន់ដណ្ដើមសម្បត្តិរបស់អញ ។

ឈឹសេង, គេងហ៊នត្រូវដូច្នោះ ក៏ខ្លាចខ្លួនក្រែងមានសេចក្ដីខុសឡើង ទើបឆ្លើយថា ខ្ញុំបាទទាំង ២ នាក់នេះ មិនបានគិតប្រទូសរ៉ាយអ្នកកំទេ ព្រោះខ្លាចអាជ្ញាដីវឃីប្រើ បានជាលើកទាហានមក អ្នកប្រមេក្ដាលើកទោសខ្ញុំបាទទាំងពីរចុះ ។ នាងស៊ុនហ៊ូយ៉ិនក៏ស្រែកគំហកថា ដីវឃីមានអាជ្ញាសិទ្ធិឲ្យសម្លាប់បាន ។ ជាខ្លួនធ្វើតាម ឯខ្លួនយើងនឹងសម្លាប់ខ្លួនវិញមិនបានឬ បានជាមកពាលោធ្វើការដូច្នេះ នាងស៊ុនហ៊ូយ៉ិនក៏ជេរប្រទេចដីវឃីជាច្រើនណាស់ ហើយក៏បង្ខំចររថស្រូតទៅ ទៀវតិនឹងជូឡុងក៏លើកទាហានតាមពីក្រោយ ។

ឯឈឹសេង, គេងហ៊នខ្លាចនាងស៊ុនហ៊ូយ៉ិន ក្រឡេកឃើញជូឡុងជានាយទាហាន មានថ្វីដៃនៅពីក្រោយទៀវតិ ក៏មិនអាចធ្វើប្រការម្ដេចឲ្យទាហានវែកបើកផ្លូវទៅ កាលទៀវតិទៅឆ្ងាយហើយ ចម្ងាយផ្លូវប្រហែល ៦០ សិន (២៤គ.ម.) ឃើញតាន់ប៊ូនឹងកូជៀងលើកតាមទៀវតិមកដល់ទីនោះ ឈឹសេង, គេងហ៊នក៏អធិប្បាយរ៉ាយរឿងឲ្យតាន់ប៊ូ,កូជៀងស្ដាប់ ។ តាន់ប៊ូថា អ្នកបណ្ដោយឲ្យទៀវតិទៅរួចនោះខុសណាស់ហើយ ឥឡូវ ស៊ុនគួនប្រើខ្ញុំទាំងពីរ មកចាប់ទៀវតិនឹងនាងស៊ុនហ៊ូយ៉ិនឲ្យបាននាំទៅវិញ ។ ឈឹសេង, គេងហ៊នត្រូវដូច្នោះក៏ក័យស្លុតលើកទាហានរត់តាមទៅទាំង ២ កងជាមួយគ្នា ។

ឯទៀវតិ បានឮសំឡេងទាហានស្រែកហ៊ោពីក្រោយ ក៏និយាយនឹង

នាងស៊ិនហ៊ុយអ៊ិនថា ឥឡូវទាហានតាមមកទៀតហើយ យើងនឹងគិតប្រការម្ដេច? ។ នាងស៊ិនហ៊ុយអ៊ិនថា អ្នកខំស្រូតទៅមុនចុះ ខ្ញុំនឹងជូឡុងនៅតទល់ពីក្រោយ ។ ឡៅពីនឹងទាហាន ៣០០ ក៏ស្រូតទៅតាមមាត់ទន្លេ ជូឡុងក៏ឲ្យទាហានឈរផ្តុំគ្នាកណ្ដាលផ្លូវ ឯខ្លួនជូឡុងក៏បរសេះកាន់លំពែងឈរអមថែនាងស៊ិនហ៊ុយអ៊ិន ទទួលទាហានទាំង ៤ នាយ លើកតាមមកទាន់ ក៏ចុះពីលើសេះចូលទៅគំនាប់នាងស៊ិនហ៊ុយអ៊ិន ។ ក៏សួរតើនប៊ូ, ភូជៀងថា ខ្លួនគិតតាមមកនេះ ដោយគិតប្រាថ្នាការដូចម្ដេច ? ។ តើនប៊ូ, ភូជៀងឆ្លើយថា ស៊ិនគួនប្រើខ្ញុំបាទឲ្យតាមមកអញ្ជើញអ្នកនឹងឡៅភីទៅវិញ ។

នាងស៊ិនហ៊ុយអ៊ិនឮដូច្នោះ ក៏ធ្វើជាខឹងក្រេវក្រោធស្រែកគំហកថា ព្រោះមនុស្សពួកនេះទេតើ រាំធ្វើឲ្យយើងបងប្អូនខុសអធ្យាស្រ័យចិត្តនឹងគ្នា មាតាយើងនឹងស៊ិនគួន ក៏បានរៀបការយើងនឹងឡៅពី ឲ្យជាស្វាមីភរិយា កាលយើងនឹងឡៅភីមកនេះ ក៏បានលាមាតា ។ ព្រមឲ្យយើងទៅនៅស្រុកកេងជីវជាមួយនឹងស្វាមីយើងហើយ យើងមិនមែនលបរត់មកតាមអំពើចិត្តឯងក៏ទេ ស្ម័ស៊ិនគួនជាបងយើងក៏គង់និយាយអនុលោមយល់ព្រមតាមទំលាប់ទំនៀមយកចិត្តយើងខ្លះ តែខ្លួន ២ នាក់នេះឯង បង្អាប់ស៊ិនគួនឲ្យលើកទាហានមកប៉ងនឹងធ្វើអន្តរាយយើងឬ ? ។

នាយទាហាន ៤ នាក់ ឮដូច្នោះក៏គិតថា នាងស៊ិនហ៊ុយអ៊ិន នឹងស៊ិនគួនជាបងប្អូននឹងគ្នា នាងធំគុកថៃជាមាតាស្រឡាញ់ស្មើជីវិត បើយើង

នឹងធ្វើបំពានគ្រានេះទៅ ស៊ិនគួនដែលមានចិត្តកតញ្ញូដឹងគុណមាតាមិនអាចនឹងទទឹងទាស់ចិត្តមាតាបាន យើងក៏នឹងមានទោសខុស ព្រោះស៊ិន-គួនខ្លាចមាតាណាស់ គង់នឹងក្រឡាស់យកឲ្យរួចខ្លួន សេចក្តីខុសក៏នឹងផ្ទួនធ្លាក់មកលើយើងកល់គ្នា បើយើងធ្វើសេចក្តីគាប់ប្រសើរទុកនឹងល្អជាងយូរទៅក៏មិនមានសេចក្តីសុខ ហើយក៏មិនឃើញឡៀពីក្នុងគ្រានេះសោះ ចំពោះឃើញតែដូច្នេះ នឹងនាងស៊ិនហ៊ួយ៉ិន ឯដូច្នេះក៏ជិះសេះកាន់លំពែងចេញអាការយ៉ាងមាំមួនបំផុតនឹងចូលសង្គ្រាម នាយទាហាន ៤ នាក់គិតត្រូវគំនិតគ្នាដូច្នោះ ទាំងអស់គ្នាក៏ឱនគំនាប់ ហើយបើកឲ្យនាងស៊ិនហ៊ួយ៉ិននឹងដូច្នេះចេញទៅ ។

នាងស៊ិនហ៊ួយ៉ិនក៏បង្គំទាហានឲ្យបររថតាមទៅទាន់ឡៀពី ។ ឈើសេងក៏និយាយនឹងទាហានទាំងពួងថា ឥឡូវនាងស៊ិនហ៊ួយ៉ិនក៏ទៅហួសទៅហើយ យើងនឹងវិលទៅវិញ គេនឹងយកសេចក្តីអ្វីទៅនិយាយ មានតែយកពាក្យដែលនាងស៊ិនហ៊ួយ៉ិនថានោះ ទៅប្រាប់ដីរយើចុះមិនជាអ្វីទេ ប្រឹក្សាគ្នាក៏មិនចុះរុះទទួលដីរឃឹម, ដីរថាយមកដល់ ក៏សួរនាយទាហានទាំង ៤ ថា អ្នកកល់គ្នាបានជួបប្រទះនឹងឡៀពីឬទេ? ។ នាយទាហានទាំង ៤ នាក់ឆ្លើយថា ជួបប្រទះពីព្រឹក ឥឡូវឡៀពីលើកស្រុករូតទៅហួសហើយ ដីរ-ឃឹមថា អ្នកកល់គ្នាបានជួបប្រទះនឹងឡៀពីហើយ ហេតុម្តេចមិនចាប់ខ្លួនឲ្យបាន គ៏ទប៊ូ នឹងកូដៀងក៏អធិប្បាយរាយរឿងឲ្យដីរឃឹមស្តាប់ ។ ដីរឃឹម

ថា អ្នកកល់គ្នាគិតវៃអែងវាចនាងស៊ិនហ៊ួយ៉េន មិនបានចាប់ខ្លួនទៀតពីចុក នោះមុខជាមានទោសខុសជាទម្ងន់ណាស់ហើយ បើស៊ិនគួនគិតស្រឡាញ់ នាងស៊ិនហ៊ួយ៉េនជាប្អូន ហើយនឹងអារម្មណ៍វាចមាតាជាប្រាកដ កាល ណានឹងប្រគល់ត្រាសិទ្ធិនេះមកឲ្យយើងបង្គាប់យើងថា បើជួបប្រទះ នឹងទៀតពីនៅទីណា ត្រូវឲ្យប្រហារជីវិតនាងស៊ិនហ៊ួយ៉េនជាមុន រួចសឹម សម្លាប់ទៀតពីជាក្រោយ ហើយឲ្យកាត់យកក្បាលទាំង ២ នាក់យកទៅ ឲ្យបាន បើមិនបានក្បាលអ្នកទាំង ២ ទៅឲ្យស៊ិនគួនទេ ស៊ិនគួននឹងឲ្យ កាត់ក្បាលយើងជាជំនួសវិញ ។

នាយទាហានទាំង ៤ នាក់ឮដូច្នោះ ក៏ភ័យតក់ស្លុតឆ្លើយថា ឥឡូវ ទៀតពីលើកទៅជាយូរហើយ យើងនឹងគិតយ៉ាងម្ដេចទើបស្រួល។ ដីវយើម ប្រាប់ទៅឈីសេង, គេងហងថា ទៀតពីលើកទៅនោះសុទ្ធតែទាហាន ដើរជើង ទោះដូចម្ដេចក៏ស្ទុះរត់ពីយើងមិនផុត ឲ្យអ្នកទាំងពីរស្រូតទៅប្រាប់ ដីវយីឲ្យលើកទាហានទូកយ៉ាងរហ័សទៅចាំស្ទាក់នៅផ្លូវមាត់ទន្លេខ្លួនយើង បួននាក់នឹងពួកទាហានក៏ស្រូតលើកពីខាងណោះ ទៅតាមផ្លូវគោកឲ្យខាង តែទាន់ មួងនេះបើនាងស៊ិនហ៊ួយ៉េននឹងទៀតពីនិយាយយ៉ាងណាក៏ពុំត្រូវ ជឿស្ដាប់ ត្រូវតែចាប់កាត់ក្បាលឲ្យខាងតែបាន ឈីសេង, គេងហងស្ដាប់ យល់ឃើញថាត្រូវ ក៏នាំគ្នាស្រូតរូតទៅប្រាប់ដីវយីឯស្រុកធសងគុណា ដីវយើម, ដីវថាយ, តីងប៉ូ, គូជៀងក៏ជញកងទ័ពស្រូតរូតប្រញាប់ទៅ ។

ឯឡៅពីនឹងនាងស៊ុនហ៊ួយិន នាំគ្នាទៅផុតដែនស្រុកធសង់គុណ ហើយក៏ចុះទៅដល់មាត់ទន្លេកន្លែង ១ ឈ្មោះតំបន់ឡៅឡុងថៃ ឡៅពីក៏នាំពាហនៈរកមើលក្បែរមាត់កំពង់ ដើម្បីនឹងរកទូកឆ្លងទៅស្រុកកេងជីវ ក៏មិនឃើញមានទូកឆ្លងទៅមកសោះ ឡៅពីកើតព្រួយវិតក្កណាស់ ជូ-ឡុងក៏និយាយនឹងឡៅពីថា យើងមកដល់ទីនេះផុតដែនស្រុកធសង់គុណហើយ ចូលមកជាប់ដែនស្រុកកេងជីវ បីដូចជាខ្លារួចពីទ្រុង លោកកុំវិតក្កពេកឡើយ យើងធ្វើសង្គ្រាមសម្រេចមកពល់គ្រា ក៏ដោយសារគម្រោះខុងបេងរិះគិត ឥឡូវយើងមកដល់ដីតស្រុកហើយ មុខជាខុងបេងដឹងនឹងគិតឡើជាស្រេចមិនបាច់ព្រួយរវល់ប៉ុន្មាន ឡៅពីស្ដាប់ជូឡុងនិយាយក៏គិតដល់សេចក្ដីលំបាកព្រួយដោយទុក្ខមកតាមផ្លូវ ហើយក៏នឹកដល់សេចក្ដីសុខសម្រាន្ដដែលស៊ុនគួនបានទំនុកបំរុងក្នុងស្រុកគងនី ឡៅពីក៏អង្គុយសោកការណិតអនាថខ្លួននៅមាត់កំពង់ ទទួលឮសំឡេងពាហនសេះលើកតាមមកជាច្រើន ក៏ប្រឹក្សានឹងជូឡុងថា គ្រានេះពាហនសេះលើកតាមមកច្រើនណាស់ មុខជាយើងដល់នូវសេចក្ដីស្លាប់ក្នុងគ្រានេះហើយ ជូឡុងក៏មិនទាន់នឹងឆ្លើយតបថាម្ដេច ទទួលក្រឡេកទៅឃើញទូកប្រហែល ២០ ថែវ មកតាមមាត់ទន្លេ ជូឡុងក៏ថា បុណ្យរបស់យើងដល់ហើយបានជាមានទូកមកដល់ សុំឲ្យលោកស្រួតប្រញាប់ដេញពាហនចុះដោយសារទូកនេះចុះ ឆ្លងទៅឲ្យរួចពីភ័យអន្ដរាយ ។

លុះទូកនោះចូលមកដល់ជិត ឡៅតី ពះគ្រោះមើលឃើញជាទូកអ្នកជំនួញ ក្រឡេកមើលទៅទៀតក៏ឃើញខុនបេងពាក់អាវនឹងមួកចេញមកពីក្នុងដំបូល ឡៅតីក៏អរណាស់នឹងប្រៀបពុំបាន ទើបនាំនាងស៊ុនហ៊ូយិននូវបណ្ដាទាហានលោតឡើងលើទូកនោះគ្រប់គ្នា ខុនបេងឃើញឡៅតីភ័យភិត ក៏អស់សំណើចហើយថា តាំងពីខ្ញុំចាត់ទាហានបន្ទំជាទូក អ្នកជំនួញមកចាំទទួលលោកក៏យូរណាស់ហើយ ឡៅតីឮដូច្នោះក៏ដេញទា-ហានឲ្យថយទូកផុតពីមាត់ច្រាំងទៅដល់កណ្ដាលទន្លេ ទទួលជីវឃឹម, ជីវ-ថាយ, ត័នប៊ូ, កូជៀង:លើកទាហានមកដល់មាត់ទន្លេ ។

ខុនបេងសើចចំអកហើយលើកដៃចង្អុលទៅថា នែអស់អ្នកពល់គ្នាចូរត្រឡប់វិលទៅប្រាប់ជីវយីជានាយខ្លួនចុះថា យើងបណ្ដោយឲ្យជីវយីនឹងស៊ុនគួនធ្វើកលល្បាយមកច្រើនគ្រាហើយ យើងក៏ទទួលតាមកលមកដល់ថ្ងៃនេះ ការកើសម្រេចមកខាងយើងទាំងអស់ ដែលជីវយីនឹងស៊ុនគួនមានចិត្តសប្បុរសលើកនាងស៊ុនហ៊ូយិនឲ្យជាភរិយាឡៅតី ហើយថែមឲ្យអស់អ្នកពល់គ្នាលើកគ្នាមកតាមជូនដំណើរឡៅតីទៀតនោះ យើងក៏គាប់ចិត្តណាស់ឡៅតីមិនមានភ័យអន្តរាយអ្វីទេ កុំឲ្យជីវយីគិតកលល្បាយអ្វីទៅទៀតឡើយ ពួកទាហានទាំងនោះឮហើយ ក៏យកធ្នូបាញ់បម្រុះទៅដូចគ្រាប់ភ្លៀង ព្រួញក៏ស្រុះទៅមិនដល់ ។ ខុនបេងក៏បង្គំឲ្យទាហានចែវទូកធ្វេងទៅត្រើយខាងនាយ ជិតទៅមាត់ច្រាំង ។

ឯដីវយីដែលដឹងសេចក្ដីដោយឈីសេង, គេងហងទៅប្រាប់ ក៏ប្រញាប់លើកទ័ពទូកឲ្យអ៊ុយកាយជាប៉ែកស្ដាំ, ហ័នគុនជាប៉ែកឆ្វេង ខ្លួនដីវយីជាទ័ពល្បួងស្រួតលើកតាមទៀតពីទៅ ដីវយីឃើញទៀតពីធ្ងន់ទៅដល់ត្រើយខាងណោះ ហើយក៏ដេញទាហានថៃវទូកទៅឲ្យទាន់ ខុងបេងឃើញដីវយីដេញត្រសុកចូលមក ក៏ឲ្យទាហានចតទូកឡើងប្រាំងខាងជើងនាំទៀតពីទីងនាងស៊ុនហ៊ូយិនឡើងគោករត់ទៅ ដីវយីក៏ជិះសេះនាំអ៊ុយកាយ, ហ័នគុង, ឈីសេង, គេងហង, នឹងទាហានទាំងពួងលើកតាមទៅ ៗ

ឯខុងបេងនឹងទៀតពីរត់ទៅដល់ភ្នំ កួងដៃនដំបន់អង់ដីវដែលឲ្យគួនអ៊ូបង្កប់ទាហាននៅទីនោះ ក៏នាំទៀតពីទីងនាងស៊ុនហ៊ូយិនឡើងទៅលើកំពូលភ្នំ លុះឃើញដីវយីលើកតាមទៅដល់ភ្នំនោះ គួនអ៊ូនឹងអ៊ុយអៀន, ហាងគុង, ក៏លើកទាហានចេញស្ទាក់ពីមុខ ដីវយីនឹងដេញទាហានចូលច្បាំងនឹងគួនអ៊ូក៏ទឹកញញើតខ្លាច ព្រោះទាហានខ្លួនចំណាន់តែខាងជើងទឹក មិនប៉ិនប្រសប់ច្បាំងខាងផ្លូវគោក ហើយក៏គ្មានសេះជិះគ្រប់គ្នា ដីវ-យីក៏ថយទាហានត្រឡប់ក្រោយទៅវិញ គួនអ៊ូក៏ដេញចាក់កាប់សម្លាប់ទាហានដីវយីស្លាប់អស់ជាច្រើន ហ័គគុងនឹងអ៊ុយកាយក៏ចូលប្រយុទ្ធគ្នា ដីវយីក៏ម្មានាំទាហានចុះទូកបាន គួនអ៊ូក៏លើកទាហានតាមទៅដល់មាត់កំពង់ ក៏ឲ្យទាហានស្រែកឲ្យដីវយីថា អ្នកឯងប្រើកលៗបាយបញ្ឆោតយើង ៗ ក៏ដឹងដល់ស្គាល់គំនិតអ្នកឯងទាំងអស់ ឥឡូវអ្នកឯងចាញ់កល

យើងវិញ ថែមទាំងលើកទាហានមកជូនដំណើរទ័ពឲ្យខូចខាតទាហានទៅទៀត គំនិតអ្នកឯងយ៉ាងនេះឬ ដែលនឹងបង្ក្រាបផែនដីតទៅ! ។

ដាវយើឮដូច្នោះ ក៏ក្រឡេកមើលទៅលើឃើញទ័ពពីទីងនាងស៊ុនហ៊ូយិនឡូវពួកស្រីបំរើនៅលើកំពូលភ្នំ ក៏ទឹកខឹងក្តៅក្នុងចិត្តខ្លាំងណាស់ ទើបបង្គាប់ទាហានឲ្យឡើងទៅច្បាំងទៀត ។ ហាន់គុងនឹងអ៊ុយកាយក៏និយាយឃាត់ថា ទាហានយើងគ្មានសេះជិះសោះ ទាហានខាងនោះគេសុទ្ធតែជិះសេះគ្រប់ខ្លួន យើងតស៊ូនឹងគួនអ៊ូមិនបានទេ ។ ដាវយើយល់ឃើញត្រូវ ក៏គិតតែក្នុងចិត្តថា យើងគិតកលឧបាយឲ្យស៊ុនគួនធ្វើគ្រានេះ ប៉ងនឹងចាប់ខ្លួនតាយេកស្រុកកេងជីវឲ្យបាន ក៏ថែមឲ្យវិនាសខូចខាតរបស់ឥតអំពើសោះ យើងនឹងត្រឡប់ទៅស្រុកតង់ង៉ីមើលមុខស៊ុនគួនក៏មិនពេញភ្នែក ដាវយើគិតក្តៅក្លួលរំជួលចិត្តស្ទើរនឹងបែកទ្រូងរហែកជា ២ ឯពិសព្រួញដែលជ្រួតជ្រាបទៅក្នុងឥន្ទ្រីយពីមុននោះ ក៏កំរើកពេកពិសឲ្យជួលសន្លប់ទៅមិនដឹងស្មារតី ពួកទាហានក៏ភិតភ័យច្របូលច្របល់ នាំគ្នាកែខែកោសខ្យល់ឲ្យដាវយើដឹងខ្លួនឡើងវិញ ហើយក៏លើកទាហានត្រឡប់ទៅស្រុកធសង់គុណ ។

ខណៈនោះ ខុងបេងក៏នាំទ័ពត្រឡប់ទៅស្រុកកេងជីវ ហើយក៏បែកបំណាច់រង្វាន់ពួកសេនាទាហានតាមសមគួរ ។ ឯដាវយើម, ដាវថាយ, ត័នបួ, កួជៀង ក៏លើកទាហានទៅស្រុកឡាំស៊ុ លុះទៅដល់ហើយក៏នាំគ្នាចូលទៅពណ៌នារឿងរ៉ាវជំរាបស៊ុនគួនគ្រប់ប្រការ ។ ស៊ុនគួនឮដូច្នោះក៏ខឹង

ណាស់ ទើបចាត់ទៀតោជាមេទ័ពគិតលើកទៅវាយស្រុកកេងជីវ ខទួល ជីវយើឲ្យនាំសំបុត្រមកដល់ស៊ុនគួនសេចក្ដីថា ដែលខ្ញុំបាទបានរិះគិតកល ទុបាយត្រានេះ ព្រោះគំនិតនឹងតម្រេះប្រាជ្ញាខ្ញុំបេងខ្លស់ជាងខ្ញុំបាទ បាន ជាខូចការអស្សារទៅ ទោសខ្ញុំបាទក៏ខុសណាស់ទៅហើយ វេលានេះខ្ញុំ បាទនឹងសុំទាហានលោកលើកទៅវាយយកស្រុកកេងជីវឲ្យត្រាតែបាន ជា ទីសងសឹកវិញ ។

ស៊ុនគួនឃើញសំបុត្រដូច្នេះ ក៏ឲ្យកេណ្ឌទាហានលើកទៅដោយខ្លួន ឯង ។ ទៀវជៀវក៏និយាយហាមឃាត់ថា លោកនឹងលើកទ័ពទៅវាយយក ស្រុកកេងជីវគ្រានេះ ឲ្យរិះគិតពិគ្រោះមើលកលការឲ្យស្រួលបួលសិន ព្រោះចូឆូបកដ៏យនឹងយើងបែកទ័ពទៅគ្រានេះ ក៏នៅរិះចងចិត្តគិតអាឃាត ព្យាបាទមិនសោយទេ តែដោយសារវាឃើញថា លោកនឹងឡៅពីសព្វ ថ្ងៃប្រាស្រ័យរាក់ទាក់គ្នាជាចិត្តមួយ វាក៏នៅព្រួយមិនអាចនឹងលើកទ័ពមក ច្បាំង វេលានេះ បើវាយល់ដឹងថា លោកលើកទ័ពទៅវាយស្រុកកេង ជីវហើយ កាលណាឡើយចូឆូនឹងមិនលើកទ័ពមកព្រួតវាយយកស្រុកកាំង តាំងខាងណេះ ព្រោះវាឃើញថា លោកនឹងឡៅពីបែកចិត្តពីគ្នា គ្រា ក្រោយនេះយើងក៏នឹងទប់ទល់ដោយយកម្រណាស់ ។

កោះយ៉ុងនិយាយទឹងស៊ុនគួនឡើងទៀតថា សព្វថ្ងៃចូឆូបានប្រើ មនុស្សមកល្បួមស្ដាប់ការជាដរាប បើឃើញថា លោកនឹងឡៅពីបែកចិត្ត

ពីគ្នាហើយ ចូច្ចូគង់នឹងប្រើកលទៅល្បួងឡៀតពី ។ ខ្លាចយើងលើកទៅវាយ
យកស្រុក ក៏ប្រមុខទៅចូលនឹងចូច្ចូមិនខាន បើចូច្ចូបានឡៀតពីជាពួក
មួយហើយ ក៏គង់នឹងរួមគំនិតគិតការអ៊ូវ ត្រូវគ្នាទាំងអស់ អំណើះតទៅ
ស្រុកកាំងតាំងនេះក៏នឹងអន្តរាយវិនាសជាមិនខាន គំនិតខ្ញុំបាទយល់ដោយ
ស្មានថា បើលោកធ្វើចុតហ្មាយចូលទៅក្រាបបង្គំទូលព្រះចៅហៀនតេ
ឲ្យតាំងឡៀតពីជាចៅហ្វាយស្រុកកេងជីវពេញទីតែម្តង ប្រហែលស្រួល
ជាជាង ព្រោះចូច្ចូកំឃើញថា លោកទឹងឡៀតពីត្រូវគ្នាជាខ្នងមួយចិត្តមួយ
ហើយ កាលណាឡើយវាទឹងលើកទ័ពមកច្បាំងនឹងយើងទៀត ១ ទៀត
ឡៀតពីក៏មិនមានគំនួចខឹងអ៊ូទឹងលោកសោះ រួចអំពីនោះសឹមយើងរិះរក
ឧបាយទៅនិយាយបញ្ចោតឲ្យឡៀតពីទឹងចូច្ចូខុសអធ្យាស្រ័យគ្នាវិញ គង់តែ
អ្នកទាំងពីរនេះមិញទឹងតតាំងច្បាំងគ្នាឡើង យើងក៏ត្រូវលើកទ័ពទៅវាយ
ខ្ទប់យកស្រុកកេងជីវឃើញទឹងបានដោយងាយ ស៊ុនគួនស្តាប់និយាយ
ក៏គិតឃើញត្រូវ ទើបសួរគោះយ៉ុងថា អ្នកសំឡឹងមើលទៅឃើញនរណា
ដែលគួរនឹងប្រើឲ្យកាន់ចុតហ្មាយ ទៅថ្វាយដល់ស្រុកហ៊ូតោបាន គោះ
យ៉ុងថា ឃើញតែហ៊ូហ៊ុមមួយនោះ មានតម្រេះប្រាជ្ញាវាងវៃណាស់
ចូច្ចូក៏ធ្លាប់ជួបប្រទះស្គាល់ពប់កនគ្នាមកពីដើម ។ ស៊ុនគួនយល់ត្រូវ ក៏ឲ្យធ្វើ
ចុតហ្មាយតាមពាក្យគោះយ៉ុងនិយាយ ។ លុះធ្វើរួចក៏ប្រគស្រោមប្រគល់ឲ្យ
ហ៊ូហ៊ុម ៗ ក៏លាចេញទៅស្រុកហ៊ូតោ ទទួលចូច្ចូនាំនាម៉ុនមុខមន្ត្រីខ្ញុំកជ.

ការទៅស្វែងរែងឯស្រុកនៀបគុន ហ៊ួហ៊ុំមក៏ស្រែកតាមទៅ ៗ

ឯចូឆូនោះ តាំងពីបែកទ័ពទឹកខូចខាតទ្រព្យរបស់ស្បៀងអាហារទឹងសេនាទាហាន ក៏មានសេចក្ដីអប្បយសអៀនខ្មាស ចេះតែរិះគិតគំនុំគំគួននៅមិនដាច់ តែឃើញថា ស៊ុនគួនទឹងឡៅពីនៅធ្វើការរួបរួមយកចិត្តគ្នា ក៏មិនអាចនឹងលើកកងទ័ពមកច្បាំងយកស្រុកតាំងតាំងនោះ ៗ លុះព្រះចៅហៀនតេសោយរាជ្យសម្បត្តិបាន ១៦ ឆ្នាំ ជារដូវទេសកាលគិម្ហន្ត ៗ ចូឆូក៏នាំស្រីស្នំបរិវារទូវបណ្ដានាម៉ឺនសព្វមុខមន្ត្រីទៅមើលប្រាសាទ "តង់សេកតៃ" ដែលកសាងថ្មីនៅក្បែរមាត់ទន្លេដៀងហោ ចូឆូក៏តាក់តែងរៀបខ្លួនប្រាណពាក់អាវខៀវពាក់មួកមាសឡើងអង្គុយលើប្រាសាទ ឯបណ្ដានាម៉ឺនសព្វមុខមន្ត្រីទឹងសេនាទាហានក៏ឈរជាសង្កាត់គ្នានៅក្បែរប្រាសាទ ចូឆូគិតចង់មើលថ្វីដៃទាហាន ក៏ឲ្យយកសំពត់ព្រៃក្រហមយ៉ាងល្អទៅចងពាក់លើមែកឈើថ្ងាន់ ហើយឲ្យយក (វង់បាញ់) វង់ខ្មៅទៅដោតទុកនៅចំមុខប្រាសាទចម្ងាយ ២៥ ព្យាម ឲ្យទាហានតែងខ្លួនជាពីរពួក ទាហានណាសែជាមួយនឹងចូឆូ ៗ ឲ្យស្លៀកពាក់ពណ៌ក្រហមមួកក្រហម ទាហានក្រៅពីនោះឲ្យស្លៀកពាក់ពណ៌ខៀវមួកខៀវ ឈររៀងគ្នាត្រង់មុខប្រាសាទហើយបង្គាប់ថា បើអ្នកបាញ់ត្រូវ (វង់បាញ់) ត្រង់វង់ខ្មៅយើងនឹងឲ្យបំណាច់រង្វាន់អាវ ១ បើបាញ់មិនត្រូវ យើងនឹងឲ្យផឹកទឹក ១ ពែង ៗ

ពួកទាហានក៏រៀបគ្នាឡើងជិះសេះ ចោហ៊ីវពាក់អាវក្រហមមួក

ក្រហមបរសេះវង់វិលចេញទៅមុខតាហានបាន ៣ ជុំ ហើយយិតធ្នូបាញ់ត្រូវត្រង់វង់ខ្មៅ តាហានទាំងពួងក៏វាយគង ឃ្មោះស្គរហោកញ្ជ្រៀវអឺងកង ចូធូមានចិត្តត្រេកអរណាស់ថា មិនបង្ស្រៀតដែលតោហ៊ុំជាសែលោហិតនឹងយើង ហើយស្រែកបង្គាប់តាហានឲ្យទៅយកអាវមកឲ្យតោហ៊ុំ ខណៈនោះ ប៊ុនផេងនាយតាហានក៏បំផាយសេះចេញមកនិយាយនឹងចូធូថា លោកកុំអាលយកអាវឲ្យតោហ៊ុំសិន ហើយប៊ុនផេងក៏យិតធ្នូបាញ់ត្រូវត្រង់វង់ខ្មៅទៀត តាហានទាំងពួងក៏ស្រែកហោអឺងកងឡើងទៀត ។

ប៊ុនផេងស្រែកថា តាហានទៅយកអាវមកឲ្យយើង តោហង់ឃើញដូច្នោះក៏បំផាយសេះចេញមកទៀត ស្រែកប្រាប់ប៊ុនផេងថា អ្នកកុំអាលទៅដណ្ដើមកយកអាវនោះឡើយ យើងនឹងបាញ់ឲ្យល្អជាងអ្នកទៅទៀត តោហង់ក៏យិតធ្នូបាញ់ទៅត្រូវត្រង់វង់ខ្មៅ ព្រួញក៏ដោតសៀតគ្នានឹងព្រួញមុន ទៀវខាប់ឃើញដូច្នោះក៏ថា ដែលអ្នកទាំង ៣ បាញ់ធ្នូមុននោះមិនវិសេសដូចយើងទេ ទៀវខាប់ក៏ដាក់ខ្លួនលើកធ្នូបាញ់ទៅ ព្រួញដោតជាប់ជិតព្រួញមុនជា ៤ ជ្រុងស្មើគ្នា, ហៃហ្វូអៀន ពាក់អាវក្រហមមកបញ្ឈរសេះនៅមុខតាហាន ឃើញដូច្នោះ ក៏យិតធ្នូបាញ់ប្រែក្រោយទៅត្រូវចន្លោះព្រួញ ៤ ដែលជាប់មុន ក៏ស្រែកថា យើងបាញ់ប៉ុកជាងអ្នកកល់គ្នា ហើយក៏បំផាយសេះរូលនឹងដណ្ដើមយកកដ្យ ។

ស៊ីឡុងស្រែកថា អ្នកទាំង ៤ បាញ់ត្រូវតែវង់ខ្មៅ ហើយនឹងយកអាវនោះមិនគួរទេ ខ្ញុំនឹងបាញ់ឲ្យប្លែកជាងអ្នករាល់គ្នាទៅទៀត ហើយស៊ីឡុង ក៏យឹតធ្នូបាញ់ទៅត្រូវមែកច្បាស់ដែលពាក់អាវនោះ ដាច់ធ្លាក់អាវចុះមក ស៊ីឡុងក៏បំផាយសេះទៅយកអាវនោះពាក់ត្រឡប់មកគំនាប់ចូឆូ ទាហានទាំងពួងឃើញដូច្នោះក៏ស្រែកសរសើរស៊ីឡុងថា ប៉ុនបាញ់ធ្នូនឹងរកអ្នកឯណាស្មើគ្មាន ស៊ីឡុងក៏បរសេះចេញមក ខៅធូរឃើញដូច្នោះក៏ស្រែកឲ្យស៊ីឡុងថា អ្នកកុំអាលយកអាវនោះ ត្រូវទុកឲ្យយើងវិញ ស៊ីឡុងថា អាវនេះយើងបាញ់ត្រូវហើយ ត្រូវបានមកយើង ។ មិនត្រូវឲ្យអ្នកទេ ខៅធូឮដូច្នោះក៏មិនឆ្លើយតប បំផាយសេះចូលទៅដណ្តើមយកអាវ ស៊ីឡុងក៏យកដងធ្នូវាត់ទៅត្រូវខៅធូ ១ ក៏យកដៃចាប់បានកន្ត្រាក់មកនឹងឲ្យស៊ីឡុងធ្លាក់ពីលើសេះ ស៊ីឡុងលែងធ្នូលោតចុះពីលើសេះ ខៅធូក៏ចុះពីលើសេះដូចគ្នា ទាំង ២ នាក់ក៏ចំបាប់ដណ្តើមយកអាវទាល់តែអាវនោះដាច់រហែកទៅទាំងអស់ ។

ចូឆូឃើញស៊ីឡុងនឹងខៅធូចំបាប់គ្នា ដោយទោះសោទៅវិញទៅមកទាំងសងខាងដូច្នោះ ក៏ឲ្យទាហានស្ទុះទៅហាមឃាត់ចាប់ទាញចេញពីគ្នា ហើយហៅឲ្យឡើងមកលើប្រាសាទ ឯខៅធូនឹងស៊ីឡុងក៏គគ្រឹតធ្មេញធ្វើអាការបីដូចនឹងចូលតស៊ូគ្នាទៀត ចូឆូក៏អស់សំណើចថា អ្នកទាំង ២ ជាទាហានមានថ្វីដៃស្មើគ្នា ហើយមកធ្វើឲ្យទាស់ទែងគ្នាពីព្រោះអាវ ១ ដូច្នេះ

មិនគួរសោះ ចូឆូក៏ហៅទាំងអស់ឡើងមកលើប្រាសាទ ចែកស្រាច្រើន ចែកឲ្យម្នាក់ ១ ផាប់ ហើយក៏ឲ្យរៀបតុលៀងអាហារគ្រប់គ្នា ចូឆូថា យើងមកលេងគ្រានេះ មានសេចក្ដីសប្បាយណាស់ ព្រោះបានឃើញថ្វីដៃទា-ហានផ្សេងៗ ហើយក៏និយាយនឹងទាហានទាំងពួងថា អ្នកកល់គ្នាសុទ្ធតែជាអ្នកមានតម្រិះប្រាជ្ញាមានបណ្ដាស័ក្តិ ត្រូវឲ្យតែងពាក្យកាព្យឃ្លោងសរសើរប្រាសាទថ្មីនេះ ដើម្បីឲ្យសប្បាយចិត្ត ។

នាម៉ឺនទាំងពួង ក៏ទទួលប្រសាសន៍ចូឆូ គឺៈ អងឡ្យង ១ ចុងហ៊ីវ ១ អងចិន ១ ត័នលឹម ១ ក៏តែងពាក្យកាព្យឃ្លោង ១ បទម្នាក់ សេចក្ដីថា :

វីមហាទបកដអាចជាធំ យើងគេនិយមព្រមចេតនា
លើកលោកឲ្យខ្ពស់ពេញយសា ដូចមហាក្សត្រាផុតផែនដី ។
បានទាំងប្រាបប្រាមសង្គ្រាមសឹក ហាត់ហ៊ឹកសកលពលសេនីយ
ប្រឡងជ័យជាញឲ្យឃើញថ្មី ពេញពិតឫទ្ធិល្បីក្រៃអស្ចារ្យ ។
ទីប្រាង្គដែលសាងឡើងខ្ពង់ខ្ពស់ ក៏ពុំស្មើឈ្មោះយសស័ក្ដា
គួរសាងឡើងទៀតសុទ្ធសិលា ហៅមហាមណីនិវេសន៍វដ្ឋ ។
ឲ្យមានបាំងតាំងបល្ល័ង្កពេជ្រ រំលេចក្បាច់ក្បាំងកំងកដវតិ
ទើបសមជាទីមហាចក្រព័ត្តិ គ្រប់គ្រងក្នុងកទ្ធសីមាអើយ ។

លុះតែងហើយ ក៏ជូនទៅឲ្យចូឆូ ។ ទទួលកាព្យនោះមកហើយក៏ថា កាព្យនេះល្អប្រពៃណាស់ តែអ្នកសរសើរលើសណាស់ កាលពីដើម

យើងក៏ជាមនុស្សប្រាជ្ញាតិច ប្តេជ្ញាចិត្តគិតកាន់តែសេចក្តីស័ត្យពិតត្រង់ជាទីតាំង លុះដល់គ្រាព្រះចៅហៀនគេបានសោយរាជសម្បត្តិ ផែនដីក៏កើតវិប្បរិតផ្សេង ៗ យើងក៏បានសង់គ្រឹហាឋានទៅក្រៅស្រុកទៅគុណខាងទិសឯកើត ចម្ងាយពីស្រុកទៅផ្លូវប្រហែល ៤០០ សិន លុះដល់គិម្ហរដូវនិងវស្សន្តរដូវ យើងក៏ទៅមើលទំលាប់ទំនៀមផ្សេង ៗ លុះដល់ហេមន្ត-រដូវ យើងក៏ទៅស្វែងបាញ់សត្វលេងក្នុងចិត្តគិតថា បើផែនដីសុខរាបទាបហើយ នឹងចង់ចូលធ្វើរាជការជានាម៉ឺនខ្ញុំផែនដីមិនបានដឹងថា ព្រះចៅហៀនគេ នឹងចំពោះឲ្យយើងជានាយទាហានដូច្នេះសោះ ឥឡូវនេះយើងក៏មានចិត្តកតញ្ញូនឹងព្រះមហាក្សត្រ គិតតែនឹងប្រាប់ប្រាមសឹកសត្រូវឲ្យផែនដីរាបទាបជាសុខថ្វាយប៉ុណ្ណោះ ចំពោះយកតែសេចក្តីគាប់ប្រសើរតទៅមុខ ឲ្យរន្ទឺឮថា យើងជានាយទាហាន បានជួយទំនុកបំរុងផែនដីនៃព្រះចៅហៀនគេ វេលានេះក៏ឃើញថា ល្មមសមគួរតាមតម្រេះគិតខ្វះមកហើយ ព្រោះយើងបានប្រាប់ប្រាមកំចាត់សត្រូវរាជសម្បត្តិចេញជាច្រើន តាំងពីកាលគ្រាទៀវកុក ពួកចោរជួតក្បាលលឿងនោះ ដរាបមកដល់សព្វថ្ងៃនេះ ព្រះចៅហៀនគេក៏ប្រោសតាំងយើងជាមហាឧបរាជធំជាងនាម៉ឺនទាំងពួង ហើយយើងនឹងបានគិតយកយសស័ក្តិឲ្យលើសជាងនេះទៅទៀតក៏ទេ តែយើងនៅរិះគិតថា បានជួយទំនុកបំរុងផែនដីហើយ

ក៏ត្រូវធ្វើឲ្យហូតតទៅ មួយទៀតផែនដីព្រះចៅហៀនតេនេះ បើកុំបានយើង គង់នឹងមានមនុស្សកំណាចមកតាំងខ្លួនជាស្ដេចគ្រប់ដំបន់មិនខាន ឯមនុស្សដែលគ្មានគម្រេះប្រាជ្ញាក៏មិនមានគិតដល់គុណូបការយើងឲ្យឃើញថា យើងបានជាធំនឹងបង្អាប់បញ្ញាអ៊ីក៏ជាកម្មសិទ្ធិ នៅតែគិតសង្ស័យថាយើងដូច្នេះដូច្នោះក៏ខុសទទេទៅ មិនត្រូវសោះឡើយ ម្ល៉ោះហើយខ្ញុំក៏តាញ់ក័យខ្លួនឯង សព្វថ្ងៃនេះយើងក៏តាំងចិត្តគិតធ្វើរាជការតបស្នងសងព្រះតេជព្រះគុណព្រះចៅហៀនតេដោយសុចរិត គិតតែក្ក្រាយមួយយ៉ាងទៀតថា ចង់នឹងលើកទីមហាឧបរាជនេះ ឲ្យដល់ព្រះញាតិវង្សពង្សព្រះ-ចៅហៀនតេ ក៏មិនបានឃើញរូបណានឹងចេះដឹងល្អមនឹងជួយទំនុកបំរុងផែនដីបាន បើឃើញមិនចេះស្មានលើកឲ្យទៅតែម្ដងក៏គង់នឹងនាំឲ្យសៅ-ហ្មងខូចផ្លូវរាជការ ដំណើរទៅមុខខ្លួនយើងនឹងក្ស័យបានទុក្ខក្ដៅក្រហាយជាមួយគ្នាដែលយើងថាដូច្នេះ ជាសេចក្ដីពិត មិនមែនគិតថា តែមាត់ក្រៅនោះទេ អ្នកទាំងពួងមិនទាន់ដឹងចិត្តយើងទេឬ? បើមិនដឹងហើយក៏នឹងសំគាល់ថា យើងយកតែពាក្យល្អមកចរចា ៗ

នាម៉ឺនទាំងអស់គ្នាគំនាប់ហើយថា គំនិតរបស់មហាឧបរាជដែលទំនុកបំរុងផែនដីគ្រានេះ ល្អប្រសើរជាង អ៊ុអ៊ិន នឹងដាវគង់ ដែលជួយទំនុកបំរុងផែនដីនៃព្រះចៅសេងថង់នឹងព្រះចៅសេងហង់នោះទៅទៀត ។ ចូធូញ

ដូច្នោះ  ក៏រឹតតែកំរើកចិត្តផឹកស្រាជាច្រើនពែង ហើយយកពិតនឹងត្រដាស មកទឹងសរសេរឃ្លាង ៗ ទទួលបំរើស៊ិនគួន ឈ្មោះហ៊ួហ៊ុមនាំសំបុត្រមកដល់ជូនទៅចូច្ច សេចក្ដីថា ឲ្យក្រាបទូលព្រះចៅហៀនតេ ព្រោះឡៅពីនៅស្រុកកេងជីវរ៉ាយបានអាណាខេត្តជាចំណុះច្រើនដំបន់ហើយ  ឥឡូវស៊ិនគួនបានលើកប្អូនស្រីឲ្យជាភរិយាឡៅពី  សុំឲ្យតាំងឡៅពីពេញទីជាចៅហ្វាយស្រុកកេងជីវ  ចូច្ចឃើញសេចក្ដីសំបុត្រដូច្នោះក៏តក់ស្លុតស្មារតី ដៃដែលកាន់ពិតក៏របូតធ្លាក់ចុះ  គៀយ៉ុកឃើញដូច្នោះក៏សួរថា  មហាឧប-រាជចូលក្នុងទីពិជ័យសង្គ្រាមប្រថុយស្លាប់អាយុជីវិតដូចមិនមានគិតគិតភ័យបារម្ភប៉ុន្មាន ថ្ងៃនេះគ្រាន់តែឮពត៌មានមកប៉ុណ្ណោះ ក៏របេះជ្រុះពិតធ្លាក់ពីដៃ សេចក្ដីប៉ុណ្ណោះ តើនឹងយ៉ាងម្ដេចទៅ ៗ ចូច្ចថា ឡៅពីនោះឧបមាដូចមករធ្លាប់នៅក្នុងទឹកត្រពាំងបឹងបួតាំងពីកំណើត  មិនធ្លាប់ស្គាល់ទឹកជ្រៅសោះ ហើយវេលានេះ ទៅបានចុះក្នុងទឹកនពមហាសមុទ្រដ៏ជ្រៅពន្លឹក  ដូចជាឡៅពីបានស្រុកកេងជីវ  ក៏រឹតតែមានកម្លាំងក្លៀវក្លាឡើង  ដូចមករនោះឯង  អំណើះតទៅមុខ  មុខជាយើងនឹងមានព្រួយដោយកំចាត់ឡៅពីពុំបានតាមប្រាថ្នាដោយអាការដូច្នេះ  បានជាយើងតក់ស្លុតក្នុងចិត្ត ៗ

(នៅមានត)

# រឿងព្រេងចិន

លោក ភ៉ាយ.ប៊ុតា ប្រែរៀបរៀង

(តមក)

គ្រានោះ ព្រះអង្គម្ចាស់ទ្រង់យាងចូលទៅក្នុងហ្វូងមហាជន ហើយងាកព្រះសិរទតទៅលើនភាល័យដូចអ្នកដទៃទាំងពួង, តែទ្រង់មិនឃើញអ្វីសោះឡើយ ទ្រង់សួរអ្នកដែលស្ថិតនៅជិតថា: តើអ្នកឯងមើលអ្វី? ។ អ្នកនោះមុននឹងតបឆ្លើយ, ក៏បានពិនិត្យពិច័យបុកពានឹងអាកប្បកិរិយាព្រះអង្គម្ចាស់យ៉ាងហ្មត់ចត់ហើយពោលថា:

"ព្រះអង្គម្ចាស់ក្សត្រីនៃយើង ជាព្រះរាជធីតាមួយព្រះអង្គ មានព្រះរូបឆោមស្រស់ប្រិមប្រិយប្រកបដោយព្រះឆវីវណ្ណល្អក្រៃពេក ។ ចំណែកព្រះមហាក្សត្ររបស់យើង, ព្រះអង្គមានព្រះរាជហឫទ័យស្រឡាញ់ព្រះរាជបុត្រីខ្លាំងណាស់ មិនឲ្យអ្នកណាក្រៅពីព្រះអង្គឃើញព្រះរាជបុត្រីនោះសោះឡើយ, ដោយខ្លាចក្រែងមានមនុស្សចូលមកឃើញព្រះរាជបុត្រីព្រះអង្គក្នុងព្រះបរមរាជវាំង, ក៏បានត្រាស់បង្គាប់ឲ្យមេជាងយ៉ាងជំនាញម្នាក់សាងព្រះដំណាក់មួយនៅលើអាកាស ។ ព្រះអង្គម្ចាស់ក្សត្រីទ្រង់គង់នៅក្នុងព្រះដំណាក់តែមួយព្រះអង្គឯង, រាល់ៗថ្ងៃ ក្រោយដែលទ្រង់បានបង្ហើយព្រះរាជភារកិច្ចក្នុងព្រះរាជអាណាចក្ររួចហើយ ព្រះរាជារបស់

យើងស្តេចយាងទៅកាន់ព្រះរាជដំណាក់នៃព្រះអង្គម្ចាស់ក្សត្រី, ពេលនេះព្រះអង្គយាងទៅទីនោះហើយ, ប៉ុន្តែស្តេចនឹងយាងត្រឡប់មកវិញក្នុងពេលឆាប់ៗនេះ, យើងទាំងអស់គ្នានៅទីនេះរង់ចាំទទួលព្រះអង្គ" ។

គ្រានោះ ព្រះអង្គម្ចាស់ទ្រង់មានព្រះបន្ទូលសួរថា: "គេសាងព្រះដំណាក់ព្រះនាងយ៉ាងណា បានជានៅលើមេឃឯណោះ?" ។ អ្នកនោះក៏ក្រាបបង្គំទូលថា: "ព្រះដំណាក់ព្រះនាងគឺ ទេវតាសាង មានតែព្រះមហាក្សត្រិយតែមួយព្រះអង្គប៉ុណ្ណោះ ដែលទ្រង់មានព្រះសិទ្ធិយាងទៅកាន់ព្រះដំណាក់នោះបាន" ។

ព្រះអង្គម្ចាស់ ទ្រង់បានកត់សំគាល់នូវពត៌មានដោយសព្វគ្រប់ដែលបុរសនោះក្រាបបង្គំទូល, លុះពេលសន្ធ្យាកាលត្រី ទ្រង់បានគង់លើអស្សេះហោះទៅកាន់ប្រាសាទព្រះនាង ដែលមានរស្មីភ្លឺទ្វាលព្រាលឆ្អៅល្អអស្ចារ្យ, លុះយាងដល់ខ្លោងទ្វារធំដែលចូលទៅមហាប្រាសាទ, ទ្រង់ចុះពីលើអស្សេះ ហើយចូលទៅក្នុងមហាប្រាសាទ ។

គ្រានោះព្រះរាជធីតាទ្រង់ទតទៅឃើញមនុស្សដើរចូលមកក្នុងមហាប្រាសាទ ស្មានថាព្រះវរបិតា, តែពិនិត្យពិច័យហ្មត់ចត់ នូវបុរសដែលដើរនោះ ព្រះនាងក៏ទ្រង់ឈ្វេងយល់ថា បុរសនេះមិនមែនព្រះវរបិតារបស់អញទេ, ប្រហែលជាទេវតាហើយ មនុស្សសាមញ្ញមិនអាចមក

ដល់ទីនេះទេ ។ ក្សាមនោះ ព្រះនាងដ៏មានព្រះកាយស្រស់បំព្រង ដូចនាងទេពធីតា ទ្រង់យាងចេញពីក្រឡាព្រះបន្ទំទៅសួរបុរសដែលដើរចូលមកនោះដោយគារវភក្តិយ៉ាងក្រៃលែង ។ ឯព្រះអង្គម្ចាស់គ្រាន់តែទោលព្រះនេត្រទតទៅយល់ព្រះនាងក្សាម ក្នុងព្រះហឫទ័យព្រះអង្គ ក៏ពុះពោរដោយសេចក្ដីស្នេហាយ៉ាងរំភើបក្រៃលែង ទ្រង់ព្រះតម្រិះថា៖ " ឱ! ធ្វើម្ដេចបានព្រះនាងជាព្រះទេពី! " ។ ចំណែកខាង ព្រះរាជធីតាវិញ កាលបើទតទៅយល់ព្រះអង្គម្ចាស់ហើយ ព្រះនាងទ្រង់មានព្រះហឫទ័យរំជើបរំជួលខ្លាំងណាស់ដែរ ដោយឃើញសម្រស់ព្រះកាយរបស់ព្រះអង្គម្ចាស់មានលក្ខណៈប្លែកពីជនសាមញ្ញ ។ ស្រាប់តែមួយរំពេចនោះ ព្រះនាងទ្រង់ភាក់អន់ព្រះហឫទ័យជាខ្លាំងចំពោះព្រះវរបិតា ដោយទ្រង់ព្រះតម្រិះថា ព្រះបិតាបានបង្ខាំងអញ ឲ្យនៅក្នុងមហាប្រាសាទតែម្នាក់ឯង មនុស្សគ្រប់រូបសុទ្ធតែគ្រូវការដោយសេចក្ដីស្នេហាទាំងអស់ ។ ក្រោយដែលព្រះអង្គម្ចាស់ទ្រង់ធ្វើសន្ធនាការ អស់កាលដ៏យូរបន្តិចមក ព្រះនាងទ្រង់សំដែងនូវព្រះរាជបំណងចំពោះព្រះអង្គម្ចាស់ ហើយទ្រង់ក៏សម្រេចនូវសមគ្គសំវាសទៅតាមព្រះរាជបំណង ។

លុះព្រះអរុណរះឡើង ព្រះអង្គម្ចាស់ ទ្រង់យាងចេញពីមហាប្រាសាទ គង់លើអស្សតរហោះមកចុះជិតគោជនីយដ្ឋានខាងក្រោម ។

តាមធម្មតា ព្រះមហាក្សត្រិយអង្គនេះ កាលបើស្តេចយាងទៅកាន់មហា-ប្រាសាទព្រះរាជបុត្រីហើយ ទ្រង់បានយកព្រះរាជបុត្រីទៅថ្លឹងនឹងជញ្ជីង ព្រោះព្រះអង្គទ្រង់ជ្រាបថា បើនារីណាមានបុរសមកនៅរួម, នារីនោះនឹងឡើងទម្ងន់ជាមិនខាន ។ ពេលថ្លឹង ព្រះអង្គទ្រង់បានទតទៅឃើញថា ព្រះរាជធីតាព្រះអង្គមានទម្ងន់លើស ២ លីត្រ (១ លីត្រតាមធម្មតាកន្ទះគីឡូក្រាម, ១ លិត្រអង់គ្លេសមាន ០គ.ក. ៤៥៣) ។ ព្រះមហា-ក្សត្រទ្រង់បើកព្រះនេត្រធំ ហើយមានព្រះកាយញាំញ័រប្រប់ ទ្រង់ព្រះពិ-រោធយ៉ាងខ្លាំង, រួចទ្រង់ព្រះតម្រិះថា " ប្រហែលជាមានហេតុអ្វីហើយ " ហើយស្តេចយាងវិលត្រឡប់ទៅកាន់ព្រះបរមរាជវាំងវិញ ដោយប្រញាប់ប្រញាល់យ៉ាងក្រៃលែង ។ ពួករដ្ឋមន្ត្រីបានឃើញព្រះមហាក្សត្រិយទ្រង់មិនសប្បាយព្រះរាជហឫទ័យ ក៏ក្រាបបង្គំទូលសួរព្រះអង្គចំពោះរឿងនេះ ។ ព្រះអង្គទ្រង់ប្រាប់រដ្ឋមន្ត្រីឲ្យដឹងនូវពត៌មានសព្វគ្រប់ ។

ព្រះរាជាទ្រង់មានព្រះរាជបន្ទូលសួរសីហនាទថា: " តើមានបុរសណាអាចហ៊ានឡើងមកកាន់មហាប្រាសាទនេះក្រៅពីអញ ! ចូរលោករដ្ឋ-មន្ត្រីទាំងឡាយជួយរិះរកនូវមធ្យោបាយ ដើម្បីនឹងចាប់នូវបុរសក្លាហាននេះឲ្យបាន " ។

គ្រានោះ មានរដ្ឋមន្ត្រីម្នាក់ បានក្រាបបង្គំទូលថា: " នៅក្នុងព្រះ

កដសាណាចក្រយើងនេះ មានយោធា ៤ នាក់ធ្លាប់មានថ្វីដៃ បើតាមទូល ព្រះបង្គំជាខ្ញុំយល់ថា គួរល្អែងចូលព្រះបាទ ត្រាស់បង្គាប់ឲ្យយោធា ៤ នាក់នោះ ទៅយាមគ្រប់ទិសទាំងបួននៃមហាប្រាសាទព្រះនាង បើឃើញ បុរសណាមួយចូលមក ត្រូវចាប់បុរសនោះយកមកថ្វាយព្រះអង្គ" ។

ព្រះមហាក្សត្រិយទ្រង់មានព្រះយោបល់ស្របតាមថា: "យោបល់ លោកវជ្ជមន្ត្រីនេះសមម្យេណាស់, គួរយកមកអនុវត្តក្នុងពេលនេះ" ។ លុះដល់សាយណ្ហសម័យ , ព្រះមហាក្សត្រិយស្តេចនាំពួកយោធាទាំង ៤ នាក់ យាងទៅកាន់មហាប្រាសាទព្រះរាជបុត្រី ហើយទ្រង់ដាក់ឲ្យ យាមមហាប្រាសាទនោះគ្រប់ទិសទាំងបួន ហើយស្តេចយាងត្រឡប់ មកកាន់ព្រះបរមរាជវាំងវិញ ។ ឯពួកយោធាទាំង ៤ នាក់ជាអ្នកល្មោភ ខាងដេក ដល់ពេលព្រះអង្គម្ចាស់យាងចូលមកជួបនឹងព្រះនាង, ពួកយោ-ធានោះក៏ដេកលក់ឥតដឹងអ្វីទេ ។ ព្រះអង្គម្ចាស់ទ្រង់យាងចូលទៅក្នុង មហាប្រាសាទផ្ទុំជាមួយព្រះនាងរហូតដល់បច្ចូសសម័យ ។ លុះព្រះមហា-ក្សត្រស្តេចយាងមកកាន់មហាប្រាសាទព្រះនាង, ទ្រង់មានព្រះរាជហឫ-ទ័យក្រេវក្រោធជាខ្លាំង ដោយទ្រង់យកព្រះនាងទៅថ្វីង, ស្រាប់តែព្រះ នាងមានទម្ងន់ដល់ទៅប្រាំប័លិត្រ លើសពីកាលថ្លឹងម្សិលមិញទៅទៀត ។ ដំណើរអកុសលនេះ បានឮទៅពាសពេញ, មានអ្នកនគរពោលពាក្យ

ខ្សឹបខ្សៀវគ្នាអំពីរឿងនេះ ។ ព្រះកដាទ្រង់មានព្រះកដហប្ញទ័យអៀនអន់ឥតឧបមា ហើយទ្រង់ស្ទើរមិនហ៊ានចេញពីព្រះបរមរាជវាំង, ទ្រង់ត្រាស់បង្គាប់ឲ្យអញ្ជើញលោករដ្ឋមន្ត្រីមួយរូបទៀតមកប្រឹក្សានឹងព្រះអង្គ ។

លោករដ្ឋមន្ត្រីនេះក្រាបបង្គំទូលថា : " សូមល្អងធូលីព្រះបាទត្រាស់បង្គាប់ឲ្យលាបព្រះខែនសយនា, ព្រះសុវណ្ណកោច្ចៈព្រះនាង នូវប្រេងស្អិតពណ៌ខ្មៅ ។ ដល់ពេលស្អែក, ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នានឹងដែកគេពិនិត្យឲ្យហ្មត់ចត់នូវមនុស្សទាំងឡាយក្នុងរាជធានី ។ បើឃើញមនុស្សណាមានប្រឡាក់ដោយប្រេងស្អិតខ្មៅនេះ, មនុស្សនោះគឺជាអ្នកប្រព្រឹត្តបទឧក្រិដ្ឋនោះហើយ ។

ព្រះមហាក្សត្រទ្រង់ក៏ធ្វើតាមលោករដ្ឋមន្ត្រីនេះ ទ្រង់ត្រាស់បង្គាប់ឲ្យយកប្រេងខ្មៅស្អិតទៅលាបក្រឡាព្រះបន្ទំ, ព្រះសុវណ្ណកោច្ចៈ...។ល។ ព្រះនាង ។ ឯព្រះអង្គម្ចាស់ទ្រង់ស្តេចយាងទៅកាន់មហាប្រាសាទព្រះនាងទៀត ។ ដល់ព្រះអង្គម្ចាស់ទ្រង់ចេញពីមហាប្រាសាទពេលព្រឹក, ទ្រង់បានទតឃើញថា ព្រះពស្ត្ររបស់ព្រះអង្គមានប្រឡាក់ដោយប្រេងស្អិតខ្មៅ ។ ទ្រង់ក៏ផ្លាស់គ្រឿងទ្រង់នោះ ដែលមានដាំគជខ្យងនឹងត្បូងជាច្រើន គ្រវែងចោលតាមបង្អួចនោះទៅ ។

(នៅមានត)

ទំនៀមទម្លាប់ នៃខេមរជាតិ
ខ្មែរគួរថ្នឹងឃ្នាត សិក្សាពេញទី ។
ព្រោះខេមរជាតិ ជាជាតិសោភី
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។

ប.ត

## រឿងព្រេងប្រាជ្ញសុភាសិត ៤ បទ:

១- ឃ្លានទំអត់ ៣- គេឲ្យច្រើនកុំយក

២- ខ្វត់ទំរក ៤- ខ្លាចឲ្យចូលជិត

( តចប់ )

បុរសនោះ គិតចូលទៅបរិភោគបាយសំណល់ពីយក្ស តែគិតឃើញថា គួរអញរកបាយថ្មីទៀតទើបគួរ, ឥឡូវ ខ្សែ-ដំបង-កន្ទ្រង់បក់-ពោយ នៅក្នុងកណ្ដាប់ដៃអញហើយ គួរអញសាកល្បងមើល តើពូកែយ៉ាងណាទៅ, គិតស្រេចហើយ ក៏និយាយទៅកាន់កន្ទ្រង់ថា "ចូរឯងទៅយកបាយដ៏ឆ្ងាញ់មកឲ្យអញ" ។ មួយសន្ទុះក្រោយមក បុរសនោះបានឃើញអាហារភោជនរៀបជាថ្មីពាសពេញលើតុ ក៏ចាប់បរិភោគទៅ ហើយធ្វើដំណើរតទៅទៀត ដើរកាត់ព្រៃតូចធំ អស់ពេលយូរថ្ងៃ ទើបដល់ទៅជនបទមួយ បានជួបនឹងពួកឈ្មួញ ៥០០ នាក់ ក្នុងម្នាក់ៗ មានរទេះ

មួយរយ ១, លុះឃើញដូច្នោះ បុរសកំសត់ ក៏ចូលទៅសុំទឹកបរិភោគ សន្ទនាគ្នាដោយសេចក្តីរាក់ទាក់, ទីបំផុតក៏សាកសួរថា លោកពូ! ហេតុដូចម្តេច បានជាលោកពូមិនឈប់នៅទីនេះសិន ដើម្បីសម្រាកឲ្យគោផឹកទឹក ស៊ីស្មៅស្រួលបួលផង ។ ពួកឈ្មួញស្រែកប្រាប់ថា ឱលោកអើយ! ឈប់នៅទីនេះយូរពុំបានទេ ព្រោះទីនេះមានឧបសគ្គដោយយក្សស្រីម្នាក់ វាចាំកំញើញមិនឲ្យពួកខ្ញុំសំចតនៅទីនេះ ។ បុរសឮដូច្នោះក៏សួរថា ចុះយក្សស្រីនោះនៅទីណា? ជូនខ្ញុំទៅបានឬទេ? ។ ពួកឈ្មួញនិយាយថា កុំទៅអីលោក! យក្សស្រីនេះកាចសាហាវណាស់ វានៅឆ្ងាយពីទីនេះប្រហែល ៤-៥ សិន ។ ដោយបុរសនោះទទូចខ្លាំងពេក, ពួកឈ្មួញក៏ជូនទៅដល់កន្លែងយក្សស្រីនោះ ។ បុរសឃើញដូច្នោះ ក៏ដើរចូលទៅគ្មានកោតញញើតអ្វីឡើយ ។

យក្សស្រី កាលបើបានឃើញពួកឈ្មួញដើរចូលមក ក៏ស្រែកកំញើញដោយប្រការផ្សេងៗ ។ បុរសនោះ ក៏ប្រើខ្សែចងដំបងវាយយក្សស្រីនោះ ។ យក្សស្រីដោយត្រូវនឹងដំបងយ៉ាងខ្លាំង ក៏ស្រែកទ្រហោយំសូមចុះចាញ់ ទុកតែជីវិតទៅ ទោះបើលោកបង្គាប់ដូចម្តេច ពុំហ៊ានរឹងទទឹងឡើយ ។ បុរសនោះថា "បើដូច្នោះអញដោះលែងនាងឯងបាន ប៉ុន្តែ ត្រូវទៅមុខកុំមកទីនេះទៀត" និយាយហើយ បុរសកំសត់បានដោះ

លែងយកស្រីនោះ ។ យកស្រីមានចិត្តត្រេកអរណាស់ សំពះលាបុរស នោះគេចបាត់ទៅ ។

ឯពួកឈ្មួញ មានសេចក្ដីស្ញប់ស្ញែងចំពោះឫទ្ធិរបស់បុរសកំសត់ជាខ្លាំងថា "យ៉ី! បុរសនេះខ្លាំងពូកែណាស់ហ្ន៎! ពួកយើងគួរជូនទ្រព្យសម្បត្តិដល់គាត់ខ្លះទើបគួរ ព្រោះគាត់បានជួយយើងឲ្យបានរួចពីសេចក្ដីអន្ដរាយ", គិតគ្នាស្រេចហើយ ពួកឈ្មួញក៏យកវត្ថុផ្សេង ៗ ជូនបុរសនោះ ។

បុរសគិតថា បើអញយករបស់នេះខុសបណ្ដាំគ្រូថា "គេឲ្យច្រើនកុំយក" លុះគិតឃើញដូច្នោះហើយ ក៏និយាយទៅពួកឈ្មួញថា ខ្ញុំមានចិត្តត្រេកអរចំពោះអំណោយរបស់លោកជាទីបំផុត ប៉ុន្តែសូមឲ្យលោកយកទ្រព្យសម្បត្តិនេះ ទៅប្រកបការងាររបស់លោកវិញចុះ ខ្ញុំសូមលាលោកទៅកាន់ស្រុកកំណើតវិញ ខ្ញុំចេញពីស្រុក ៤ ឆ្នាំហើយ ពុំដឹងជាមាតាបិតាប្រពន្ធកូនបានសុខទុក្ខដូចម្ដេចទេ ។

ពួកឈ្មួញបានសាកសួរឈ្មោះ ទីលំនៅ ឃុំ ស្រុក ខេត្រ នៃបុរសកំសត់ ។ ក៏ប្រាប់ឈ្មោះទីលំនៅសព្វគ្រប់ដល់ពួកឈ្មួញ ហើយលាពួកឈ្មួញចេញដើរទៅ បានដល់គេហដ្ឋានរបស់ខ្លួន ឃើញប្រពន្ធកូនទាំងអស់សុខសប្បាយតាមធម្មតា, បុរសកំសត់សប្បាយចិត្តណាស់ គិត

ថា  អញចេញទៅរៀនសិល្បសាស្ត្រអស់រយៈវេលា ៤ ឆ្នាំ ឥតបានវិជ្ជាអ្វីសោះ បានតែពាក្យបណ្តាំ ៤ ម៉ាត់ប៉ុណ្ណោះ ។

អ្នកស្រុកដឹងខាង  កាលបើបានឃើញបុរសកំសត់ត្រឡប់មកពីរៀនវិជ្ជាវិញ គ្មានឃើញតែអ្វីមួយ ជាកំស្តុតាងយកមកផ្ញើប្រពន្ធកូន ក៏និយាយចំអកឡកឡឺយទៀតថា  ប្រពន្ធនៅផ្ទះ រកព្រឹកខ្វះល្ងាច  រកល្ងាចខ្វះព្រឹក ដើរតែសូមទានគេ ។

បុរសនោះ ទឹកខ្មាស់គេជាខ្លាំង  ប៉ុន្តែមិនដឹងធ្វើដូចម្តេច ។

ឯពួកឈ្មួញ  លុះទៅដល់ផ្ទះខ្លួនវិញ  ក៏ពិគ្រោះគ្នាថា  យើងតាំងពីកើតមក  ពុំដែលបានឃើញមនុស្សណា  មានឫទ្ធិដូចបុរសនោះសោះ, យើងត្រូវទឹកគុណគាត់កុំភ្លេច  ក្នុងពេលដែលយើងជូនទ្រព្យគាត់ៗពុំយក ដូច្នេះ យើងត្រូវនាំគ្នាទៅលេងនឹងគាត់ម្តង  យកទ្រព្យសម្បត្តិទៅជូនគាត់ដល់ផ្ទះក្រែងគាត់ទទួលយក ។ គិតគ្នាស្រេចហើយ  ពួកឈ្មួញទាំងនោះក៏ផ្ទុកទ្រព្យសម្បត្តិលើរទេះ សេះ ដំរី  បរឆ្ពោះទៅកាន់ស្រុកបុរសកំសត់ប្រមាណជាង ៩ ថ្ងៃ  ទើបដល់ទៅភូមិនោះ,  បានសាកសួរអ្នកស្រុកនូវឈ្មោះភូមិស្រុកនឹងឈ្មោះបុរសកំសត់ ។ គេក៏ចង្អុលបង្ហាញថា  ផ្ទះរបស់បុរសនោះតូច  ហើយប្រក់ស្បូវមើលទៅឃើញលិមៗ ។  ពួកឈ្មួញក៏តម្រង់ទៅយ៉ាងប្រញាប់ លុះទៅដល់ផ្ទះបុរស  បានជួបនឹងបុរសម្នាក់ទៀត

កំសួរថា លោកដែលទើបត្រឡប់មកពីរៀនវិជ្ជានៅផ្ទះទេឬ? ។ មនុស្សនោះឆ្លើយថា ហៅរកលោកធ្វើអ្វី! អាហ្នឹងខោមិនខោ អាវមិនអាវ ប្រពន្ធកូនរកតែបាយស៊ីគ្មាន រកព្រឹកខ្វះល្ងាច រកល្ងាចខ្វះព្រឹក ។ ពួកឈ្មួញបានស្គាល់ផ្ទះបុរសនោះហើយ ក៏នាំគ្នាចូលត្រសន់ទៅ លុះឃើញបុរសវិជ្ជានោះហើយ នាំគ្នាលុតជង្គង់ប្រណម្យអញ្ជលីគ្រប់ ៗ គ្នា ៗ បុរសនេះ ក៏ក្រោកទទួលពួកឈ្មួញដោយសេចក្ដីកក់តាក់ក្រៃលែង ។ មនុស្សជិតខាងឃើញហេតុដូច្នោះ, ក៏នឹកក្នុងចិត្តថា ឈ្មួញទាំងនេះរកធ្លុត ឬអី? បានជាលុតជង្គង់សំពះមនុស្សអនាថា កំសត់ទុគ៌តរកបាយស៊ីគ្មាន ។

ឈ្មួញទាំងឡាយបានសាកសួរពីដំណើរបុរសនោះ ដែលមកតាមផ្លូវ ៗ បុរសក៏បានប្រាប់វិញតាមដំណើរ ។ តមកពួកឈ្មួញសួរថា ដីភូមិនេះ ជាដីរបស់លោកឬ? ។

— ដីនេះ ជាដីរបស់គេទេ ខ្ញុំគ្រាន់តែសុំគេសង់ខ្ទមមួយប៉ុណ្ណោះ (បុរសឆ្លើយ) ។

ពួកឈ្មួញក្ដដូច្នោះ ក៏ពិគ្រោះគ្នាថា " យើងគិតទិញដីនេះ ឲ្យបាន ៥០០ ព្យាម ៤ ជ្រុង សម្រាប់សង់ផ្ទះមួយជូនលោក ហើយធ្វើយ៉ាំង ជង្រុក ក្រោលគោ-ក្របី នឹងធ្វើកំពែងព័ទ្ធជុំវិញ " លុះពិគ្រោះគ្នាហើយ ក៏រកទិញដីអ្នកស្រុកគ្រប់ចំនួន ៥០០ ព្យាម នាំគ្នាសង់ផ្ទះមួយយ៉ាំងស្អាត

ព្រមទាំងឃ្លាំង ជង្រុកនឹងសម្ភារៈដទៃទៀតជាច្រើន, លុះសង់រួចហើយ កំដញ្ជូនទ្រព្យសម្បត្តិដាក់ឃ្លាំង ដាក់ជង្រុក ហើយអញ្ជើញបុរសវិជ្ជា ព្រមទាំងប្រពន្ធកូនឲ្យឡើងនៅលើគ្រឹះស្ថានដ៏ស្តុកស្តម្ភនោះ ។

ចៅបុរសព្រមទាំងប្រពន្ធកូន ក៏ឡើងទៅលើគ្រឹះស្ថានដោយរីករាយ ទៅជាអ្នកមានមួយយ៉ាងធំ ។

ឯពួកឈ្មួញ បានសួមចងជាមិត្តដ៏ស្និទ្ធទៅអនាគត ។

បុរសនោះ មានកេរ្តិ៍ឈ្មោះល្បីសុសសាយពេញទាំងព្រះនគរ ។ ដំណឹងនេះមិនបាត់ស្ងាត់ក៏ជ្រាបទៅដល់ព្រះមហាក្សត្រម្ចាស់ផែនដី ។ ព្រះអង្គទ្រង់ត្រាស់បង្គាប់ឲ្យបុរសនោះចូលគាល់, លុះទ្រង់សាកសួរបុរសនោះជ្រាបសព្វគ្រប់ហើយ ក៏ទ្រង់ព្រះរាជទានងារដល់បុរសកំសត់ជាមហាសេដ្ឋីក្នុងទីក្រុងនោះ ។

មហាជនពេញទាំងព្រះនគរ មានសេចក្តីកោតស្ញប់ស្ញែងបុរសនោះយ៉ាងអស្ចារ្យ ។

# រឿងព្រេងប្រទេសយូហ្គោស្លាវី

ចែងអំពី " ប្រណីតភាព "

ប្រែពីភាសាអង់គ្លេស

ដោយភិក្ខុ ម៉ែង-វៀម

សិស្សពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ

---

សម័យមួយ មានបុរស ៣ នាក់ ដែលមានដើមព័រមួយដើម ហើយដាក់វេនគ្នាថែរក្សាឈើនោះ ៗ កាលណា ជនពីរនាក់ទៅធ្វើការ, អ្នកទី ៣ តែងបិតនៅផ្ទះ ដើម្បីថែរក្សាដើមព័រ កុំឲ្យមានសេចក្ដីអន្តរាយណាមួយ ឬ អ្នកណាមួយមកលួចបេះផ្លែឈើនោះបាន ។

គ្រានោះ មានទេវតាមួយរូប ដែលត្រូវគេបញ្ជូនចុះពីស្ថានសួគ៌ ដើម្បីមកពិសោធមើលចិត្តថ្លើមនៃជនទាំងបីរូបនោះ, ក្លែងភេទធ្វើជាយាចករូបហើយ , បានចូលទៅជិតដើមព័រក្នុងថ្ងៃដែលបងច្បងបំផុតនៃជនទាំង ៣ នាក់ត្រូវវេនយាម បានលាដៃលូកទៅខាងមុខរួចនិយាយថា :

– ប្អូនប្រុស , ក្នុងនាមនៃព្រះជាម្ចាស់សួគ៌ សូមប្អូនចែកផ្លែព័រទុំឲ្យបងមួយមក ! ៗ

បុរសឆ្លើយតប ដោយជូនផ្លែមួយទៅយាចកក្លែងក្លាយថា :

– ខ្ញុំសូមជូនមួយនេះ , ប៉ុន្តែផ្លែឯទៀត ខ្ញុំជូនមិនបានទេ ព្រោះជារបស់ក្រុមបងប្អូនខ្ញុំ ។

ទេព្តាថ្លែងអំណរគុណបុរសនោះហើយ ក៏ធ្វើដំណើរចេញបាត់ទៅ ។

ថ្ងៃក្រោយមក ដល់វេនបងបន្ទាប់នៅចាំ ។ ពេលនោះ ទេព្តាបានក្លែងភេទជាយាចក រួចមកសុំផ្លែពីរទុំម្ដងទៀត ។ បុរសជាបងបន្ទាប់បានជូនផ្លែមួយទៅយាចកដោយពាក្យថា :

– សូមអញ្ជើញយកមួយនេះទៅចុះ , ប៉ុន្តែផ្លែឯទៀត ខ្ញុំជូនមិនបានទេ ព្រោះជារបស់បងប្អូនខ្ញុំ ។

យាចកបានដំកបលាបុរសនោះហើយ ក៏ធ្វើដំណើរដើរចេញទៅ ។

ថ្ងៃទី ៣ ជាថ្ងៃដែលប្អូនពៅត្រូវវេនយាម ហើយយាចកក្លែងក្លាយក៏ចូលទៅសុំដូចមុន ។ បុរសទី ៣ ក៏ធ្វើដូចបង ១ របស់ខ្លួនដែរ ។

នៅថ្ងៃជាបន្ទាប់មក, ទេព្តាកាលក្លែងភេទជាព្រះភិក្ខុមួយរូបរួចហើយ ក៏ចូលទៅរកក្រុមបងប្អូនទាំង ៣ នាក់នោះ តាំងពីព្រលឹម គឺនៅពេលដែលពួកនេះកំពុងតែបិតនៅក្នុងផ្ទះនៅឡើយ ។ ព្រះភិក្ខុបានមានថេរដីកាថា "កូនប្រុស , មក! , មកតាមអាត្មា ; ប្រហែលជាអាត្មាអាចរកវត្ថុអ្វីមួយជូនកូនឲ្យបានប្រសើរជាងការនៅឃ្លាលដើមពីរ តែមួយដើមនេះ" ។

បុរសទាំងបីនាក់ បានដើរតាមភិក្ខុក្លែងក្លាយនោះ អស់កាលយ៉ាងយូរ ទើបបានទៅដល់មាត់បឹងមួយ ដែលមានកងមូល ហើយមានទឹក

ស្រៅ ៗ កិក្កុ បានសួរទៅបងប្អូនបំផុតថា៖

–កូនប្រុសឪពុក, បើប្រសិនណាជាអាត្មាជូនពរដល់កូន, តើកូនត្រូវការពរបែបណា ?

–ពន្លឺនេះទៅជាការមួយអស្ចារ្យណាស់ បើប្រសិនជាទឹកបឹងទាំងមូលនេះ ក្លាយទៅជាស្រាទំពាំងបាយជូរ ហើយបានមកជារបស់ខ្ញុំ, (បុរសឆ្លើយ) ៗ

ក្បៀណនោះ ទេវតាបានលើកដំបងរបស់ខ្លួន ហើយគូសជាសញ្ញាកាកបាទ ហើយភ្លាមនោះ ទឹកបឹងទាំងមូលបានក្លាយទៅជាស្រាទំពាំងបាយជូរដែលកើតពីការបិតយ៉ាងធំ ៗ មនុស្សទាំងឡាយ នាំគ្នាពាក់ស្រាបំពេញធុងដ៏ច្រើន រួចប្រមៀលចុះឡើង ៗ មហាទ្រព្យាហកម្មមួយក៏ប្រាកដឡើង ជាមួយគ្នានឹងពេង ផ្ទះហោង ហើយមនុស្សទាំងឡាយតែចុះឡើង ដោយរវល់ ហើយបាននាំគ្នាលើកបុរសជាបងប្អូនបង្អស់ ធ្វើជាចៅហ្វាយរបស់ខ្លួន ដោយសេចក្តីគោរព ៗ

ឥឡូវ ពររបស់អ្នកបានសម្រេចហើយ, (កិក្កុពោល) ប៉ុន្តែនៅពេលដែលអ្នកបានឡើងជាអ្នកស្តុកស្តម្ភនេះ ចូរកុំភ្លេចនូវទុលិទ្ធភាពនៃព្រះអាទិទេពឲ្យសោះ ៗ

ពេលនោះ កិក្កុនិងបុរសពីរនាក់ទៀតបានចេញដំណើរតទៅមុខ, ទោលបុរសជាបងប្អូនឲ្យនៅរវាក់នឹងទ្រព្យាហកម្មស្រារបស់ខ្លួន ហើយគេ

ទៅរហូតបានដល់កលចំការមួយ ជាទីដែលគេចិញ្ចឹមហ្វូងព្រាបជាច្រើន ។

-បើប្រសិនណាជាអាត្មាជូនពរមួយដល់អ្នក (ភិក្ខុពោលទៅកាន់បងបន្ទាប់), តើអ្នកត្រូវការអ្វី ? ។

- រកទីងទៅជាហេតុដ៏អស្ចារ្យសម្បើមណាស់, (បុរសឆ្លើយ), បើប្រសិនណាជាហ្វូងព្រាបទាំងអស់នេះ ក្លាយទៅជាហ្វូងចៀម ហើយបានមកជារបស់ខ្ញុំ ! ។

ទេព្តាបានលើកដំបងខ្លួនរួចគ្រវីធ្វើជាសញ្ញាគាកបាទ ហើយមួយរំពេចនោះ ចំការទាំងមូល ក៏ពោរពេញទៅដោយហ្វូងចៀម ។ ហើយមានកេងបង្ហា, មានផ្ទះច្រើនខ្នង, ស្ត្រីទាំងឡាយ នាំគ្នារែកទឹកដោះមេចៀម ហើយជួសយកខ្លាញ់ចេញពីទឹកដោះទាំងនោះមកធ្វើជា ប្រហូម៉ាស ។ មានហ្វូងបុរសរៀបចំបាក់បែងម្ហូបលក់ជាផ្សារ ហើយមនុស្សដទៃទៀត នាំគ្នាសំអាតកេមចៀម ។ មនុស្សទាំងឡាយនោះ កាលដែលគេសម្រាំចុះ - ឡើង ក៏មកញ៉ែញបុរសជាបងបន្ទាប់ទៅធ្វើជាចៅហ្វាយនាយរបស់ខ្លួន ដោយគោរព ។

ពេលនោះ ទេព្តាបានពោលថា :

– ឥឡូវ អ្នកបានសម្រេចសេចក្តីប្រាថ្នារបស់អ្នកហើយ, ប៉ុន្តែនៅពេលដែលអ្នកបានក្លាយខ្លួនទៅជាបុរស ប្រកបដោយសុភមង្គលបែបនេះ ចូលអ្នកកុំភ្លេចនូវទុគ្គតភាព នៃព្រះអាទិទេពឡើសោះ ! ។

ទេព្តា នឹងបុរសជាប្អូនពៅ បានបន្តដំណើរខ្លួនទៅមុខទៀត ហើយទេព្តាបានពោលថា:

– កូនប្រុស, ចូរឯងធ្វើសំណូមពារមួយនឹងគេចុះ ! ។

បុរសឆ្លើយតបទេព្តាដោយស្ងប់ស្ងៀមថា:

– បពិត្រលោកឪពុក, របស់ដែលខ្ញុំអង្វរករព្រះម្ចាស់សួគ៌ឲ្យជួយនោះ មានតែមួយទេ គឺភរិយាប្រកបដោយគុណសម្បត្តិ សច្ចៈ គួរឲ្យគោរព តែប៉ុណ្ណោះ ។

– កូនឯង សុំតែនេះ ជាតែមួយគ្រជាទីបំផុតក្នុងលោក ! ( ទេព្តាឆ្លើយ ); ក្នុងលោកនេះស្ត្រីដែលប្រកបដោយគុណសម្បត្តិ, សច្ចៈ គួរគោរពនោះ មានតែបីនាក់ទេ, ហើយពីរនាក់ត្រូវគេដណ្តឹងទៅហើយ, ចំណែកឯស្ត្រីទី ៣ ជាព្រះអគ្គមាស់ ហើយពេលនេះ កំពុងតែត្រូវព្រះមហាក្សត្រពីព្រះអង្គ បញ្ចុះបញ្ចូលឲ្យរៀបការជាមួយ ។ បើដូច្នេះ, ចូរយើងទៅរកព្រះមហាក្សត្រ ដើម្បីក្រាបទូលទ្រង់ពីសេចក្តីសុំរបស់ឯង ។

ពេលនោះ គេដើរដោយល្ហិតល្ហៃតាមផ្លូវឆ្ពោះទៅទីក្រុង ជាទីដែលព្រះអគ្គមាស់គង់នៅ, ដល់ហើយ ក៏ចូលទៅក្នុងព្រះបរមរាជវាំង, មានអាការៈដូចជាផុនដាបយ៉ាប់យ៉ឺនដោយដំណើរ ។

ព្រះមហាក្សត្រទ្រង់អនុញ្ញាតឲ្យជនទាំង ២ រូប ចូលក្រាបបង្គំគាល់

ហើយកាលដែលជនទាំង ២ រូបក្រាបទូលពីបេសកម្មរបស់ខ្លួន ព្រះមហាក្សត្រក៏លាន់ព្រះឧស្ឋថា:

– យី, ឲ្យខ្ញុំសម្រេចយ៉ាងណាទៅហ៎? ស្តេចពីរអង្គ ហើយឥឡូវថែមបុរសកំលោះមួយទៀត ចូលមកសុំចងមេត្រីភាពដើម្បីបុត្រីខ្ញុំ ក្នុងថ្ងៃជាមួយគ្នា! តើឲ្យខ្ញុំថាម៉េចទៅ ? ។

– ក្រាបទូល រឿងនេះ ទុកឲ្យព្រះអង្គម្ចាស់សួគិសំរេចវិញចុះ! (ទេព្ធាឆ្លើយ) ។

– អីចឹងមែនហើយ, ប៉ុន្តែត្រូវធ្វើយ៉ាងម៉េច ? ។

– តាមរបៀបនេះ សូមទ្រង់មេត្តាប្រោសកាត់មែកទំពាំងបាយជូរចំនួនបីមែកមក ហើយសូមឲ្យព្រះរាជធីតាព្រះអង្គ ជ្រើសញាណលើមែកទាំងបីសំគាល់នូវឈ្មោះផ្សេងៗគ្នា នៃគូដណ្តឹង ។ រូបហើយ, សូមព្រះរាជធីតា យកមែកទាំងបីទៅដោតដាំនៅក្នុងឧទ្យាន, នារាត្រីនេះ ។ បើមែកណាមានផ្កាក្នុងវេលាយប់នេះ, មានចង្កោមទំពាំងបាយជូរទុំ ក្នុងវេលាព្រឹក, សូមទ្រង់អនុញ្ញាតឲ្យឈ្មោះ ដែលមានជាប់នៅលើមែកនោះ ទទួលព្រះមង្គលាភិសេកជាមួយព្រះរាជធីតា នៃព្រះករុណាក្រាបទូល ! ។

– អើ! យោបល់នេះ ចំជាឆើតមែន! (ព្រះមហាក្សត្រទ្រង់ប្រកាស) ។

ពេលនោះ ព្រះអង្គម្ចាស់ក្សត្រី ទីងតួដណ្តឹង បានយល់ព្រមតាមយោបល់នេះ, ហើយព្រះអង្គ បានសរសេរឈ្មោះតួដណ្តឹងលើ ម្លែកទំពាំងបាយជូរបីម្លែករួចយកទៅដាំ ។

ព្រឹកឡើង គេឃើញម្លែកពីរ បានស្វិតស្រពោនជ្រុះស្លឹកស្ទើរអស់, ម្លែកទីបី មានស្លឹកខៀវខ្ចី មានបន្ត្រោមផ្លែទំពាំងបាយជូរទុំ, ឯឈ្មោះដែលចារឹកនៅលើម្លែកមានផ្កា គឺជាឈ្មោះនៃបុរសជាប្អូនពៅគេនោះឯង ។ ព្រះមហាក្សត្រទ្រង់ទទួលអាជ្ញានៃព្រះម្ចាស់សួគ៌នេះ ដោយឥតមានសោកស្តាយអ្វីឡើយ, ទ្រង់នាំព្រះរាជធីតាទៅកាន់ព្រះវិហារ ហើយអនុញ្ញាតឲ្យបុត្រីរៀបមង្គលាភិសេក ជាមួយបុរសប្លែកនោះទៅ ។ បន្ទាប់មក, ព្រះមហាក្សត្របានប្រសិទ្ធិពរជ័យ រួចបញ្ជូនអ្នកទាំងពីរ ចេញពីប្រាសាទ ឲ្យទៅតាមទេវតា ដែលនាំអ្នកទាំងពីរចូលទៅក្នុងព្រៃ រួចទុកអ្នកទាំងពីរចោលក្នុងទីនោះ ។

មួយឆ្នាំកន្លងផុតទៅ ទេវតាត្រូវគេបញ្ជូនត្រឡប់មកកាន់ផែនដីម្តងទៀត ដើម្បីពិនិត្យមើលឲ្យដឹងថា តើបុរសជាបងប្អូនទាំងបីនាក់ ក្លាយទៅជាយ៉ាងណាហើយ ។ កាន់យកខោអាវសំលៀកបំពាក់ជាស្មូមយាចកដូចជាន់មុន, ទេវតាបានចូលទៅរកបងច្បងបង្អស់ ដែលកំពុងតែរវល់រកជាមួយនឹងស្រាទឹកការបិតស្រារបស់ខ្លួន ។

- សូមលោកមេត្តាប្រទានស្រាឲ្យយាចកខ្ញុំ មួយពែងមក: (ទេវតាសុំ) ។

- ថយចេញ, អាយាចកកញ្ចាស់ ! (បុរសគំហកឲ្យ ដោយគំរោះគំរើយ), បើអញចេះតែឲ្យមួយពែង ១ គ្រប់តែយាចកដូច្នេះទៅ ខ្លួនអញមុខតែនឹងក្លាយទៅជាយាចកមិនខានទេ ! ថយចេញទៅ ! ។

ទេព្តា លើកដំបងគ្រវី ធ្វើជាសញ្ញាកាកបាទ, ចូរមើល ! ស្រា, ការបិតស្រា, កេង នឹងកម្មករបាត់អស់រលីង ហើយទន្ទេកង់មូល មានទឹកជ្រៅ ក៏ប្រាកដឡើងដូចមុន ។

- ដោយបានជួបភ័ព្វក៏សនាល្អ គាត់ឯងទៅជាក្មេចសេចក្តីទលក្រ របស់ព្រះអាទិទេពអស់, (ទេព្តាពោល ដោយមធ្យ័ត), ត្រឡប់ទៅដើមតរគាត់ឯងវិញទៅ ! ។

ឯទេព្តា បានបន្តដំណើរទៅជួបបុរសជាបន្ទាប់ទៀត ដែលកំពុងតែរវល់ក្នុងកិច្ចការធ្វើទឹកដោះនឹងហ្វ្រូម៉ាសរបស់គេ ។

- ខ្ញុំសូមគោរព, សូមលោកមេត្តាប្រទានមកយាចកខ្ញុំ នូវហ្វ្រូ-ម៉ាសមួយដុំមក ! (ទេព្តាសុំ), ។ អញឲ្យហ្វ្រូម៉ាសទៅមនុស្សកំជិលក្អក គ្មានបានគុណបំណាច់ ដូច្នេះ ម្តេចកើត ! ។

ទេព្តាលើកដំបងឡើងគ្រវីជាសញ្ញាកាកបាទ, ចៀមនឹងទុហខដ្ឋាន ហើយនឹងកិច្ចការរវល់ទាំងអស់ ក៏វិនាសអស់រលីង, ហើយលេចចេញឯចំការដាទីនៅនៃហ៊ុងព្រាប ដែលគេចិញ្ចឹមដូចដើមវិញ ។ ពេលនោះទេព្តាពោលដោយមុិតប្រាយថា ៖

- អ្នកឯងគេចសេចក្ដីទ័លក្ររបស់ព្រះអាទិទេព , ថយត្រឡប់ទៅស្រុកដើមរបស់អ្នកឯងវិញចុះ ! ។

ទេព្ដា បានបន្តដំណើរដោយប្រញាប់ប្រញាល់ឆ្ពោះទៅកាន់ព្រៃដែលខ្លួនបានយកបុរសជាប្អូនទៅទីងប្រពន្ធដែលជាព្រះអគ្គម្ចាស់នោះទៅពេល ។ លោកបានឃើញ អ្នកទាំងពីររស់នៅក្នុងមហាទុគ្គតភាពក្នុងកូនខ្ទមកំព្រកនោះ ។

ទេព្ដា ដែលនៅតែក្លែងភេទជាយាចកគោកយ៉ាកនោះ បានពោលថា ៖

- សូមឲ្យព្រះអាទិទេពបិតនៅជាមួយអ្នក ! ក្នុងនាមព្រះជាម្ចាស់សួគ៌ , សូមលោកប្រទានចំពោះខ្ញុំ នូវសាយកគ្គបន្តិចមក , ហើយខ្ញុំសូមជ្រកនៅទីនេះមួយយប់ផង ។

- ខ្លួនយើងនេះ ជាមនុស្សទីទ័លសម្បើមណាស់ , (បុរសឆ្លើយ), ប៉ុន្តែ សូមអញ្ជើញចូលមក, យើងនឹងចែកឲ្យអ្នក "នូវអ្វីដែលយើងមាន" ។

បុរសជាប្អូនទៅ នឹងព្រះអគ្គម្ចាស់ក្សត្រី បានសំរួលយាចក ដោយជូនភ្លើងសំពប់អាំង , ឯព្រះអគ្គម្ចាស់ក្សត្រីបានរៀបកន្ទុងបី សម្រាប់អង្គុយបរិភោគបាយល្ងាច ។ ប្ដីប្រពន្ធនេះ ក្រខ្វាំងដល់ថ្នាក់ថា ដុំនំប៉័ងដែលចំអិននៅលើចង្ក្រាន មិនមែនធ្វើពីម្សៅសាលីឡើយ គឺធ្វើពីសម្បកឈើមុក ដែលបុរសជាស្វាមីស្វែងរកពីព្រៃមក ។

ប្រពន្ធ បាននិយាយតិចៗថា :

– អ្នក, ខ្ញុំខ្មាសអ្នកណាស់ដោយគ្មានទំប៉ុងពិតប្រាកដជូនអ្នក ដែលជាភ្ញៀវរបស់ខ្ញុំពីសា ។

– ខ្ញុំត្រូវការបន្តិចបន្តួចទេ, (ទេព្តាឆ្លើយដោយញញឹម) ។

ប៉ុន្តែ នៅពេលដែលគេទៅបើកចង្ក្រានមើលហើយស្រាប់តែប្រទះឃើញដុំទំប៉ុងក្រហមឆ្អិនឆ្អើពីមេឡាស្រូវសាលី, ព្រះអង្គម្ចាស់ក្សត្រី ក៏ស្រែកយំឡើងថា, "ឱ, ទេព្តាជួយហើយតើ!" ហើយនាងក៏យំសោកដោយការភ្ញាក់ ផងដោយសេចក្តីសប្បាយចិត្តខ្លាំងពេក ។

ព្រះអង្គម្ចាស់ក្សត្រីបានទាញយកថូដ ដែលពេញដោយទឹកជ្រោះមក, ហើយកាលចាក់ទឹកនេះទៅក្នុងពែង វាស្រាប់តែក្លាយទៅជាសុកទំពាំងបាយជូរដ៏ផ្អែមមួយបែប ។ ចំណែកខាងបុរសជាស្វាមី ក៏គេមានសេចក្តីសប្បាយហួសប្រៀបដូចជាព្រះអង្គម្ចាស់ក្សត្រីដែរ ។

ទេព្តាបានពោលថា :

– ដោយហេតុតែសុភមង្គលរបស់អ្នក, អ្នកមិនបានបំភ្លេចចោលនូវសេចក្តីទីលក្ររបស់ព្រះអាទិទេព, ដូច្នេះ អាទិទេពនឹងផ្តល់រង្វាន់ចំពោះអ្នក! ។

ជាដូច្នេះហើយ, ទេព្តាបានលើកដំបងរបស់ខ្លួនឡើងហើយ គ្រវីធ្វើជាសញ្ញាកាកបាទ ហើយភ្លាមនោះ ខ្ទមទុគ៌តក៏វិនាសបាត់ទៅ ។

ប្រាសាទអស្ចារ្យមួយ ពោរពេញទៅដោយធនធាន ទីងតែវិសេស ៗ ក៏ប្រាកដឡើង ត្រង់ទីដែលខ្ទមបាត់ទៅ ។ ពាសាពាសីទាំងឡាយ ច្រើននាក់ ក៏ដើរចុះឡើងច្រវាក់, រួចគេបានលើកបុរសកំសត់ធ្វើជា "ចៅហ្វាយប្រុស" របស់គេ, លើកព្រះអង្គម្ចាស់ក្សត្រីជាភរិយានៃបុរស នោះធ្វើជា "ចៅហ្វាយស្រី" ។

យាចកគោកយ៉ាក បានក្រោកឈរឡើងដោយមានមុខញញឹម រួចស្តីថា:

- សម្បត្តិទាំងនេះ គឺព្រះអាទិទេពបានឲ្យដល់អ្នក, ហើយសម្បត្តិទាំងអស់នេះ ទឹងទៅជារបស់អ្នក ដកបណាអ្នកបេះចែករំលែកដល់អ្នកដទៃផង ។ ខ្ញុំសូមប្រសិទ្ធិពរសិរីសួស្តីឲ្យកើតមានដល់អ្នក ហើយខ្ញុំសូមលាហើយ ណាកូន! ។

ពេលរួច, ទេព្តាបានត្រឡប់ទៅកាន់ស្ថានសួគ៌វិញ ដើម្បីធ្វើសេចក្តីរាយការណ៍អំពីសោកណាតានៃបេះដូងរបស់បុរសជាប្អូនពៅ ។ ឯបុរសជាប្អូនពៅគេនេះ បានរស់នៅជាមួយភរិយារបស់គេដោយមេត្រីភាព ទឹងសេចក្តីស្នេហាដ៏ជ្រាលជ្រៅតមក ។

-ចប់-

# ផ្នែកកំណត់និងប្រវត្តិការណ៍

## បណ្ណាល័យពុទ្ធសាសនាមួយនៃប្រទេសកម្ពុជា នៅក្រុងរង្គូន (សហភាពភូមា)

លោក ញ៉យ - ប៊ុក រៀបរៀង

---

បណ្ណាល័យពុទ្ធសាសនាមួយរបស់ប្រទេសកម្ពុជា បានឧប្បត្តិឡើងនៅទីក្រុងរង្គូន ( សហភាពភូមា ) ដោយសម្តេចសហជីវិនព្រះបិតាឯករាជ្យជាតិជាទីស្នេហារបស់យើង ទ្រង់បានសព្វព្រះរាជហឫទ័យព្រះរាជបញ្ជាឲ្យស្ថាបនាឡើង ។

កាលឱកាសដែលឯកឧត្តម ទ័-តឹមសួរ ឯកអគ្គរាជទូតប្រទេសកម្ពុជាប្រចាំទីក្រុងបាងកក(១)បានអញ្ជើញទៅបំពេញបេសកកម្មឯទីក្រុងរង្គូន ពីថ្ងៃទី ២៧ ឧសភាទៅថ្ងៃទី ៣ មិថុនា ១៩៥៩. ឯកឧត្តម អ៊ូ-ថាន់ ទុន-អ៊ូង រដ្ឋមន្ត្រីក្រសួងការបរទេស សហភាពភូមា បានមានប្រសាសន៍ចំពោះឯកឧត្តមឯកអគ្គរាជទូតថា: " ពុទ្ធិកសមាគមពិភពលោកប្រទេសភូមាបានស្ថាបនានូវមហាបណ្ណាល័យមួយ ធ្វើពីបេតុងអារម៉េ ជិតសាលសន្និសីទសាសនាអន្តរជាតិ ដើម្បីទីនឹងតម្កល់ទុកនូវឯកសារខាងព្រះពុទ្ធសាសនា

---

១– សព្វថ្ងៃពុំមានឯកអគ្គរាជទូតខ្មែរ ប្រចាំក្រុងបាងកកទេ ព្រោះខ្មែរយើងបានផ្តាច់សម្ពន្ធមេត្រីទូត ជាមួយសៀមតាំងពីថ្ងៃ ២៣ តុលា ១៩៦១ នេះ ។

គឺគម្ពីរ, សៀវភៅ, ក្បួនច្បាប់ប្រពៃណីខាងព្រះពុទ្ធសាសនា ។ ល ។ ការស្ថាបនាខ្លួនមហាបណ្ណាល័យនេះ គឺធ្វើឲ្យបានជាប់រហូតដល់ ២.៥០០ ឆ្នាំទៀត, គឺឲ្យបានដល់អវសាននៃពុទ្ធសករាជគម្រប់ ៥០០០ ព្រះវស្សា ។ នៅក្រោមមហាបណ្ណាល័យនេះ មានសង់បណ្ណាល័យនៃប្រទេសពុទ្ធ-សាសនិកគឺ ប្រទេសស៊ីឡង់, ថៃឡង់ ដែលត្រូវស្ថាបនា ហើយរចនាទៅតាមសិល្បៈប្រពៃណីនិយមនៃប្រទេសរៀង ៗ ខ្លួន . . . ។

ឯកឧត្ដម អ៊ូ-ថាន់-ទុន-អ៊ូង មានប្រសាសន៍តទៅទៀតថា បើប្រទេសកម្ពុជា ចង់ស្ថាបនាបណ្ណាល័យនោះ, ឯកឧត្ដមនឹងបម្រុងទុកកន្លែងមួយក្រោមមហាបណ្ណាល័យនោះ ។

ឯកឧត្ដម ទី-គីមសួរ ថា នឹងឆ្លៀតឱកាសក្នុងពេលដែលសម្ដេចសហជីវិនព្រះប្រមុខរដ្ឋ ព្រះអង្គទ្រង់យាងចុះព្រះទីនាំងអាកាសយានទៅចំណតអាកាសយាន " មីងហ្គាឡាដុង " ឯកឧត្ដមនឹងក្រាបបង្គំទូលសម្ដេចសហជីវិន ចំពោះរឿងនេះ ។

---

ក្នុងពេលនោះ, សម្ដេចសហជីវិនព្រះប្រមុខរដ្ឋជាទីគោរព និងជាទីស្នេហាស្មើដោយជីវិតនៃយើង, ទ្រង់បានយាងចុះព្រះទីនាំងអាកាស-យាននៅទីនោះ, ក្រោយដែលព្រះអង្គទ្រង់វិលត្រឡប់អំពីការបំពេញ

ព្រះរាជបេសកកម្មនៅទីបអីរ៉ូប ,  ទ្រង់ក៏បានសព្វព្រះរាជហឫទ័យតាមសេចក្តីស្នើរបស់ឯកឧត្តម អ៊ូ-ថាន់-ទុន-អ៊ុន, ទ្រង់ឲ្យស្ថាបនាបណ្ណាល័យពុទ្ធសាសនា របស់ប្រទេសកម្ពុជាមួយនៅទីនោះ ទ្រង់បានត្រាស់បង្គាប់ឲ្យសហជីវិនរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ, សាធារណការ, ឃោសនាការ, សិល្បការ ឲ្យប្រជុំដើម្បីនឹងរិះរកនូវមធ្យោបាយ ឲ្យបានសម្រេចនូវសមិទ្ធិ មានការរៀបចំក្បាច់រចនាសិល្បៈដ៏វិចិត្រ ដើម្បីដកលំសៀវភៅក្បួនគម្រោ, នឹងបុកណវត្ថុផ្សេង ៗ ល ។

ក្រសួងទាំង ៤ ក៏បានប្រជុំគ្នា ហើយបានចាត់ឲ្យលោក ពាន់-មូលពាន់ ជាវិស្វករឲ្យទៅពិនិត្យដល់ទីកន្លែងនៅប្រទេសភូមា ចំពោះរឿងនេះ ។ លោក ពាន់-មូលពាន់ បានអញ្ជើញទៅដល់ទីកន្លែងនោះ ក៏បានគូរផែនដី បណ្ណាល័យពុទ្ធសាសនា របស់ប្រទេសកម្ពុជា នៅក្រុងរង្គូននោះសព្វគ្រប់ ។

បណ្ណាល័យ ពុទ្ធសាសនាប្រទេសកម្ពុជានៅទីក្រុងរង្គូននេះ មានសារៈសំខាន់ពន់ពេក ព្រោះថា បណ្ណាល័យនេះ ទុកជានិមិត្តរូបនៃប្រទេសកម្ពុជា ដែលបញ្ចេញនូវស្នាដៃសិល្បៈរុងរឿង ព្រមទាំងធ្វើក្បាច់រចនាតាមទំនៀមទម្លាប់វប្បធម៌ខេមរជាតិ . . . ។ល។ ពួកទេសចរអន្តរ-

ជាតិដែលធ្វើដំណើរទៅមកតាមទីក្រុងរុង្គូន (ប្រទេសភូមា) តែងទៅទស្សនាបណ្ណាល័យនេះ ដែលមានបណ្ណាល័យប្រទេសឯទៀតដូចជាប្រទេសថៃឡង់, ប្រទេសស៊ីឡង់ជាដើមស្ថិតនៅជិត ៗ គ្មានដីប្រទេសយើងដែលរចនាតាមប្រពៃណីរៀង ៗ ខ្លួន ។

បណ្ណាល័យនេះ ជាសំឡេងមួយនៃប្រទេសកម្ពុជា ដែលបានស្ថាបនាឡើង សម្រាប់ដំកល់នូវឯកសារខាងព្រះពុទ្ធសាសនា ព្រមទាំងរៀបចំឲ្យមានលំអ ប្រកបដោយសិល្បៈខ្មែរសុទ្ធ ៗ ឲ្យវិសេសវិសាល ដើម្បីញ៉ាំងកិត្តិសព្ទនៃប្រទេសកម្ពុជាឲ្យល្បីល្បាញពេញសកលលោក ។

ម្យ៉ាងទៀតបណ្ណាល័យពុទ្ធសាសនានេះ ជាថាវរវត្ថុរបស់ប្រទេសកម្ពុជាយើងដែលសម្តេចសហជីវិនជាព្រះអគ្គមគ្គុទ្ទេសក៍ ជាព្រះបិតាឯករាជ្យជាតិជាទីស្នេហានៃយើង ទ្រង់សព្វព្រះរាជហឫទ័យឲ្យស្ថាបនាឡើងដើម្បីញ៉ាំងវប្បធម៌នៃប្រទេសកម្ពុជាឲ្យមានមុខមាត់លើឆាកអន្តរជាតិ ។